ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2012, 14:33
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៦៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោកស្រី ណាតាចា វីស៊ែល រីស៊ើ
*(Ms. Natacha WEXELS-RISER)*

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊័រ
*(Mr. Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក កែត រេយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកគែន *(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស *(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត *(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក គឹម ម៉េងឃី

លោក ឡោ ជុនធី

លោក សំ សុគង់

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោក បាណាបេ ណេគ្វី *(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកកែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក បាណាបេ ណោគ្វី | បារាំង |
| លោក សតឹម ល្មុត (TCW-583) | ខ្មែរ |
| លោក សៅ សារុន (TCW-604) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក សតឹម លូត** (TCW-583)

សួរដោយលោក គង់ សំអុន ផ្តើមពី៖ ........ ទំព័រ ៣
សួរដោយលោក អាកឡូរ វែកគែន ផ្តើមពី៖ ........ ទំព័រ ២៨
សួរដោយលោក សុន អរុណ ផ្តើមពី៖ ........ ទំព័រ៣១
សួរដោយលោក ហ្សាស្តេី ប៉ោ ផ្តើមពី៖ ........ ទំព័រ៣៧
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ........ ទំព័រ៤៨

**ការសួរសំណួរទៅសាក្សី÷ លោក សៅ សារុន** (TCW-604)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........ ទំព័រ៥៣
សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី៖ ........ ទំព័រ៥៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៦]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៅរឿងក្តីនេះ មានវត្តមានគ្រប់ចំនួន។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់រយៈពេលពេញមួយថ្ងៃនៅថ្ងៃនេះ ហើយលិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះសាក្សីបម្រុងទុក តើគាត់មានវត្តមានដែរឬទេនៅក្នុងថ្ងៃនេះ?

[០៩:០៣:៣៧]

**ក្រឡាបញ្ជី៖**

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ ពីសាក្សីថ្ងៃនេះដែលមានរហស្សនាម TCW-604 នឹងមកដល់តុលាការនៅព្រឹកនេះវេលាម៉ោងដប់។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ

២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានស្ដាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

[០៩:០៤:៣៥]

អង្គជំនុំជម្រះយល់ឃើញថា ពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងគាត់អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បានដែរ នៅក្នុងអំឡុងពេលដំណើរការសវនាការ។

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ សម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ ហើយឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងកិច្ចដំណើរការសវនាការសម្រាប់ពេញមួយថ្ងៃនេះ។

[០៩:០៥:៤៤]

សួស្ដីលោក សគីម ល្មុត ហើយអង្គជំនុំជម្រះអរគុណសាក្សីដែលបានខិតប្រឹងប្រែងចំណាយពេលវេលាដ៏មានតម្លៃ ហើយចូលរួមនៅក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយប្រកបដោយភាពអំណត់អត់ធ្មត់ ហើយឥឡូវនេះដល់ពេលវេលានៃការតាំងសំណួរដេញដោលចំពោះលោក ដោយក្រុមមេធាវីការពារក្ដី ដែលអង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន មុន មេធាវីពីរក្រុមទៀត។ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[០៩:០៦:៤០]

**លោក គង់ សំអុន៖**

បាទ សូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះ និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជាដំបូងសូមជម្រាបសួរលោកសាក្សី! ខ្ញុំមេធាវី គង់ សំអុន ជាមេធាវីការពារលោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួនជម្រាបលោក ដើម្បីឲ្យលោកឆ្លើយបញ្ជាក់ជូនទៅក្រុមប្រឹក្សាជំនុំជម្រះ អំពីបញ្ហាដែលជាប់ពាក់ព័ន្ធក្នុងករណីសំណុំរឿង០០២ នេះ។

ជាដំបូង ខ្ញុំបាទសូមសួរលោកទាក់ទងទៅនឹងបរិបទខាងប្រវត្តិសាស្ត្រខ្លះៗ ជាពិសេសទាក់ទងទៅនឹងរូបលោកផ្ទាល់ ជាមួយនឹងចលនាបដិវត្តន៍មុនឆ្នាំ១៩៧៥។

[០៩:០៧:២៨]

លោកបានបញ្ជាក់ក្នុងអង្គសវនាការកន្លងមក អំពីការជួយឧបត្ថម្ភជាប្រាក់បន្តិចបន្តួចទៅដល់ចលនានេះ តើលោកអាចបញ្ជាក់ថែមទៀតទេថា ក្រៅពីថវិកានោះ លោកមានបានជួយជាស្មារតី ឧទាហរណ៍ការផ្តល់យោបល់ ដើម្បីឲ្យចលនាបដិវត្តន៍នោះមានការរីកចម្រើនទៅមុខដែរទេ? ហើយបើមានអ្វីខ្លះបាទ? សូមអញ្ជើញ!

**លោក សតឹម ល្អុត៖**

**ឆ៖** បាទ ខ្ញុំមិនមានទេបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការប្រជុំនៅក្នុងក្រុមការងាររបស់លោក តើលោកធ្លាប់មានការងារបែបនេះទេ ជាការប្រជុំ ឬជាការពិភាក្សា?

**ឆ៖** បាទ ធ្លាប់មានការប្រជុំបាទ។

**ស៖** ដើម្បីកុំឲ្យលោកសាក្សី គាត់យល់ច្រឡំ ខ្ញុំផ្អាកបន្តិចនេះដើម្បីឲ្យមានការបកប្រែ ពីព្រោះកាលណាខ្ញុំសួរលោកជាប់ៗគ្នាទៅ ការបកប្រែជាភាសាផ្សេងទៀតនឹងមិនមានធ្វើទាន់ទេបាទ។ អ៊ីចឹងសូមលោកអធ្យាស្រ័យ។ តើការប្រជុំដែលលោកបានធ្លាប់ចូលរួមនោះ លោកអាចចាំបានពីប្រធានបទអ្វីខ្លះ ដែលលោកបានពិភាក្សានៅក្នុងការប្រជុំនោះដែរទេ?

[០៩:០៩:១៦]

**ឆ៖** បាទ ខ្ញុំមិនបានចាំច្បាស់លាស់ ព្រោះរឿងហ្នឹងវា៣០ឆ្នាំជាង ច្រើនណាស់ហើយ។

**ស៖** បាទ សូមអរគុណ។ តើលោកចាំអ្នកណាដែលលោកធ្វើការជាមួយនោះទេ ឧទាហរណ៍ថា លោកធ្លាប់ទៅប្រជុំជាមួយ ឬក៏លោកដែលធ្លាប់ទាក់ទងជាមួយនៅក្នុងដំណាក់កាលធ្វើការតស៊ូបដិវត្តន៍នោះ? គឺមុនឆ្នាំ៧៥។

**ឆ៖** ខ្ញុំមិននឹកឃើញទេ ព្រោះតែម្តងប្រជុំជាមួយអ្នកនេះ ម្តងប្រជុំជាមួយអ្នកនោះ បាទ។

**ស៖** តើលោកធ្លាប់ដែលជួបជាមួយលោក ខៀវ សំផន អីទេក្នុងមុនឆ្នាំ៧៥?

**ឆ៖** បាទ មុនឆ្នាំ១៩៧៥ ធ្លាប់ជួបគាត់ ព្រោះគាត់ជាៗសភាតំណាងរាស្ត្រ ជារដ្ឋមន្ត្រី ប៉ុន្តែក្នុងការប្រជុំអីផ្សេងៗក្នុងបដិវត្តន៍ គឺថាមិនដែលជួបជាមួយគាត់ទេបាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់-- បាទ ខ្ញុំសួរសាឡើងវិញថា ក្នុងចន្លោះពេលដែលលោក ខៀវ សំផន ចូលទៅក្នុងព្រៃឆ្នាំ៧៥-- មុនឆ្នាំ៦៨ ហ្នឹង តើលោកធ្លាប់ជួបគាត់ក្នុងឋានៈជាអ្វី មុនឆ្នាំ១៩៦៨ ហ្នឹង? ជាកិច្ចការរាជការ ឬមួយក៏កិច្ចការអ្វីដែលលោកមានប្រសាសន៍អម្បាញ់មិញថា ជួប បានជួបនេះ?

[០៩:១១:៤១]

**ឆ៖** បាទ មិនមែនជាកិច្ចការរាជការទេ ចួនកាលជួបថៃដន្យអីនៅកន្លែងធ្វើការអីចឹងទៅ។ មិនមែនជា ព្រោះខ្ញុំគ្មានប្រាស្រ័យទាក់ទងអីជាមួយការងាររបស់គាត់នៅក្រសួងពាណិជ្ជកម្មក៏គ្មាន នៅសភាហ្នឹងក៏គ្មាន តែចួនកាលជួនថៃដន្យអីចឹងទៅនៅភ្នំពេញហ្នឹង ទៅកន្លែងនេះ កន្លែងនោះជួបគាត់ទៅ ហើយស្គាល់គ្នា ព្រោះស្គាល់ស្រាប់ហើយ។

**ស៖** បាទ សូមអរគុណ។ តើលោកមានដែលជួបជាមួយគាត់ លោក ខៀវ សំផន ជួបជាមួយគាត់ពិភាក្សាអំពីរឿងចលនាតស៊ូអីទេ?

**ឆ៖** បាទ មិនដែលទេបាទ។

**ស៖** ចុះក្រោយឆ្នាំ៧០ តើលោកធ្លាប់មានទំនាក់ទំនងជាមួយលោក ខៀវ សំផន ទេ?

**ឆ៖** ក្រោយមកទៀត ខ្ញុំមិនដែលបានជួបអីទំនាក់ទំនងជាមួយគាត់ទេបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការជួយឧបត្ថម្ភ ដែលលោកបានធ្វើចំពោះចលនាបដិវត្តន៍ តើលោកយល់ដូចម្តេចដែរ? ហេតុអីបានជាលោកជួយឧបត្ថម្ភជាថវិកា ដែលលោកមានប្រសាសន៍ថាបន្តិចបន្តួចទៅដល់ចលនានេះ? លោកអាចពន្យល់ក្រុមប្រឹក្សាជំនុំជម្រះបានទេ?

[០៩:១៣:៣៦]

**ប្រធានអង្គជំនុំ៖**

នេះជាសំណួរច្រំដែល ម្សិលមិញមានសំណួរហ្នឹងរួចហើយ។ សាក្សីមិនបាច់ឆ្លើយតបទេ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំសូមបន្ថែមបន្តទៅសំណួរថ្មីមួយទៀត។

**សួរដោយលោក គង់ សំអុន៖**

**ស៖** តើលោកមានឋានៈជាអ្វីដែលក្នុងជួរបក្សនៃបក្សកុម្មុយនីស្តហ្នឹង មុនឆ្នាំ១៩៧៥?

**លោក សគីម ល្មុត៖**

**ឆ៖** មុន១៩៧៥ មិនមានជាបក្សអីកុម្មុយនីស្តអី ក៏មិនមាននិយាយពីបក្សកុម្មុយនីស្ត ពីអីទេពេលនុ៎ង។ ហើយខ្ញុំក៏គ្មានឋានៈជាអ្វីដែរ គ្រាន់ថាប្រជុំអីម្តងម្កាលជាមួយគេអ៊ីចឹង។ ពេលនោះ មិនៗទាន់និយាយអីពីបក្សកុម្មុយនីស្ត ពីស្អីអត់ អត់ៗមានទេពេលនុ៎ង។

[០៩:១៤:៣៩]

**ស៖** បាទ សូមអរគុណ។ តើលោកមានធ្លាប់ឮពាក្យមួយគេហៅថា “សមានជន” ដែលទេនៅក្នុង មុន ឆ្នាំ១៩៧៥ ហ្នឹង?

**ឆ៖** បាទ ធ្លាប់ឮ “សមានជន”។

**ស៖** ក្នុងការប្រតិបត្តិរបស់លោកផ្ទាល់ តើលោកស្ថិតនៅក្នុងថ្នាក់នៃ “សមានជន” នេះដែរទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំដូចជាស្ថិតនៅក្នុងប្រភេទ “សមានជន” នេះបាទ។

**ស៖** លោកអាចពន្យល់ក្រុមប្រឹក្សាជំនុំជម្រះបានទេថា តើ “សមានជន” នេះមានន័យដូចម្តេចដែរ?

**ឆ៖** ខ្ញុំយល់ថា “សមានជន” គ្រាន់ថាមានចិត្តគាំទ្រចលនាហ្នឹង ប៉ុន្តែវាមិនមែនសកម្មទេ។ ផ្ទុយគ្នាអ៊ីចឹង គ្រាន់តែមានចិត្តចង់ជួយ ចង់អីប៉ុណ្ណឹង។

[០៩:១៦:១៤]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅចំណុចទីពីរ ទាក់ទងនឹងការជម្លៀស។ លោកបានជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះជាច្រើនហើយអំពីការជម្លៀស ដែលលោកបានមានប្រសាសន៍ថា លោកបានចាកចេញពីភ្នំពេញ ទៅជាមួយនឹងគេនឹងឯង នៅពេលដែលមានការបញ្ជាប្រាប់ឲ្យចាកចេញពី

ភ្នំពេញក្នុងរយៈពេលខ្លីបាទ។ ខ្ញុំសូមចង់សួរទាក់ទងទៅនឹងបញ្ហាផ្ទាល់ខ្លួនរបស់លោក តើនៅពេលដែលមានការជម្លៀស លោកបានព្យាយាមទាក់ទងរកបុគ្គលណាដែលធ្លាប់បានទំនាក់ទំនងពីមុនមក នៅមុនពេលជ័យជម្នះនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានទាក់ទងទេ ហើយក៏ៗគ្មានមធ្យោបាយនឹងទាក់ទងដែរ ហើយមិនដឹងជាអស់លោកគាត់នៅឯណា នៅឯណី ខ្ញុំមិនដឹងដែរ អត់។ ទោះជាចង់ព្យាយាមក៏ធ្វើវាមិនកើតដែរ មិនដឹងជានៅឯណា។

**ស៖** បាទ សូមអរគុណ។ តើលោកមានទទួល បានទទួលការផ្តល់យោបល់ ឬមួយក៏ការជួបជាលក្ខណៈពិសេសណាមួយពីមន្ត្រីរបស់លោកចលនាបដិវត្តន៍ ចលនាតស៊ូបដិវត្តន៍មុនឆ្នាំ៧៥ នោះទេ នៅក្រោយពេលដែលមានការជម្លៀសហើយនេះ?

[០៩:១៨:០១]

**ឆ៖** បាទ គ្មានទេបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរទៅចំណុចទីបី ទាក់ទងទៅនឹងការចាកចេញពីសហករណ៍នៅខាងត្បូងស្ទឹងមានជ័យ ហើយចូលមកភ្នំពេញនេះណ៎ា។ លោកបានជម្រាបក្រុមប្រឹក្សាជំនុំជម្រះរួចហើយថា មានគេនីរ-- មានគេទៅប្រាប់ប្រធានសហករណ៍ ហើយប្រធានសហករណ៍ហ្នឹងមកជម្រាបផ្ទាល់ ហើយលោកក៏មិនបានជួបជាមួយអ្នកដែលមកនោះដែរ បាទ។ ខ្ញុំសូមសួរបន្ថែមថា នៅពេលដែលប្រធានសហករណ៍ប្រាប់លោកឲ្យមកភ្នំពេញ តើគេមានប្រាប់លោកថាមកកន្លែងណាទេ នៅភ្នំពេញនេះ?

**ឆ៖** បាទ គេមិនបានប្រាប់មុនទេ តែពេលនោះ គឺខ្ញុំចាំថាគឺជាអនុប្រធានសហករណ៍ហ្នឹង ក៏នាំខ្ញុំមកភ្នំពេញ ហើយដូចជាឌុបម៉ូតូអីចឹង ព្រោះតាមខ្ញុំចាំ ឌុបម៉ូតូ។ មកភ្នំពេញ ហើយក៏មក-- ហើយស្នាក់នៅនៅក្បែរមន្ទីររបស់ឧស្សាហកម្ម ដូចខ្ញុំបានជម្រាបពីៗម្សិលអីអីចឹងដែរបាទ។

[០៩:១៩:៤២]

**ស៖** បាទ សូមអរគុណ។ អីចឹង ខ្ញុំសូមបញ្ជាក់លោកសាជាថ្មីថា នៅពេលដែលលោកចាកចេញពីសហករណ៍ខាងត្បូងស្ទឹងមានជ័យនេះ គឺមិនមែនមកម្នាក់ឯងទេ គឺមានអនុប្រធានសហករណ៍ជាអ្នកជូនលោកមកតាមម៉ូតូ បាទ។ តើប្រធានសហករណ៍មានបានជម្រាបលោកជាមុនថា ជូនលោកទៅដាក់នៅកន្លែងណាទេនៅពេលដែលចាកចេញមកហ្នឹង?

**ផ៖** បាទ គេមិនបានប្រាប់មុនទេបាទ។

**ស៖** បាទ សូមអរគុណ។ ចុះពេលដែលលោកមកដល់ភ្នំពេញ នៅពេលដែលលោកចូលទៅកន្លែងមួយហ្នឹង តើលោកដឹងថាជាកន្លែងអ្វីភ្លាមទេ ឬមួយក៏មានការណែនាំដូចម្ដេចដែរ?

**ផ៖** បាទ មកដល់ភ្លាមហ្នឹង ក៏មិនដឹងថាកន្លែងហ្នឹងជាកន្លែងរបស់មន្ទីរណា របស់អ្នកណាដែលទេបាទ។ បន្ទាប់មកបានមានខាងប្រធានមន្ទីរ អីនែ៎ ប្រធានក្រសួងហ្នឹងជួបប្រាប់ថាឲ្យនៅ ស្នាក់នៅនុ៎ងសិនហើយ។

[០៩:២១:០៨]

**ស៖** បាទ សូមអរគុណ។ តើពេលដែលលោកមកដល់ភ្លាម គេទទួលលោកជួបជាមួយនឹងប្រធានហ្នឹងភ្លាម ឬមួយក៏មានរយៈពេលចន្លោះប្រហែលប៉ុន្មានម៉ោង ប៉ុន្មាននាទីអីដែរបាទ?

**ផ៖** ខ្ញុំមិនច្បាស់ទេ ត្រង់ប៉ុន្មាននាទី ប៉ុន្មានម៉ោងហ្នឹង ឬក៏ថ្ងៃហ្នឹងខ្ញុំមិនចាំច្បាស់ទេ គ្រាន់តែថាគេប្រាប់ឲ្យនុ៎ង ក៏នៅទៅ។ បាទ ខ្ញុំមិនចាំប៉ុន្មានម៉ោងក្រោយអីៗ ខ្ញុំមិនច្បាស់ទេបាទ ខ្ញុំមិនចាំម៉ោងទេបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកជួបនៅក្នុងថ្ងៃតែមួយ ឬមួយក៏ថ្ងៃបន្ទាប់ជាមួយនឹងប្រធានស្ថាប័នកន្លែងនុ៎ង?

**ផ៖** បាទ ខ្ញុំមិនចាំទេបាទ។

**ស៖** លោកអាចបញ្ជាក់បានទេថា ប្រធានស្ថាប័ននោះជាអ្នកណា ដែលលោកបានជួបនោះ?

**ផ៖** គឺលោក អន ហ្នឹងបាទ លោក អន ជាឧស្សាហកម្មដែរ។

**ស៖** លោកចាំបានទេ នៅពេលដែលលោកជួបជាមួយលោក អន ហើយហ្នឹង។ លោក អន និយាយជាមួយលោកអ្វីខ្លះ?

**ផ៖** គាត់មិនបាននិយាយពីស្អីផ្សេងៗទេ គ្រាន់តែថាឲ្យខ្ញុំនៅចាំហ្នឹងសិនទៅ ហើយចាំអាចមានថ្នាក់លើអីមកជួបអីណែនាំអីផ្សេងៗ គាត់និយាយតែប៉ុណ្ណឹងផង ព្រោះខ្លួនគាត់គ្មានបានណែនាំថា ខ្ញុំហ្នឹងមកត្រូវធ្វើអីៗ។ គាត់អត់បានបញ្ជាក់អីទេបាទ។

[០៩:២៣:២៨]

**ស៖** បាទ សូមអរគុណ។ គាត់មិនបានបញ្ជាក់ដោយសារគាត់មិនដឹង ឬមួយក៏គាត់មិនមានតួនាទីក្នុងការជម្រាបលោកអំពីកិច្ចការដែលត្រូវធ្វើបន្ត?

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអភ័យទោសលោកប្រធាន សូមជំទាស់ពីព្រះរាជអាជ្ញា ដោយហេតុថា មេធាវីមិនអាចសួរឱ្យសាក្សីគាត់ធ្វើសន្និដ្ឋានពីបុគ្គលម្នាក់ទៀតនោះបានទេបាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានអីឆ្លើយតបទេ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ វាមានបញ្ហាពីរនៅក្នុងកន្លែងនេះ គឺទីមួយទាក់ទងទៅនឹងការដែលសាក្សីអាចដឹងថា អ្នកនោះក៏ដឹង ប៉ុន្តែគាត់ប្រាប់ថាគាត់មិនមានភារកិច្ចក្នុងការជម្រាបទេ។ អ៊ីចឹងវាមានលក្ខខណ្ឌខុសគ្នា មិនមែនមានន័យថា សាក្សីមិនដឹងទាល់តែសោះទេ។ លក្ខខណ្ឌខ្លះ ការទទួលខុសត្រូវវាមានបុគ្គលផ្សេងៗគ្នា អ៊ីចឹងភារកិច្ចដែលឈ្មោះ អន ត្រូវជម្រាបមកសាក្សីអាចមិនមែនជាមនុស្សដែលភារកិច្ច។ បាទ អ៊ីចឹងគាត់ថា គាត់មិនប្រាប់ទេ គាត់មិនជម្រាបទេ។ ឯលក្ខខណ្ឌមួយទៀត គឺអាចក្នុងលក្ខណៈដូចសហព្រះរាជអាជ្ញាបានលើកអម្បាញ់មិញថា សាក្សីមិនដឹងពីបញ្ហាឈ្មោះ អន។ អ៊ីចឹងលក្ខខណ្ឌនេះ វាមានពីរលោកប្រធាន។

[០៩:២៥:០៩]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយនូវសំណួរចុងក្រោយអម្បាញ់មិញ ដែលសួរឡើងដោយមេធាវីទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តទៅសំណួរថ្មី។ រហូតដល់ពេលណា ទើបលោកបានជួបនឹងអ្នកដែលលោក អន ជម្រាបថាជាថ្នាក់លើ?

**លោក សគឹម ល្អុត៖**

**ឆ៖** តាមខ្ញុំចាំ ដូចជាមិនយូរប៉ុន្មានទេ។ មិនយូរដល់ច្រើនអាទិត្យ ច្រើនណាស់មួយថ្ងៃពីរថ្ងៃមិនដឹង។ ខ្ញុំចាំមិនបាន-- ដែលមានខាងលើមកប្រាប់ខ្ញុំថា មានភារកិច្ចអីៗបាទ។ ដូចជាមិនយូរប៉ុន្មានទេ ខ្ញុំមិនចាំចំនួនថ្ងៃទេ តែថាដូចមិនយូរទេបាទ។

[០៩:២៦:១៦]

**សះ** បាទ សូមអរគុណ។ នៅពេលដែលលោកជួបនោះ ជាអ្នកណាគេ? ជាថ្នាក់លើ?

**ធះ** អ្នកដែលចុះមកជួបខ្ញុំនេះហ្នឹង គឺលោក វន វ៉េត តែខ្ញុំមិនដឹងគាត់ឋានៈក្នុងជួរបក្សហ្នឹងយ៉ាងណាៗដែរ តែថាមើលទៅ គាត់វាលើលោក អន ហ្នឹង លោក វន វ៉េត ហ្នឹង។ ហើយមកក៏ប្រាប់ថាខ្ញុំហ្នឹងមកមានការអី វាត្រូវធ្វើអីៗ ហ្នឹង ឲ្យខ្ញុំដឹងត្រួសៗហើយ។ ហ្នឹងគាត់មកប្រាប់។

**សះ** បាទ សូមអរគុណ។ ចុះលោកបានបញ្ជាក់រួចហើយ ថាលោក អន ជាប្រធានក្រសួងនៅកន្លែងដែលលោកបានចូលស្នាក់នៅដំបូង អ៊ីចឹងមែនទេ?

**ធះ** បាទ។

**សះ** បាទ អម្បាញ់មិញនេះ លោកបានបញ្ជាក់ទៀតទេថា អ្នកឈ្មោះ វន វ៉េត ហ្នឹង លោកមិនដឹងឋានៈអ្វីក្នុងបក្សទេ ប៉ុន្តែលោកគិតថា គាត់ធំជាងលោក អន។ អ៊ីចឹងបានន័យធំជាងក្រសួង។ លោកយល់អ៊ីចឹងទេ?

[០៩:២៧:៣២]

**ធះ** បាទ ខ្ញុំយល់អ៊ីចឹងបាទ។

**សះ** បាទ សូមអរគុណ។ នៅពេលដែលជួបលោក វន វ៉េត តើវន វ៉េត ហ្នឹង បានជម្រាបលោកពីកិច្ចការអ្វីដែលត្រូវធ្វើខ្លះ?

**ធះ** រឿងនេះ ក៏ខ្ញុំបានឆ្លើយរួចម្តងពីរដងរួចហើយ គឺថាខ្ញុំឆ្លើយឡើងវិញក៏បានដែរ គឺគាត់មកប្រាប់ខ្ញុំថា មានគណៈប្រតិភូចិនមក គេមានអ្នកធនាគារ និងគណៈប្រតិភូនោះ ហើយខាងគណៈប្រតិភូខ្មែរ ត្រូវមានអ្នកណាម្នាក់ចេះដឹងពីបញ្ហាធនាគារ ដើម្បីទៅស្តាប់គេ។ ហើយថា គាត់ហៅខ្ញុំបង បងឯងចាំហ្នឹងហើយ ចាំដល់ពេលគណៈប្រតិភូគេមក នឹងទៅចូលរួម ហើយក៏ក្រោយមក គាត់ចាត់ចែង ដូចថា គេយកខោអាវអីស៊ីវិលហ្នឹង ឲ្យត្រៀមស្លៀកពាក់ ព្រោះមកពីសហករណ៍មក ស្លៀកខ្មៅ ខោខ្មៅអាវខ្មៅ ហើយដល់ចូលប្រជុំត្រូវមានអាខោយើងធម្មតាហ្នឹង ហើយមានអាវសឺមិអី គឺថាឲ្យត្រៀមខោអាវ ស្បែកជើងអីតែប៉ុណ្ណឹងបាទ។

[០៩:២៨:៥៧]

**សះ** តើ-- ខ្ញុំសូមអរគុណ។ សូមសួរបន្ត តើហេតុដូចម្តេចបានជាលោក វន វ៉េត ហ្នឹង គាត់ដឹងពីសមត្ថភាពរបស់លោក នៅពេលនោះ?

**ធះ** អត់ទោស សូមសួរបញ្ជាក់ម្តងទៀត ខ្ញុំដូចជាស្តាប់មិនសូវ-- មិនយល់ច្បាស់។ សូមសួរ

បញ្ជាក់ម្តងទៀតបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរថា តើមានហេតុផលអ្វី? ឬក៏មានអ្នកណាទៅប្រាប់បានជា -- សូមទោស ខ្ញុំសូមកែសម្រួល កុំឱ្យមានការជំទាស់។ ខ្ញុំចង់សួរថា ហេតុដូចម្តេចបានជាលោក វន វ៉េត ដឹងពីសមត្ថភាពរបស់លោកទាក់ទងទៅនឹងធនាគារ ដែលជាបទពិសោធន៍ជំនាញកិច្ចការធនាគារ? ធ្វើម៉េចបានលោកដឹង ឱ្យគេដឹង ថាលោកមានសមត្ថភាពផ្នែកធនាគារ? បានគេមកហៅលោក?

[០៩:៣០:០០]

**ឆ៖** ខ្ញុំមិនដឹងជានរណាបញ្ជាឱ្យទៅហៅខ្ញុំមកទេ។ ខ្ញុំមិនដឹងទេ ខ្ញុំមិនដឹងនរណាទេ។ ហើយអ្នកដែលដឹងពីខ្ញុំចេះធនាគារនោះវាច្រើនគ្នាដែរ ពីព្រោះនៅធនាគារសម័យនុ៎ង ខ្ញុំក៏គេឯងស្គាល់ច្រើនណាស់។ តែប៉ុណ្ណឹង ហើយខ្ញុំមិនដឹងថា លោក វន វ៉េត លោកណាៗចារឈ្មោះខ្ញុំ ឱ្យទៅយកមក ខ្ញុំក៏ៗៗមិនដឹងដែរទេបាទ។ អស់ហើយបាទ។

**ស៖** សូមអរគុណ។ តើរយៈពេលក្រោយមកទៀត លោកធ្លាប់បានជួបអ្នកណាខ្លះដែលលោកបានស្គាល់ពីមុន ដែលដឹងពីប្រវត្តិរូបរបស់លោក ថាលោកមានសមត្ថភាពចំណេះដឹងផ្នែកធនាគារ? លោកបានជួបអ្នកណាខ្លះទេ?

**ឆ៖** ខ្ញុំដូចមិនបានជួបអ្នកណាផ្សេងទៀតទេ ព្រោះខ្ញុំជម្រាបអំមិញគឺថា អ្នកដែលដឹងថាខ្ញុំចេះធ្វើធនាគារហ្នឹង មានច្រើនគ្នា ហើយខ្ញុំជួប-- ខ្ញុំមិនដឹងថាជួបនរណាដូចថា-- ហើយក្រោយមកជួបលោក វ៉ាន់ រិទ្ធ ហ្នឹងក៏គាត់ដឹងខ្ញុំនៅធនាគារ ព្រោះធ្លាប់ធ្វើការជាមួយគ្នា។ ហើយអ្នកផ្សេងទៀតគេដឹងឬមិនដឹង ខ្ញុំក៏អាចថាអ្នកនេះដឹង អ្នកនោះដឹងដែរបាទ។

[០៩:៣១:៤៥]

**ស៖** បាទសូមអរគុណ។ អម្បាញ់មិញលោកបានលើកឈ្មោះ វ៉ាន់ រិទ្ធ ថាលោកធ្លាប់ធ្វើការជាមួយ។ ខ្ញុំសូមសួរបញ្ជាក់ថា តើលោក វ៉ាន់ រិទ្ធ នេះបានជួបជាមួយនឹងលោកភ្លាម ក្នុងរយៈពេលដែលលោកក្រោយពេលជួបជាមួយលោក វន វ៉េត ឬមួយក៏ក្នុងរយៈពេលយូរ?

**ឆ៖** ភ្លាមហ្នឹងអត់បានជួបគាត់ទេបាទ អត់បានជួបគាត់ទេបាទ។ រហូតទៅដល់តែមានការប្រែប្រួលក្នុងគណៈកម្មាធិការពាណិជ្ជកម្ម ដែលគាត់មកជំនួសលោក ឌឿន នៅពេលនុ៎ងបានជួបហើយ។ រួចចន្លោះហ្នឹងអត់ដែលបានជួបគាត់ទេ។

**ស៖** បាទ។ លោកធ្លាប់ស្គាល់លោក ឌឿន ពីមុនមកទេ?

**ឆ៖** បាទ មិនធ្លាប់ស្គាល់ទេបាទ។

**ស៖** អ៊ីចឹងលោកស្គាល់នៅពេលណា?

**ឆ៖** គឺពេលដែលគេរៀបចំជាគណៈប្រតិភូ ដែលជួបចរចាជាមួយខាងភាគីចិនហ្នឹង គឺថាវាមានគាត់ជាប្រធាន ហើយខ្ញុំហ្នឹងក៏ចូលក្នុង គឺថាអ្នកចេះដឹងខាងធនាគារហ្នឹង គឺចាប់ស្គាល់គាត់ពីពេលនុ៎ងមកហើយៗ។ ហើយក៏ដឹងថាគាត់ហ្នឹងជាប្រធាន គណៈកម្មាធិការពាណិជ្ជកម្ម បន្ទាប់ពីពេលនុ៎ងមកបាទ។

[០៩:៣៣:៥៤]

**ស៖** នៅពេល-- បាទសូមអរគុណ។ នៅពេលដែលលោកមកធ្វើការនៅក្នុងធនាគារ ដែលលោក-- ដែលមានឈ្មោះថា ធនាគារពាណិជ្ជកម្មក្រៅប្រទេស ដែលលោកបានជម្រាបជូនអង្គសវនាការកន្លងមកនេះ តើធនាគារនោះមានរចនាសម្ព័ន្ធដូចម្ដេចដែរ?

**ឆ៖** បាទ ចំពោះរចនាសម្ព័ន្ធហ្នឹង គឺខ្ញុំបានជម្រាបម្ដងហើយ ប៉ុន្តែឥឡូវខ្ញុំជម្រាបឡើងវិញក៏បានដែរ។ គឺថា--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេសំណួរហ្នឹង! ជាសំណួរច្រំដែលទេ។

[០៩:៣៤:៤៩]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ដោយសារខ្ញុំចង់ភ្ជាប់ ប៉ុន្តែមិនថ្មីទេ ខ្ញុំអាចជម្រាបជូនវិញ។ លោកបានបញ្ជាក់ថា មានប្រធានម្នាក់ដែលជានាយក ហើយនិងលោកជានាយករងនៅក្នុងស្ថាប័ននោះ។ តើលោកអាចបញ្ជាក់អំពីបុគ្គលិកនៅក្នុងនោះបានទេថា មានការចាត់តាំងអ្វីផ្សេងទៀតក្រៅពីថ្នាក់ដឹកនាំដែលលោកបានលើកជម្រាបជូននេះ?

**លោក សគីម ល្មុត៖**

**ឆ៖** គ្មានទេបាទ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងការងារប្រចាំថ្ងៃរបស់លោកវិញ ពាក់ព័ន្ធទៅនឹងកិច្ចការធនាគារនោះ តើមានចំណុចអីខ្លះដែលលោកអាចមើលឃើញថា ជាការងាររបស់ធនាគារដែរទេ?

[០៩:៣៦:០៣]

**ឆ៖** មិនមានជាការងារអីដូចថា ដូចធនាគារដែលយើងធ្លាប់ស្គាល់នោះទេ វាគ្មានការងារអីដូចថាធ្វើទៅវាមាន ត្រូវធ្វើបញ្ជី មានផ្នែកនេះផ្នែកនោះអី គឺគ្មានទេបាទ។

**ស៖** បាទ សូមអរគុណ។ សូមលោកបញ្ជាក់សាជាថ្មីថា អត់មានទាល់តែសោះ ឬមួយក៏មានចំណុចណាខ្លះ ដែលអាចបញ្ជាក់ថា វាជាកិច្ចការធនាគារដែរ?

**ឆ៖** ខ្ញុំមិនថាអត់ទាល់តែសោះទេ ប៉ុន្តែវាមាននោះដូចជា វាមិនមានលក្ខណៈអីគួរឲ្យចាប់អារម្មណ៍ទេបាទ។

**ស៖** បាទ សូមអរគុណ។ នៅពេលសាកសួរកន្លងមក លោកបានឆ្លើយថា លោកបានធ្វើការងារជាអ្នកបកប្រែជាច្រើនលើកច្រើនសា ជាពិសេសគឺការបកប្រែជាភាសាបារាំង។ ខ្ញុំសួរថាតើកិច្ចការបកប្រែនេះ វាអាផ្នែកណាមួយទាក់ទងនឹងកិច្ចការធនាគារដែរទេ?

**ឆ៖** ខ្ញុំអាចនិយាយបានថា សឹងតែគ្មាន មានតែរឿងខាងពាណិជ្ជកម្ម រឿងអីៗផ្សេងៗ តែពីរឿងធនាគារ ខ្ញុំថាសឹងតែគ្មាន។

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលដែលលោកបានទទួលការចាត់តាំងឲ្យធ្វើជានាយករងនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យនៅពេលនោះ តើលោកបានទទួលការណែនាំ ការផ្តល់យោបល់ ឬក៏ប្រឹក្សាយោបល់ ការបង្គាប់បញ្ជាដូចម្តេចខ្លះដែរ?

[០៩:៣៨:៣២]

**ឆ៖** បាទ គ្មានការណែនាំអីច្បាស់លាស់ទេបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកមានបានណែនាំពីកិច្ចការធនាគារនេះ ដល់មន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យដែរទេ?

**ឆ៖** ការងារធនាគារនេះ ដំបូងដែលពេលមានគណៈប្រតិភូចិន គេពន្យល់អំពីរឿងបែបបទនាំចេញ នាំចូលឯកសារម៉េច ហើយអស់លោកទាំងនោះមិនយល់ ខាងខ្ញុំក៏ពន្យល់ ពន្យល់ជាទ្រឹស្តីទេ ថាត្រូវធ្វើយ៉ាងម៉េចៗ អាហ្នឹងពន្យល់អ៊ីចឹង។ ជួយពន្យល់គេ ព្រោះអស់លោកនោះគាត់មិនយល់ទេ។ ហើយដល់មកនៅអែបជាមួយគណៈកម្មការពាណិជ្ជហ្នឹង ពេលដែលគេគណៈកម្មការពាណិជ្ជហ្នឹងគេខាងធ្វើឯកសារពាក់ព័ន្ធនឹងនាំចេញ នាំអីហ្នឹង ក៏ជួយប្រាប់គេថា ត្រូវធ្វើបែបម៉េចៗ ប្រាប់គេអ៊ីចឹងហើយគេអ្នកធ្វើទេ ខ្ញុំគ្រាន់តែជួយប្រាប់ប៉ុណ្ណឹង។

[០៩:៤០:០៥]

**ស៖** បាទ សូមអរគុណ។ លោកលើកអម្បាញ់មិញពាក្យថា “គេ” ហ្នឹងសំដៅទៅលើអ្នកណាគេ?

**ឆ៖** “គេ” ហ្នឹង គឺសំដៅទៅអ្នកដែលធ្វើការនៅខាងផ្នែកពាណិជ្ជកម្មនុ៎ង បាទខ្ញុំសូមទោសក្រែងមិនសូវត្រូវម៉េច គឺ “គេ” ហ្នឹងគឺសំដៅដល់អស់អ្នកដែលធ្វើការនៅនុ៎ងបាទ។ មិនមែនគេណាផ្សេងទៀតទេបាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចចាំឈ្មោះអ្នកដែលលោកធ្វើការជាមួយ ដែលលោកមានប្រសាសន៍អំមិញថា នៅៗក្រសួងពាណិជ្ជកម្មហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ។

**ស៖** ក្នុងពេលការងាររបស់លោកបន្ទាប់ពីការតែងតាំងជានាយករងធនាគារហ្នឹងមក តើលោកបានទៅជួយផ្ដល់យោបល់ហ្នឹងជាញឹកញាប់ប៉ុនណាដែរ ដល់មន្ត្រីនៃក្រសួងពាណិជ្ជកម្ម ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ?

[០៩:៤១:៤៣]

**ឆ៖** ខ្ញុំមិនចាំប៉ុន្មានដងៗទេ តែពេលណាគេសួរទៅក៏ពន្យល់គេ ប្រាប់គេទៅ មិនមែនទៅជាបង្រៀនជាវគ្គអប់រំសិក្សាអីក៏គ្មានទេបាទ។ គេមកសួរ ដឹងត្រង់ណាប្រាប់ត្រង់ហ្នឹងទៅបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា រយៈពេលដែលលោកបានពិភាក្សាឬក៏បានប្រាប់ណែនាំទៅដល់មន្ត្រីនោះ រយៈពេលប្រហែលជាប៉ុន្មាននាទី ប៉ុន្មានម៉ោងដែរក្នុងមួយលើកៗ?

**ឆ៖** ខ្ញុំអាចបញ្ជាក់ថាប៉ុន្មាននាទី ប៉ុន្មានម៉ោងទេ ប៉ុន្តែអាចនិយាយជារួមថា វាមិនជាយូរអីប៉ុន្មានទេបាទ គេសួររឿង សួរយើងចំណុចណា យើងឆ្លើយចំណុចនុ៎ង។ ណាប្រាប់បានប្រាប់ ណាខ្ញុំមិនដឹង ខ្ញុំថាអាហ្នឹងខ្ញុំអត់ចេះដែរ។

**ស៖** បាទ សូមអរគុណ។ តើលោកប្រាប់ទៅលើអ្វីដែលលោកនិយាយថាជាទ្រឹស្ដីហ្នឹង លោកអាចចាំថា ជាទ្រឹស្ដីប្រភេទការអនុវត្ត ឬក៏ជាទ្រឹស្ដីនៃការអនុវត្តធនាគារបែបសកលលោក បែបជាសកល? ខ្ញុំសូមសួរសាឡើងវិញ។ ទ្រឹស្ដីដែលលោកបានណែនាំទៅមន្ត្រីរបស់ក្រសួងពាណិជ្ជហ្នឹង ជាទ្រឹស្ដីអនុវត្តទូទៅ ឬក៏ជាទ្រឹស្ដីសម្រាប់ការអនុវត្តពិសេសទៅករណី ដែលគេមកសួរ?

[០៩:៤៤:១០]

**ឆ៖** គឺពន្យល់អំពីទ្រឹស្តីដែលគេអនុវត្តទូទៅលើសកលលោក គឺថាកាលណាធ្វើពាណិជ្ជកម្មក្រៅប្រទេស គេមានទ្រឹស្តី គោលការណ៍របស់គេដែលប្រទេសណាក៏ដោយត្រូវតែធ្វើតាមនុ៎ង។ ហើយអានុ៎ងមួយទៅ។ ហើយមានរឿងពិសេសៗខ្លះ គេមកសួរទៅ ដូចថារឿងជាក់ស្តែង រឿងប្រត្តិបត្តិជាក់ស្តែងខ្ញុំមិនចាំរឿងអីខ្លះទេ ហ្នឹងក៏ប្រាប់គេទៅ ពេលណាខ្ញុំដឹង ពីព្រោះនៅធនាគារហ្នឹង ខ្ញុំមិនចេះគ្រប់ៗផ្នែកទេ ធនាគារផ្នែកច្រើនណាស់។ ពិសោធន៍ខ្ញុំ វាមានតែខាងផ្នែកឥណទាន ខ្ចីលុយ ខ្ចីកាក់ទេ។ ហើយដល់ខាងក្រៅប្រទេសហ្នឹង ខ្ញុំចាំទ្រឹស្តីខ្លះ ហើយក៏ធ្លាប់ធ្វើការឃើញគេធ្វើអីដឹងខ្លះប៉ុណ្ណឹងទេ។ តែខ្ញុំក៏មិនអ្និនអីស៊ីជម្រៅអីទេបាទ។ ហើយគ្រាន់តែដឹងទ្រឹស្តី អាចពន្យល់បាន ហើយនិងការងារជាក់ស្តែងខ្លះយកមក ខ្លះក៏គេពន្យល់ទៅ កន្លែងខ្លះអាហ្នឹងខ្ញុំក៏មិនយល់ថា ខ្ញុំមិនដឹងដែរទេ លៃលកទៅ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ទំនាក់ទំនងការងាររបស់លោកក្នុងសម័យនោះស្ថិតនៅក្រោមស្ថាប័នណា?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេបាទ។

**ស៖** លោកបានជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះកន្លងមកថា មានឈ្មោះ ម៉ី ដែលជានាយករបស់លោក ប៉ុន្តែលោកមិនដែលបានជួប មិនដែលបានស្គាល់អ្នកនោះទេបាទ។ តើលោកមានធ្លាប់ឮគេប្រាប់ថា ឈ្មោះ ម៉ី នោះជាមនុស្សដែលមានពិតប្រាកដ ឬមួយក៏ជាឈ្មោះដែលពុំមានមនុស្សទេ? លោកដឹងទេ?

[០៩:៤៦:៥១]

**ឆ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

**ស៖** សូមលោកបញ្ជាក់សាជាថ្មីថា លោកអត់ដឹងៗ យ៉ាងម៉េច?

**ឆ៖** គឺខ្ញុំអត់ថា តើអ្នកនុ៎ងមានជាមនុស្ស រូបរាង ឬក៏ជាក់ស្តែង ខ្ញុំមិនដឹងដែរ។ អត់ដឹងទេបាទ ឃើញមានអីចឹង តែខ្ញុំមិនដែលជួបគាត់ មិនដឹងជា-- គេគ្រាន់តែដាក់ ឬមានមែន ហើយគ្រាន់មិនឲ្យជួបខ្ញុំ អាហ្នឹងអត់ដឹងអីចឹង។ អត់ដឹង មិនប៊ាន មិនដឹងថាគាត់មានតែឈ្មោះអីចឹង មនុស្សអត់ ខ្ញុំមិនដឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបន្តថា តើលោកធ្លាប់បានរាយការណ៍ទៅថ្នាក់ណាមួយអំពីផែនការរបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេសរបស់លោក ដែលលោកគិតថា គួរធ្វើយ៉ាងម៉េចឲ្យ

ធនាគារហ្នឹងវាល្អប្រសើរ វាដើរ វាជឿនលឿនដែរឬទេ?

**ផ៖** បាទអត់មានទេបាទ អត់មានទេបាទ។ ហើយបើនេះ ខ្ញុំក៏មិនដឹងធ្វើរបៀបម៉េចដែរផែនការ ខ្ញុំម្នាក់ឯង ហើយក៏មិនដឹងជាគោលនយោបាយធំបែបម៉េច? របៀបម៉េច? ដូច្នេះ ខ្ញុំអត់មាន អត់ដែលមានផែនការ ផែនអី ស្នើអីទៅក៏-- ហើយ ឬក៏មានគំនិតផ្ដើមខ្លួនឯងចង់អីចេះ ចង់អីចុះក៏គ្មានដែរបាទ។

[០៩:៤៨:៥១]

**ស៖** ចុះទាក់ទងទៅនឹងថ្នាក់លើវិញពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬក៏ពីក្រសួងនានាដែលជាប់ពាក់ព័ន្ធហ្នឹងដែលមានផ្ដល់យោបល់ ឬក៏ណែនាំលោកឲ្យធ្វើផែនការ ឬចេញជាគោលការណ៍ដើម្បីឲ្យមានការរីកចម្រើនដល់ធនាគារហ្នឹងដែរទេ?

**ផ៖** បាទ មិនមានទេបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកយល់ដូចម្ដេចដែរពីសកម្មភាពការងារជានាយករងធនាគាររបស់លោកនៅពេលនោះ ក្នុងកាលៈទេសៈដូចលោកបានជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះអម្បាញ់មិញនេះ?

**ផ៖** សូម--

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ឆ្លើយទេ! សំណួរនេះសំណួរឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋាន បញ្ចេញគំនិតអត្តនោម័តិខ្លួនឯង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក។ ក៏ប៉ុន្តែសំណួរនេះវាជាប់ពាក់ព័ន្ធទៅនឹងសាក្សីដោយផ្ទាល់--

[០៩:៥០:៣០]

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យសាក្សីឆ្លើយទេ ពីព្រោះសំណួរជាសំណួរនាំឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋាន ថ្ងៃនេះមិនមែនកាត់ទោសសាក្សីទេ។ គឺជារឿងអញ្ជើញគាត់មកធ្វើសាក្សី អ្វីដែលគាត់ដឹង គាត់ឮ គាត់ចងចាំប៉ុណ្ណោះ។ លោកអាចប្ដូរទៅសំណួរថ្មីទៀត។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឲ្យលោកជួយពន្យល់ពាក្យបី។ ទីមួយគឺ “រណសិរ្ស” តើលោក

ធ្លាប់ឮពាក្យហ្នឹងទេពីមុនមក? ហើយមានន័យដូចម្ដេចដែរក្នុងរណៈ-- ពាក្យថា "រណសិរ្ស" នេះ?

[០៩:៥១:៣៣]

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ ធ្លាប់ឮ ប៉ុន្តែខ្ញុំអាចពន្យល់បានទេ ព្រោះរឿងនេះវាជារឿងមុនខ្មែរក្រហមឡើងមកកាន់កាប់ រណសិរ្ស ហ្នឹងខ្ញុំមិនអាចពន្យល់ជូនបានទេបាទ។ ប៉ុន្តែ រណសិរ្ស គឺជាការរួបរួមគ្នាហើយ តែថាយ៉ាងម៉េចៗ អាហ្នឹងវាតាំង-- រឿងពីមុន។

**ស៖** ចុះការ-- ពាក្យថា "រាជរដ្ឋាភិបាល" ដែលប្រើនៅក្នុងសម័យតស៊ូរហូតមកដល់ការអនុម័តរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជាប្រជាធិបតេយ្យ។ លោកយល់ពាក្យនេះទេ?

**ឆ៖** រយៈពេលនោះ ខ្ញុំដូចជាស្រពេចស្រពិលណាស់ គឺថាតស៊ូហើយ ខ្មែរឈ្នះទៅ ចូលមក រយៈពេលប៉ុន្មាន ខ្ញុំៗមិនអាច លើកថែម ជម្រាបអីឲ្យច្បាស់លាស់ទេបាទ។

[០៩:៥២:៥៤]

**ស៖** បាទ សូមអរគុណ។ ពាក្យចុងក្រោយទាក់ទងទៅនឹង "អង្គការ" តើលោកយល់យ៉ាងម៉េចដែរនូវពាក្យនេះមុនឆ្នាំ១៩៧៥?

**ឆ៖** មុន៧៥ ដូចខ្ញុំមិនធ្លាប់ឮពាក្យថា "អង្គការ" ហ្នឹងទេបាទ។

**ស៖** លោកឮនៅពេលណា?

**ឆ៖** គឺក្រោយមក នៅពេលដែលកងទ័ពខ្មែរក្រហមហ្នឹងចូលមកកាន់កាប់កម្ពុជាហ្នឹង បាទ។ ពេលហ្នឹងគឺមានអង្គការ ស្អីអង្គការៗ ចាប់ពីពេលហ្នឹងមក។ ពីមុនដូចមិនដែលឮថា ប្រើពាក្យ "អង្គការ" ហ្នឹងទេបាទ។

**ស៖** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

ខ្ញុំសូមលោកប្រធានអនុញ្ញាតបង្ហាញឯកសារ D279/6 ដែលជាឯកសារនៅក្នុងតុលាការមានលេខ E3/439 ត្រង់ទំព័រទី៧។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីឲ្យចំណងជើងឯកសារ ហើយនិងលេខ ERN បើឲ្យលេខទំព័រហ្នឹង ទំនងជាមិនអាចដោះស្រាយបានជាមួយនឹងភាសាពីរផ្សេងទៀតទេ។

**លោក គង់ សំអុន៖**

ចំណងជើងមានឈ្មោះថា “កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី” លេខ ERN ជាភាសាខ្មែរ 00418545។ ដោយសារអត្ថបទនេះមានសំណួរ កម្រងសំណួរជាលេខរៀង អ៊ីចឹងខ្ញុំសូមជម្រាបជូនលេខរៀងសំណួរត្រង់សំណួរចម្លើយ៣៥ និង៣៦។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ហើយឯកសារនេះដូចមានហើយ។ មន្ត្រីរដ្ឋបាលពិនិត្យឯកសារ ហើយចង្អុលបង្ហាញចំណុចដែលត្រូវដេញដោលដោយមេធាវីជូនដល់សាក្សី។ ហើយឲ្យ-- អនុញ្ញាតឲ្យបុគ្គលិកជំនួយការបង្ហាញឯកសារទៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនេះនៅលើអេក្រង់ទូរទស្សន៍ផងដែរ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

[០៩:៥៧:២៥]

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សី លោកបានឃើញចំណុចនេះហើយ។ បាទ សូមអរគុណ។ សូម-- តើលោកត្រូវការពេលវេលាដើម្បីអានចំណុចនេះទេ?

**លោក សគឹម ល្មុត៖**

**ឆ៖** ខ្ញុំសូមសួរលោកមេធាវីវិញ ថាចង់ឲ្យខ្ញុំឆ្លើយរបៀបម៉េច? បើអានេះ ខ្ញុំបានៗ ខ្ញុំដឹងហើយរឿងហ្នឹង តើឲ្យខ្ញុំឆ្លើយបញ្ជាក់អំមិញម៉េចទៀតបាទ?

**ស៖** បាទ--

**ប្រធានអង្គជំនុំ៖**

លោកពិនិត្យសិនទៅលោកមេធាវី-- អ្ហឺ!លោកសាក្សីគ្រាន់តែពិនិត្យលើចំណុចនេះទៅ ចាំស្ដាប់សំណួរ ព្រោះមេធាវីអត់ទាន់តាំងសំណួរទេ ដោយសារឲ្យលោកមើលនូវខ្លឹមសារនៃចម្លើយរបស់លោកដែលបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកន្លងមក។ អ៊ីចឹងកាលណាមើលចប់ហើយ គាត់នឹងអាចនឹងតាំងសំណួរពាក់ព័ន្ធនឹងចំណុចដែលគាត់ចង់តាំងសំណួរចំពោះលោកនេះ។

សូមអញ្ជើញលោកមេធាវី អាចតាំងសំណួរគាត់បានហើយ!

[០៩:៥៨:៤៩]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ នៅក្នុងសំណួរ-ចម្លើយលេខ៣៥ នេះ លោកបានបញ្ជាក់ថា-- សូមទោស នៅពេលដែលគេសួរថា៖ “តើលោកចាំបានដែរឬទេ អ្នកណាជាអ្នកបង្កើតក្រសួងសេដ្ឋកិច្ច? ហើយបង្កើតនៅឆ្នាំណា?” ហើយលោកបានឆ្លើយថា៖ “ខ្ញុំមិនដឹងពេលណាទេ ប៉ុន្តែនៅក្នុងកិច្ចទំនាក់ទំនងអន្តរជាតិ ខ្មែរក្រហមត្រូវតែមានក្រសួងសម្រាប់ទំនាក់ទំនង។ បើតាមខ្ញុំស្មានប្រហែលជានៅពេលដែលខ្មែរក្រហមបង្កើតរដ្ឋាភិបាល ប្រហែលជាពេលនោះហើយដែលគេបង្កើតក្រសួងសេដ្ឋកិច្ច”។

សំណួររបស់ខ្ញុំសួរថា លោកប្រើពាក្យ “ប្រហែល” និងពាក្យថា “ស្មាន” ក្នុងការបង្កើតក្រសួងសេដ្ឋកិច្ច។ តើលោកមានមូលដ្ឋានអ្វីផ្សេងទេ នៅពេលនោះ បន្ថែមទៀតទេ ដែលនាំឲ្យលោកស្មាន ឬក៏ប្រហែលថា ក្រសួងសេដ្ឋកិច្ចនោះ បង្កើតនៅពេលណានោះ?

[១០:០០:៣៤]

**ឆ៖** បាទ លោកប្រធាន ខ្ញុំបាទសូមជម្រាបលម្អិតពីបញ្ហានេះ។ ទីមួយ ខ្ញុំជម្លៀសចេញពីភ្នំពេញទៅ ខ្ញុំទៅនៅសហករណ៍ធ្វើស្រែមួយវស្សា មួយចម្រូតទៀត។ ដូច្នេះ មួយរយៈពេលនេះ គឺនៅសហករណ៍ ត្រង់គេធ្វើអ្វីភ្នំពេញអីនេះ គឺថាខ្ញុំមិនដឹងទេ។ ទីពីរ ថាគេបង្កើតឆ្នាំណា ពេលណា ក៏ខ្ញុំមិនដឹងដែរ ហើយជាការខ្ញុំប៉ាន់ប្រមាណប្រហែលជាការយល់ដឹងរបស់ខ្ញុំប្រៀបធៀបទៅនឹងគ្រប់ប្រទេស។ វាត្រូវតែមានអីចឹង តែជាក់ស្តែង ខ្ញុំមិនដឹងទេ ប៉ុន្តែថាអានេះជាការយល់ដឹងរបស់ខ្ញុំ។ ប្រទេសណាក៏ដោយ ក៏ត្រូវមានរដ្ឋាភិបាល ត្រូវមានក្រសួងសេដ្ឋកិច្ច ត្រូវអីៗ មានអីចឹងទៅអី។ ដូច្នេះ ខ្ញុំនិយាយហ្នឹងសុទ្ធតែប្រហែលទេ គឺជាការសន្និដ្ឋាន ការយល់ដឹងរបស់ខ្ញុំទេ តាមការចេះដឹងរបស់ខ្ញុំទេ។ ប៉ុន្តែជាក់ស្តែង គឺពីពេលដែលខ្ញុំនៅសហករណ៍នោះ ប៉ុន្មានយូរដែរ ខ្ញុំរយៈពេលហ្នឹង គេបង្កើតអីក៏ខ្ញុំបាទមិនដឹងដែរបាទ។ អាហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹងបាទ។ សូមអស់បាទ។

[១០:០១:៥៩]

**ស៖** បាទ សូមអរគុណ។ សូមលោកពិនិត្យមើលសំណួរ-ចម្លើយទី៣៦។ ខ្ញុំសូមអានជូនលោកយើងនឹងបង្ហាញ-- សំណួរ៖ “យើងនឹងបង្ហាញលោកនូវឯកសារមួយ ដែលនៅក្នុងនោះ មានលេខ ERN 00019108 - 00019126 ដែលមានចំណងជើងថា ការប្រជុំគណៈកម្មការអចិន្ត្រៃយ៍ ដែលមានកាល

បរិច្ឆេទថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥"។ ចម្លើយរបស់លោកបានឆ្លើយថាៈ "ខ្ញុំមិនដែលបានឃើញឯកសារនោះទេ។ គណៈអចិន្ត្រៃយ៍គឺជាគណៈមជ្ឈិម។ ខ្ញុំនៅមានឋានៈទាបណាស់ពេលនោះ។ ពេលនោះ ខ្ញុំមានចំណេះដឹងមែន ប៉ុន្តែខ្ញុំមានឋានៈទាបក្នុងជួរបក្ស"។ ខ្ញុំសូមសួរឲ្យលោកបញ្ជាក់អំពីពាក្យថា "គណៈអចិន្ត្រៃយ៍ គឺជាគណៈមជ្ឈិម" តើលោកអាចបញ្ជាក់បានទេ ត្រង់ចំណុចនេះ?

**ឆ៖** បាទ ទាំងនេះគឺថានៅហ្នឹងឯកសារនេះ ដាក់ថា គណៈអចិន្ត្រៃយ៍ ហើយខ្ញុំគិតថា អចិន្ត្រៃយ៍នេះ គឺគណៈមជ្ឈិមហ្នឹង ខ្ញុំសំដៅទៅថា វាជាពាក្យបារាំងថា *"កុំមីតេ សង់ត្រាល់"* អីៗខាងលើអ៊ីចឹង។ ឈ្មោះជាក់ស្តែងយ៉ាងម៉េច ខ្ញុំមិនដឹងទេ ថាអចិន្ត្រៃយ៍ហ្នឹង គឺជាគណៈកម្មការនៅថ្នាក់ដឹកនាំខាងលើ។ តែនៅឯកសារដាក់ថា គណៈអចិន្ត្រៃយ៍ ដូច្នេះ ខ្ញុំមិនមាននាទីអីនៅក្នុងសមាជិកអចិន្ត្រៃយ៍ ឬមជ្ឈិមហ្នឹងទេ ហើយឋានៈខ្ញុំក៏វាទាបណាស់--

[១០:០៤:២៣]

**ស៖** បាទ ឥឡូវសូមអរគុណ។ ខ្ញុំចង់ឲ្យលោកពន្យល់អ៊ីចេះវិញ ថាពាក្យថា "អចិន្ត្រៃយ៍" ហើយនិង "គណៈមជ្ឈិម ហ្នឹង វាជាពាក្យខុសគ្នា។ ការលើកនៅក្នុងឯកសារនេះខុស ឬមួយក៏លោកយល់ថា អាហ្នឹងវាជារឿងត្រឹមត្រូវ?

**ឆ៖** ចំពោះខ្ញុំគឺថា គណៈអចិន្ត្រៃយ៍ក្តី មជ្ឈិមក្តី ខ្ញុំយល់ថា ជាគណៈដឹកនាំហើយ។ ប៉ុនបើគេចែកជាស្អី ឈ្មោះម៉េច ខ្ញុំៗមិនជំនាញទេ ប៉ុន្តែថាខ្ញុំយល់ថា គណៈអចិន្ត្រៃយ៍ក៏ដោយ មជ្ឈិមក៏ដោយ គឺថាជាគណៈដឹកនាំហើយ។ ហើយត្រង់ថាឯកសារហ្នឹងត្រឹមត្រូវ មិនត្រឹមត្រូវ ខ្ញុំៗមិនអាចសន្និដ្ឋានបានទេ ព្រោះឯកសារហ្នឹងយកមកឲ្យខ្ញុំជួយមើល។

**ស៖** សូមទោសលោកសាក្សី។ ដោយសារឯកសារនេះជាចម្លើយរបស់លោក អ៊ីចឹងហើយបានជាខ្ញុំសូមឲ្យលោកបញ្ជាក់ មិនមែនជាឯកសារយកមកពីណាទេ គឺចង់ឲ្យលោកបញ្ជាក់ពីពាក្យថា គណៈអចិន្ត្រៃយ៍ គឺជាគណៈមជ្ឈិមនេះ ជាសម្តីរបស់លោក ដែលលោកបាននិយាយអ៊ីចឹង លោកគាំទ្រ ឬមួយក៏លោកមិនទទួលស្គាល់ពាក្យនេះទេ? ការនិយាយនេះវាខុស ហើយលោកមិនដឹង លោកមិនយល់ថា តើគណៈអចិន្ត្រៃយ៍ជាអ្វី? គណៈមជ្ឈិមជាអ្វីទេ ការពិតនោះ? សូមលោកជួយបញ្ជាក់។

[១០:០៦:០៥]

**ឆ៖** ចំពោះខ្ញុំ ខ្ញុំយល់ថា ដំបូងគឺថាអចិន្ត្រៃយ៍ក្តី ឬមជ្ឈិមក្តី គឺជាថ្នាក់ដឹកនាំហើយ បាទ ហើយខ្ញុំៗយល់ថាអ៊ីចឹង បាទយល់អ៊ីចឹង។ ឬៗខ្ញុំឆ្លើយមិនច្បាស់ ក៏សូមបញ្ជាក់ម្តងទៀតបាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង នៅក្នុងទស្សនៈរបស់លោកនៅពេលនេះ គឺលោកមិនបានដឹងច្បាស់ទេ ថាគណៈអចិន្ត្រៃយ៍អ្វី? គណៈមជ្ឈិមជាអ្វី? គ្រាន់តែដឹងថា ជាថ្នាក់លើ។ សូមលោកជួយឆ្លើយដាក់ក្បាលមីក្រូបាទ។

**ឆ៖** បាទ ខ្ញុំយល់ចំពោះតែគណៈអចិន្ត្រៃយ៍ក្តី មជ្ឈិមក្តី ជាថ្នាក់ដឹកនាំ វាដូចថាកំពូលទៅចុះបាទ។ ខ្ញុំយល់អ៊ីចឹង ហ្នឹងខ្ញុំៗយល់អ៊ីចឹងបាទ។

**ស៖** បាទសូមអរគុណ។ សូមលោកបើកបន្តទៅទៀតនៅក្នុងឯកសារដដែលនេះ ត្រង់សំណួរចម្លើយ៣៨។ លោកមើលឃើញទេ? សំណួរថា៖ “តើលោកដឹងថាឈ្មោះ ហែម ធ្វើអ្វីនៅក្នុងក្រសួងឧស្សាហកម្ម?” ចម្លើយរបស់លោក៖“ពេលដែលខ្ញុំចូលធ្វើការនៅពេលនោះ គឺ អ៊ិន” នៅក្នុងនេះសរសេរអ៊ិន។ “អ”, “ិ” និង “ន”។ ប៉ុន្តែលោកធ្លាប់ឆ្លើយថា អន ជាប្រធានក្រសួង បើតាមខ្ញុំស្មាន ប្រហែលជាឈ្មោះ ហែម ជាអ្នកមើលពីលើទៀត។ ប៉ុន្តែគាត់មិនបង្ហាញមុខទេ។ ជាសម្តីរបស់លោកបានឆ្លើយទៅអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបសួរមែនទេ-- ចៅក្រមស៊ើបអង្កេតមែនទេ?

**ឆ៖** បាទ ខ្ញុំបានឆ្លើយអ៊ីចឹងមែនបាទ។

**ស៖** ខ្ញុំសូមឲ្យលោកបញ្ជាក់ទាក់ទងទៅនឹងពាក្យថា ខ្ញុំស្មាន ប្រហែលជាឈ្មោះ ហែម។ តើពាក្យថា “ស្មាន” នេះ លោកមានមូលដ្ឋានអីយកមកស្មានដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:០៩:៤៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះជាសំណួរច្រំដែលលោកប្រធាន ដែលថា ហើយជាចម្លើយរបស់គាត់ គាត់ផ្អែកទៅលើសេចក្តីសង្កេតរបស់គាត់លើឯកសារនានា។ ដូច្នេះសំណួរដែលមេធាវីលើកឡើងនេះ គឺសំណួរដដែលបាទ។

**លោក គង់ សំអុន៖**

បាទ ខ្ញុំសូមឆ្លើយតបទៅវិញថា លក្ខខណ្ឌនេះខុសគ្នា។ លក្ខខណ្ឌទីមួយ ខ្ញុំសួរទាក់ទងទៅនឹងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ដែលលោកបានឆ្លើយថា “ស្មាន” លោកសាក្សីឆ្លើយថា “ស្មាន”។

ប៉ុន្តែលក្ខខណ្ឌទីពីរនេះ គឺទាក់ទងទៅនឹងឈ្មោះ ហែម។ ដូច្នេះ ការស្មានមិនមានន័យថា ឲ្យតែស្មានសុទ្ធតែដូចជា ដូចគ្នា និយាយពីពាក្យថាស្មាន ត្រូវតែជាពាក្យច្រំដែលនោះទេ វាមានលក្ខខណ្ឌខុសគ្នា។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យសាក្សីឆ្លើយនឹងសំណួរនេះ។

[១០:១០:៣៧]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គ្មានប្រសិទ្ធភាព។

សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរ ដែលសួរចុងក្រោយដោយមេធាវីការពារក្ដីរបស់លោក ខៀវ សំផន។

**លោក សគីម ល្មុត៖**

**ឆ៖** សូមបញ្ជាក់ថា ពេលនោះមានឯកសារជាច្រើនយកមកឲ្យខ្ញុំអាន។ អានហើយទៅបានឲ្យខ្ញុំជួយៗសន្និដ្ឋាន ជួយយល់ ពន្យល់វាអាចអ៊ីចឹងទេ? ហើយអាហ្នឹងក៏ដែលខ្ញុំស្មាននោះគឺថា មិនមែនខ្ញុំនឹកឃើញស្មានថា ទេ គឺថា ឈរនៅលើឯកសារដែលបង្ហាញឲ្យខ្ញុំហូរហែមក។ ខ្ញុំថា តាមឯកសារហ្នឹង វាគួរ ឬក៏ត្រូវថា លោក ហែម នោះនៅពីលើហើយ។ ហើយដល់ចាប់ចំណុចនេះមក វាអាហ្នឹងពាក់ព័ន្ធនឹងឯកសារដែលយកមកបង្ហាញខ្ញុំបាទ។ ហ្នឹងខ្ញុំសូមបញ្ជាក់អ៊ីចឹង គឺថា មានឯកសារយកមកហូរហែអ៊ីចឹងទៅ មើលទៅថា វាតាមឯកសារហ្នឹង វាប្រហែល ឬក៏ត្រូវថា លោក ហែម ហ្នឹងនៅពីលើគណៈកម្មការឧស្សាហកម្មហ្នឹង ឬក៏ពាណិជ្ជកម្មអីហ្នឹងបាទ។ មិនមែនខ្ញុំស្មាន ដោយសារអង្គុយគិតទៅ ស្មានថា លោក ហែម នៅពីលើ។ ខ្ញុំមិនមែនស្មានអ៊ីចឹងទេបាទ មានឯកសារឲ្យខ្ញុំមើល ឲ្យអាន។ សូមអស់បាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង តាមការបញ្ជាក់របស់លោកអម្បាញ់មិញនេះ គឺលោកស្មានដោយផ្អែកតាមឯកសារ មិនមែនដោយការដឹងនូវហេតុការណ៍ពីមុនមកនោះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយ ពីព្រោះគ្មានឯកសារជាផ្លូវការអីតែងតាំងថា អ្នកណាយ៉ាងម៉េចៗ ក៏ខ្ញុំពីមុនមកក៏ខ្ញុំមិនដែលឃើញដែរ ឈរនៅលើឯកសារដែលព្រះរាជអាជ្ញាយកបានបង្ហាញខ្ញុំ ប៉ុណ្ណឹងទេបាទ។

[១០:១២:៥៣]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសំណួរចម្លើយ៣៩ ចុះមកក្រោមបន្តិចមកបន្ទាប់ពី

៣៨ អម្បាញ់មិញហ្នឹង។ សំណួរថា៖ "យោងតាម យោងទៅតាមសំណួរដែលសួរអម្បាញ់មិញ បានន័យថា ហែម ស្ថិតនៅក្នុងគណៈកម្មការសេដ្ឋកិច្ច ឬក្រសួងសេដ្ឋកិច្ចនៅពេលនោះ ដែលនៅក្រោមការចាត់ចែងរបស់ វន វ៉េត មែនទេ?" លោកឆ្លើយថា៖ "បាទ ប្រហែលជា ហែម នៅក្នុងគណៈកម្មាធិការសេដ្ឋកិច្ចមួយ ជាមួយ វន វ៉េត ឬមួយក៏ខាងលើជាអ្នកចាត់តាំងឲ្យគាត់មកគ្រប់គ្រង ខាងផ្នែកពាណិជ្ជកម្ម"។ ក្នុងលក្ខខណ្ឌនេះដែរ តើលោកមានអ្វីដែលជាមូលដ្ឋានសម្រាប់ឲ្យលោកធ្វើការសន្មតថា ឬក៏សន្និដ្ឋានថា លោក ហែម ស្ថិតនៅក្នុងគណៈកម្មាធិការសេដ្ឋកិច្ច ឬមួយក៏ខាងពាណិជ្ជកម្ម?

**ឆ៖** បាទ បើតាមខ្ញុំចាំមិនខុសទេ គឺថា ក្នុងឯកសារដែលបង្ហាញឲ្យខ្ញុំនេះ ជួយមើលនៅខាងព្រះរាជអាជ្ញាបង្ហាញឲ្យខ្ញុំ ឃើញមានចំណារមួយចំនួនដាក់ថា "ជូនៗ បងវន, បងហែម"។ ខ្ញុំសន្និដ្ឋានទៅតាមឯកសារនេះហ្នំ។ ដូច្នេះ សន្និដ្ឋានអាចថា គាត់ទាំងពីរនាក់ហ្នឹងវានៅគណៈកម្មការសេដ្ឋកិច្ច ដែលនៅពីលើក្រសួងផ្សេងៗ ដូចឧស្សាហកម្ម ពាណិជ្ជកម្មអីអ៊ីចឹង។ ខ្ញុំទៅលើឯកសារហ្នឹង ខ្ញុំមិនមែននឹកស្មានទេ ហើយក៏ទៅតាមឯកសារនុ៎ង វាត្រូវតែវាៗត្រូវតែទៅអ៊ីចឹង យើងយល់ទៅវាអ៊ីចឹង។ មិនមែនស្មាន នឹកស្រមៃទេ គឺឯកសារចារថា ជូន បងហែម, បងវន ហ្នឹងអីៗ អ៊ីចឹងទៅ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងដូចគ្នានេះដែរ ខ្ញុំសូមបញ្ជាក់លោកសាជាថ្មីថា លោក-- តាមអ្វីដែលលោកអះអាងអម្បាញ់មិញនេះ គឺលោកមិនបានដឹងជាអង្គហេតុច្បាស់លាស់ពីទំនាក់ទំនងការងាររបស់ឈ្មោះ ហែម នេះទៅលើស្ថាប័នខាងពាណិជ្ជកម្ម និងខាងសេដ្ឋកិច្ចនោះទេ មុនពេលដែលអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបង្ហាញលោកនោះ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយបាទ។ បាទ អ៊ីចឹងហើយបាទ ទាល់តែមានឯកសារហ្នឹងមកបង្ហាញខ្ញុំ បានប៊ានសន្និដ្ឋានថាអ៊ីចឹង។

**ស៖** តើនៅក្នុងឯកសារដែលខាងអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត បង្ហាញមានឯកសារណាបញ្ជាក់អំពីការបញ្ជា ឬក៏សេចក្តីសម្រេចដែលធ្វើឡើងដោយឈ្មោះ ហែម ដែរទេ? លោកមានបានឃើញទេ?

[១០:១៦:៣៥]

**ឆ៖** ខ្ញុំដូចជាៗមិនបានឃើញឯកសារអីបញ្ជាទេបាទ ឃើញតែឯកសារដែលរាយការណ៍ពីក្រោមទៅលើ ទៅបងហែម, បងវន ហ្នឹង។ ហើយតែបញ្ជាមកវិញ ខ្ញុំដូចជា ក្រែងខ្ញុំភ្លេច ឬអីមិនដឹង តែដូចជាមិនៗឃើញមានដែរទេ បើមានក៏សូមព្រះរាជអាជ្ញាជួយបង្ហាញខ្ញុំវិញផង បើសិនជាមាន។ ខ្ញុំមិន--

បើតាមខ្ញុំចាំ ខ្ញុំមិនៗឃើញមានទេបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតពន្យល់-- គឺថាមានឯកសារដែលយើងពិភាក្សា មានការណែនាំពីថ្នាក់មកលើគឺ D279/6.5 បាទ។

**លោក គង់ សំអុន៖**

ខ្ញុំយល់ថាមិនមែនជាពេលដែលលោកសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារនៅពេលនេះទេបាទ។ ខ្ញុំសូមអនុញ្ញាតបន្តសំណួររបស់ខ្ញុំ។

[១០:១៧:៤៧]

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមលោកពិនិត្យទៅមើលចំណុចចុងក្រោយនៃសំណួរដដែល-- ចម្លើយរបស់លោកក្នុងលេខ សួរឆ្លើយ៣៩ នេះ។ បន្ទាប់ពីខណ្ឌមក ខ្ញុំសូមអានជូន៖ "ធនាគារនោះមិនស្ថិតនៅក្រោមខាងគណៈកម្មាធិការសេដ្ឋកិច្ច ឬពាណិជ្ជកម្មនោះទេ។ ហើយខ្ញុំក៏មិនដឹងថា អ្នកណានៅពីលើខ្ញុំដោយផ្ទាល់នោះដែរ"។ តើនេះជាសម្តីអះអាងរបស់លោកពិតប្រាកដអ៊ីចឹងទេ?

**លោក សតឹម ល្មុត៖**

**ឆ៖** បាទ ខ្ញុំសូមអានចម្លើយរបស់ខ្ញុំឡើងវិញបន្តិចសិនបាទ។ "បាទ ប្រហែលជា ហែម នៅក្នុងគណៈកម្មាធិការសេដ្ឋកិច្ចជាមួយ វន វ៉េត ឬមួយខាងលើជាអ្នកចាត់តាំង ឲ្យគាត់មកគ្រប់គ្រងខាងពាណិជ្ជកម្មនេះទេ"។ អានេះ គឺខ្ញុំៗនិយាយថា ទៅតាមឯកសារនោះ ឃើញថាលោក ហែម និងលោក វន វ៉េត វានៅក្នុងគណៈកម្មាធិការសេដ្ឋកិច្ច។

**ស៖** បាទ សូមអរគុណ។ ចំណុចនេះលោកបានបញ្ជាក់រួចហើយ ខ្ញុំបានសួរលោកកថាខណ្ឌចុងក្រោយនៃសំណួរដដែលបាទ។ ខ្ញុំអានជូនលោកអម្បាញ់មិញ គឺត្រង់ធនាគារនោះមិនស្ថិតនៅក្រោមខាងគណៈកម្មាធិការសេដ្ឋកិច្ច ឬពាណិជ្ជកម្មនោះទេ។ ហើយខ្ញុំក៏មិនដឹងថាៗ អ្នកណានៅលើបញ្ជាខ្ញុំដោយផ្ទាល់ដែរ នោះដែរ។ ចុងក្រោយគេបំផុតនៃសំណួរនេះបាទ។

**ឆ៖** --

**ស៖** សូមអធ្យាស្រ័យលោក សូមចាំក្បាលមីក្រូសិនបាទ។

**ឆ៖** បាទ ខ្ញុំរក្សាចម្លើយរបស់ខ្ញុំបាទ ខ្ញុំមិនដឹងថាអ្នកណាជាផ្តើមគំនិតបង្កើតអីៗ គឺថាខ្ញុំមិនបាន

ដឹងទេបាទ។

[១០:១៩:៥១]

**ស៖** បាទ សូមអរគុណ។ តើលោកមានឆ្ងល់ទេថា ការបង្កើតធនាគារមួយ លោកពុំដឹងថាអ្នកណាជាមេ ហើយក៏ពុំមានកូនចៅនៅ-- ដែលត្រូវគ្រប់គ្រង ពុំមានអ្នកណាដែលត្រូវរាយការណ៍ជូន។ ដូច្នេះ តើវាយ៉ាងដូចម្តេចដែរ?

**ឆ៖** ពេលនោះខ្ញុំឆ្ងល់ដែរ ប៉ុន្តែក៏ ចម្ងល់នេះក៏មិនអាចលើកទៅនិយាយប្រាប់ សួរអ្នកនេះសួរអ្នកនោះបានទេ។ បាទ ខ្ញុំឆ្ងល់ដែរ។

**ស៖** ហេតុអីទៅលោក?

**ឆ៖** ខ្ញុំមិនអាចជូនហេតុផលបានទេបាទ ព្រោះហេតុចង់ដឹងឲ្យខ្ញុំហេតុរបៀបម៉េច ខ្ញុំសូមបញ្ជាក់ត្រង់ហេតុផលហ្នឹង សួរហេតុម៉េច--

**ស៖** ខ្ញុំចង់សួរថា ហេតុអីបានជាលោកថាមិនអាចសួរនាំគេបាន អំពីការបង្កើតធនាគារមួយដែលមិនដឹងថាអ្នកណាជាមេ មិនដឹងថាអ្នកណាជាកូនចៅបែបនេះ?

[១០:២១:០០]

**ឆ៖** សូមជ្រាបថា ខ្ញុំមិនចង់ជជែកយកឈ្នះចាញ់ទេ សូមជ្រាបថា ប្រៀបធៀបនឹងពេលឥឡូវនេះយើងសួរហ៎ តែពេលនោះ គឺថាខ្ញុំមិនៗអាចសួរបាន ខ្ញុំឆ្លើយខ្លីប៉ុណ្ណឹង។ ខ្ញុំមិនអាចសួរបានទេបាទ។

**ស៖** មិនអាចសួរបាន សូមលោកបញ្ជាក់ថា មិនអាចសួរបានដោយកត្តាអ្វី?

**ឆ៖** ខ្ញុំយល់ថាពេលនោះ ខ្ញុំមិនត្រូវសាកសួរអីដេញដោលអី រឿងមូលហេតុអីច្រើនពេកទេ ឲ្យធ្វើប៉ុនណា ធ្វើប៉ុណ្ណឹងទៅ។ អាហ្នឹងខ្ញុំប៉ុណ្ណឹងបាទ។ សួរហេតុផលអីច្រើន ខ្ញុំមិនអាចជម្រាបបានទេបាទ គ្រាន់ថាពេលនុ៎ងខ្ញុំ គេឲ្យធ្វើប៉ុន្នាន ធ្វើប៉ុណ្ណឹងទៅ ហើយបើឆ្ងល់ទុកតែក្នុងខ្លួនឯងទៅ។

[១០:២២:០៣]

**ស៖** លោកអាចបំភ្លឺបន្ថែមទៀតថា លោកឆ្ងល់ទុកនៅក្នុងខ្លួនឯងហ្នឹង ហេតុអីបានជាត្រូវទុកនៅក្នុងខ្លួនឯង នៅពេលដែលយើងមានចម្ងល់? ហើយយើងស្ថានភាពហ្នឹងវាជីក-- លោកថាវាចម្លែកអ៊ីចឹងដែរ។ ពាក្យថា-- ត្រង់ថា ចម្លែកហ្នឹងត្រង់ថា ធនាគារមួយដែលមាន ដែលមិនដឹងថាត្រូវរាយការណ៍ទៅខាងណា ហើយក៏គ្មានកូនចៅគ្រប់គ្រង។ កត្តាអីដែលធ្វើឲ្យលោកមិនអាចនិយាយចេញបាន? អានេះជាសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សាក្សីពិចារណា ហើយឆ្លើយទៅ ព្រោះសំណួរនេះមិនមែនជាសំណួរដែលត្រូវពិភាក្សាជាមួយនឹងមេធាវីប្រឹក្សាជាមួយលោកទេ។ ពីព្រោះមិនមែនជាសំណួរនាំឲ្យចម្លើយហ្នឹងដាក់ពិរុទ្ធភាពលើខ្លួនលោកទេ។ មេធាវីអមរបស់លោកហ្នឹង គឺនៅពេលណាដែលលោកគិតថា សំណួរ ឬក៏ការឲ្យលោកធ្វើអំណះអំណាងហ្នឹង វាគិតទៅថាលោកនិយាយទៅវានឹងដាក់កំហុសមកលើខ្លួនឯង។ ប្រសិនបើលោកគិតអ៊ីចឹង សូមលោកគិតពិភាក្សា ប្រឹក្សាយោបល់ជាមួយនឹងមេធាវី។

[១០:២៣:៤៣]

ដោយឡែកមិនសំណួរផ្សេងទៀត មិនមានភារកិច្ចអីមកពិភាក្សានោះទេនេះ។ ប្រឹក្សាហ្នឹង គឺប្រឹក្សាសំខាន់សំណួរដែលដាក់ពិរុទ្ធភាពលើខ្លួនឯង ថាតើត្រូវឆ្លើយ ឬមិនឆ្លើយ? ឆ្លើយក៏បានដែរ ព្រោះជាសិទ្ធិ សិទ្ធិរបស់លោក លោកអាចឆ្លើយបាន។ តែលោកមានសិទ្ធិមិនឆ្លើយ ប្រសិនបើទំនងចម្លើយរបស់លោកនាំឲ្យទម្លាក់កំហុសលើខ្លួនឯង។ លោកឆ្លើយនឹងសំណួរទៅ ប្រសិនជាលោកនៅចងចាំ ចាំសំណួរ។

**លោក សគឹម ល្មុត៖**

**ឆ៖** មួយអំពីរឿងថាបុគ្គលិកមានម្នាក់ ពីរនាក់នេះ គឺថាកំណត់មកថាមានតែប៉ុណ្ណឹង ក្នុងសេចក្តីប្រកាសដែលបង្កើតហ្នឹងមានតែប៉ុណ្ណឹង។ ហើយខ្ញុំឆ្ងល់ ប៉ុន្តែវាធនាគារមិនពេញលក្ខណៈសម្បត្តិអីអ៊ីចឹង តែ ខ្ញុំយល់ថាពេលនោះខ្ញុំត្រូវតែនៅស្ងៀម ខ្ញុំមិនមានប្រយោជន៍អីនឹងទៅសួរដេញដោល ហើយក៏សួរដេញដោលច្រើនទៅ ក្រែងតែវាប៉ះពាល់លើសុវត្ថភាពរបស់ខ្លួនដែរ។ អាហ្នឹងវាអ៊ីចឹង។

**ស៖** បាទ សូមអរគុណចំពោះសំណួររបស់លោក។ ខ្ញុំសូមសួរសំណួរចុងក្រោយ។ តើនៅពេលដែលលោកធ្វើជានាយករងធនាគារពាណិជ្ជកម្មក្រៅប្រទេសនោះ លោកស្គាល់ឈ្មោះ ហែម ទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ក្នុងការងារនេះ គឺមិនដែរ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:២៥:៥៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមិនចង់ជំទាស់ទេ ប៉ុន្តែសំណួរនេះធ្វើឲ្យសាក្សីភ័ន្តច្រឡំពីព្រោះសាក្សីបញ្ជាក់រួច

ហើយ គាត់ថាគាត់ស្គាល់ ហែម ជាអ្នកណា ហើយគាត់បញ្ជាក់កាលពីម្សិលមិញនោះ គាត់ថា ហែម គឺ ថា ខៀវ សំផន។ អ៊ីចឹងគឺថា បើសួរឲ្យគាត់បញ្ជាក់ឡើងវិញ គឺជាសំណួរដដែលអាចធ្វើឲ្យសាក្សីមាន ការភ័ន្តច្រឡំបាទ។

**លោក គង់ សំអុន៖**

បាទ ខ្ញុំសូមឆ្លើយតប។ សហព្រះរាជអាជ្ញាមានការភ័ន្តច្រឡំចំពោះពេលវេលា។ កាលដែលសួរ ថា លោក ហែម ជាខៀវ សំផន វាជារឿងដោយឡែក។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់បានពីសាក្សីនៅពេលនេះ គឺ ឈ្មោះ ហែម តើគាត់ស្គាល់ទេ នៅឆ្នាំដែលគាត់ជានាយករងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនោះ គឺ ខុសគ្នាស្រឡះបាទ។ សូមអនុញ្ញាតឲ្យសាក្សីឆ្លើយ។

[១០:២៦:៤៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣០:៥៤]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គ្មានប្រសិទ្ធភាព។ លោកមេធាវីអាចតាំង សំណួរជាថ្មីម្ដងទៀត ចំពោះសាក្សីរូបនេះ ឲ្យច្បាស់ដើម្បីគាត់ឆ្លើយបានជាក់ច្បាស់។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំបាទសូមសួរលោកសាក្សី ថាតើលោកស្គាល់ឈ្មោះ ហែម នេះទេ នៅក្នុងខណៈពេល ដែលលោកជានាយករងនៃធនាគារពាណិជ្ជកម្មប្រទេសក្រៅនៃកម្ពុជា?

**លោក សគឹម ល្មុត៖**

**ឆ៖** បាទ សូមឆ្លើយថា ពេលនោះមិនមានការទំនាក់ទំនងអីជាមួយឈ្មោះ ហែម នេះទេ គឺថា ធនាគារគ្មានរាយការណ៍អីទៅៗគាត់ គាត់ក៏មិនរាយការណ៍មកអីៗ បើមកហើយក៏មិនដែលជួបបុគ្គល គាត់ដែរ។

[១០:៣១:៥២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបញ្ជាក់សាឡើងវិញ អ៊ីចឹងបានន័យថា លោកមិនដែលជួប

ទំនាក់ទំនងការងារអ្វីជាមួយនឹងឈ្មោះ ហែម នេះទេ ក្នុងសម័យដែលលោកធ្វើជានាយករងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជានោះបាទ។

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ ខ្ញុំអស់សំណួរ សូមអនុញ្ញាតឲ្យសហការីបន្ត បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្ដល់កន្លែងសម្រាកសមរម្យដល់សាក្សី និងទីប្រឹក្សាសាក្សី នៅក្នុងរយៈពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្ដល់សក្ខីកម្មវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥១នាទី)*

[១០:៥១:១៥]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើមានសំណួរ-- នៅសល់សំណួរទៀត។

សូមអញ្ជើញ!

**លោក អាកទូរ វែកគែន៖**

អរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ខ្ញុំបាទឈ្មោះ អាកទូរ វែកគែន ជាមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរឲ្យបានលឿន។ ខ្ញុំគិតថាប្រហែលជាពីរបីអីទេ។ ខ្ញុំនឹងសួរខ្លីៗទេ។

[១០:៥២:៣៩]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** មុនពេលឈប់សម្រាក លោកបានឆ្លើយថា នៅសម័យកម្ពុជាប្រជាធិបតេយ្យ លោកមិនមានទំនាក់ទំនងអ្វីជាមួយនឹងបង ហែម ទេ។ ខ្ញុំចង់សួរលោកថា នៅសម័យកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ តើលោកមានធ្លាប់គិតទេថា នៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោក លោក ខៀវ សំផន គឺជាថ្នាក់លើរបស់លោក?

**លោក សគីម ល្មុត៖**

**ឆ៖** ខ្ញុំមិនបានគិតអ៊ីចឹងទេ។ ប៉ុន្តែគ្រាន់តែៗសង្ស័យទេ។ តែថា គិតជាជាក់ស្ដែងគាត់ជាថ្នាក់លើអីច្បាស់លាស់ ក៏ខ្ញុំមិនហ៊ានបញ្ជាក់ថា ច្បាស់លាស់ទេ។ ខ្ញុំមិនៗអាចបញ្ជាក់ឲ្យច្បាស់លាស់ថា គាត់ហ្នឹងជាៗថ្នាក់លើរបស់ខ្ញុំទេបាទ។ គ្រាន់តែសង្ស័យថា ប្រហែល សង្ស័យជាគិតអត្តនោម័តិទេ តែថាជាក់ស្ដែងគាត់ថ្នាក់លើមែន ឬមិនមែន មិនដឹងជាការចាត់តាំងខាងលើរបៀបម៉េច ខ្ញុំមិនៗអាចថាជាក់ស្ដែងបានទេបាទ។

[១០:៥៤:២៥]

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកដឹងទេថា លោកខៀវ សំផន មានមុខងារអ្វីនៅក្នុងរដ្ឋ?

**ឆ៖** តាមខ្ញុំចាំគាត់ជានាយករដ្ឋមន្ត្រី អីអ៊ីចឹងមិនដឹងតាមមើល៍ ភ្លេចហើយ ពេលហ្នឹង មែនទែនដូចជានាយករដ្ឋមន្ត្រី។ ហើយត្រង់ឆ្នាំណា ពេលណា ខ្ញុំភ្លេចឆ្នាំហើយ តែក្នុងរយៈពេលនុ៎ង។

**ស៖** តើការដែលលោកស្មានអំពីតួនាទីរបស់លោក ខៀវ សំផន នៅសម័យនោះ តើវាមានឥទ្ធិពលអ្វីទេទៅលើចម្លើយមុនៗរបស់លោក ដែលលោកថា លោកគ្រាន់តែស្មាន ឬក៏លោកសន្និដ្ឋាននោះ? ខ្ញុំសូមរៀបចំសំណួរឡើងវិញ ព្រោះថា ដូចជាមិនសូវច្បាស់សួរអ៊ីចឹងទៅ។ ប្រហែលជាលោក

មិនយល់សំណួរខ្ញុំ។ លោកបាននិយាយថា លោកគិតស្រមៃថា ប្រហែលជាគាត់ហ្នឹងជានាយករដ្ឋមន្ត្រី តើការសន្មតតួនាទីរបស់គាត់ហ្នឹង គឺថានាំឲ្យលោកគិតថា គាត់នៅលើ ជាថ្នាក់លើរបស់លោក តើអ៊ីចឹងមែនទេ? វាថាដែលលោកគិតអ៊ីចឹងទៅ ធ្វើឲ្យលោកនឹកស្រមៃថាគាត់ហ្នឹង មានតួនាទីបែបហ្នឹង តើអ៊ីចឹងមែនទេ?

[១០:៥៦:២៣]

**ឆ៖** បាទ តួនាទីគាត់ជានាយករដ្ឋមន្ត្រី គឺមិនមែនខ្ញុំនឹកស្រមៃទេ ពេលនុ៎ងគឺ ប្រកាសអន្តរជាតិថាគាត់ជានាយករដ្ឋមន្ត្រី តែត្រង់ថា ការងារធនាគារជាមួយខ្ញុំផ្ទាល់នោះ ខ្ញុំមិនដឹងទេ ព្រោះគាត់មិនដែលចុះមកបញ្ជាខ្ញុំថា ធនាគារថាត្រូវធ្វើអ៊ីចេះធ្វើអ៊ីចុះ ក៏មិនដែលឃើញបាទ។

**ស៖** ខ្ញុំសូមអភ័យទោសលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការមើល ពិនិត្យមើលបញ្ហាបកប្រែអត់មានភាសាបារាំងទេ។

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

**អ្នកបកប្រែ៖**

សូមគោរពលោកប្រធាន យើងអាចបន្តបានហើយបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសាក្សីឆ្លើយ សូមឆ្លើយសំណួរអម្បាញ់មិញហ្នឹង សំណួរតបទៅនឹងសំណួររបស់លោកមេធាវីចុងក្រោយនេះឡើងវិញ ព្រោះ--

បញ្ហាខ្មែរម្តង ឥឡូវភាសាខ្មែរអត់មានឮទេ។ ឥឡូវចេញមកសុទ្ធតែអង់គ្លេសដែរខ្ញុំហ្នឹង។

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

**អ្នកបកប្រែ៖**

អាឡូៗ លោកប្រធាន តើលោកប្រធានឮភាសាខ្មែរទេបាទ? បាទ អរគុណពីអ្នកបកប្រែបាទ។

[១០:៥៨:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសាក្សី ឆ្លើយតបនឹងសំណួរចុងក្រោយអម្បាញ់មិញនេះ ដែលសួរដោយមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក សគីម ល្មុត៖**

**ឆ៖** បាទ មុខងារលោក ខៀវ សំផន ជានាយករដ្ឋមន្ត្រីហ្នឹង គឺមិនមែនខ្ញុំនឹកស្មាននោះទេ គឺហ្នឹងគេប្រកាសជាផ្លូវការ លើឆាកអន្តរជាតិតែម្តង។ តែត្រង់មុខងារមួយទៀត ដែលថាគាត់ត្រួតត្រាបញ្ហាលើធនាគារ អាហ្នឹងខ្ញុំមិនអាចបញ្ជាក់បានទេបាទ។ អស់ហើយបាទ។ បាទ ខ្ញុំបាទ មានប៉ុណ្ណឹងបាទ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** តើលោកស្គាល់អក្សរ ឬហត្ថលេខារបស់លោក ខៀវ សំផន ទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេបាទ។

**លោក អាកឡូរ វែកគែន៖**

លោកប្រធានខ្ញុំអស់សំណួរហើយ។

[១០:៥៩:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្ត អង្គជំនុំជម្រះ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សី សគីម ល្មុត។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ សុន អរុណ ជាមេធាវីការពារលោក នួន ជា។ ជាដំបូងខ្ញុំមានសំណួរដូចតទៅនេះ៖ លោកសាក្សីបានជម្រាបទៅសហព្រះរាជអាជ្ញាថា លោកបានចូលបដិវត្តន៍ពីសម័យសង្គមរាស្ត្រនិយមក្នុងទសវត្សរ៍ទី៦០ រឿងនេះពិតអ៊ីចឹងទេ? សូមលោកបញ្ជាក់ម្តងទៀត។

**លោក សគីម ល្មុត៖**

**ឆ៖** បាទ ពិតអ៊ីចឹងមែន។

[១១:០១:០៧]

**ស៖** លោកចាំបានទេ ប្រហាក់ប្រហែលឆ្នាំណាទេ?

**ឆ៖** ខ្ញុំចាំមិនបានទេបាទ មិនដឹងជាឆ្នាំណាទេបាទ។

**ស៖** សូមអរគុណ។ ពេលដែលលោកចូលរួមនៅក្នុងរណសិរ្សដើម្បីបដិវត្តន៍នុំង លោកនៅជានិស្សិតនៅឡើយ ឬលោកបានធ្វើការរួចហើយ?

**ឆ៖** បើតាមខ្ញុំចាំ គឺចូលធ្វើការរួចហើយបាទ។ ធ្វើការរួចហើយបាទ។

**ស៖** ពេលដែលលោកសាក្សីបានចូលរណសិរ្ស ដើម្បីធ្វើការជាមួយនឹងរណសិរ្សពេលនុំង គេហៅថា កាលហ្នឹងមិនទាន់មានរណសិរ្សអីនៅឡើយទេ បើតាមខ្ញុំចាំ គេហៅថា ខ្មែរក្រហមពេលនោះ លោកមិនទាន់មាន-- ពេលនោះលោក តើលោកស្គាល់ ដែលឮឈ្មោះ ហ៊្វុង និង ហ្វ្រ៊ុងទេ?

[១១:០២:៤៣]

**ឆ៖** បាទ ហ៊្វុង និង ហ្វ្រ៊ុងហ្នឹងធ្លាប់ឮ។

**ស៖** លោកចាប់ឮពីពេលណាមក?

**ឆ៖** ខ្ញុំមិនចាំឆ្នាំទេ តែពេលនុំងគឺដូចជាមានរណសិរ្សជាមួយព្រះករុណា ជាមួយអីចលនាអីទាំងអស់ហ្នឹង ហ្វ្រ៊ុង, ហ៊្វុង ហ្នឹង តែត្រង់ឆ្នាំខ្ញុំមិនចាំឆ្នាំច្បាស់លាស់ទេ។

**ស៖** សូមអរគុណ។ ពេលដែលលោកចូលរណសិរ្សហ្នឹង និយាយឲ្យចំមែនទែន ថាតើលោកចូលក្នុងក្រុម ហ្វ្រ៊ុងហ្នឹង ហ៊្វុងហ្នឹង ឬក៏រណសិរ្សរបស់ខ្មែរក្រហម?

**ឆ៖** ដំបូងឡើងគឺថា គ្មានប្រើពាក្យថា ខ្មែរក្រហមអីក៏គ្មានទេ សម័យនុំង មិនទាន់ឮពាក្យថា “ខ្មែរក្រហម” អីទេ។ ហើយដល់ ហ្វ្រ៊ុង, ហ៊្វុង ហ្នឹងខ្ញុំមិនបានចូលជាសកម្មអីនៅក្នុងចលនាហ្នឹងទេ។ អត់បានរួមអី គ្រាន់តែនៅចូលៗ ពីដែលដំបូងនោះ គឺមិនមានឈ្មោះថា ខ្មែរក្រហមអីអត់មានទេបាទ។

**ស៖** លោកបានជម្រាបតុលាការអំមិញថា លោកចូលក្នុងរណសិរ្សក្នុងទសវត្សរ៍ឆ្នាំ៦០។ លោកកាលពីលោកនៅនិស្សិតនៅក្មេងបន្តិច លោកដែលឮថាមានក្រុមច្រើនណាស់ ក្រុមដើម្បីរំដោះជាតិ ឧទាហរណ៍ថា ក្រុម សឺង ង៉ុកមិញ, ក្រុម ចន្ទរង្សី , កៅ តក់ ជាដើម ។ល។ លោកដែលឮពាក្យអស់ហ្នឹងទេ?

**ឆ៖** បាទ ដែរឮបាទ។

**ស៖** ប៉ុន្តែពេលនុំង លោកមិនទាន់បានធ្វើអ្វីសកម្មចូលក្នុងបក្សទាំងអស់ហ្នឹងនៅឡើងទេ មិនអីចឹងណា?

**ឆ៖** បាទ គ្មានទេ ខ្ញុំសូមបញ្ជាក់បន្តិច អំមិញថាប្រើពាក្យ “រណសិរ្ស” ពេលនោះមិនទាន់មានឮពាក្យ “រណសិរ្ស” ហ្នឹងទេ មិនដឹងទេ ខ្ញុំមិនមានទេ “រណសិរ្ស”។ បាទ មកក្រោយទេបានមាន “រណសិរ្ស”។

**ស៖** ខ្ញុំសូមបញ្ជាក់ ខ្ញុំនិយាយអំមិញដូចជាច្រឡំបន្តិច។ កាលសម័យហ្នឹង បើតាមខ្ញុំចាំគឺគេហៅថា “ឥស្សរៈ” ប៉ុន្តែដល់ក្រោយមកទេបានមានពាក្យ “រណសិរ្ស” បាទ។ នៅរយៈពេលទសវត្សរ៍ឆ្នាំ៦០ គឺពីឆ្នាំ៦០ មកដល់ ១៩៧៥ នៅតាមទល់ដែនខ្មែរ-វៀតណាម មានចម្បាំងខ្លាំងក្លារវាងវៀតណាមខាងត្បូងដោយមានអាមេរិកជួយហើយ ជួយ ហើយវ៉ៃគ្នាជាមួយវៀតកុង។ ទ័ពរបស់វៀតណាមខាងជើងហើយបានដាលវាល់ចូលដល់ក្នុងទឹកដីខ្មែរ។

ទាំងអស់នេះសុទ្ធតែជាកត្តា អង្គហេតុនៃការកាប់សម្លាប់របស់ខ្មែរក្រហមដែលបានចោទរួចមកហើយនោះ។ ហើយនៅក្នុងទឹកដីខ្មែរជាប់ទល់ដែនមានទ័ពវៀតកុងបានមកជ្រកកោនរស់នៅគ្រាប់រំសេវថ្នាំពេទ្យនៅដីខ្មែរ។ តើលោកសាក្សីដែលឮ ដែលដឹងតាមរយៈ គេប្រាប់ ឬក៏តាមកាសែតអ្វីទេ?

[១១:០៧:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ! សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថានេះគឺជាបណ្តុំនៃអង្គហេតុដែលមេធាវីធ្វើសក្ខីកម្ម ហើយអាចថាសាក្សីគាត់មិនដឹង។ ដូច្នេះខ្ញុំគិតថានេះជាបញ្ហាមួយដែរ។ សូមអរគុណលោកប្រធាន។

**លោក សុន អរុណ៖**

ខ្ញុំយល់ថា ព្រះរាជអាជ្ញាយល់-- ឆ្លើយជំនួសសាក្សីហើយ ពេលនេះ។ ខ្ញុំសូមបដិសេធ។ ខ្ញុំអាចបន្តសំណួរតទៅទៀត។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៨:៤០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីកត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវ។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរដែលសួរដោយមេធាវីជាតិការពារក្តីលោក នួន ជា អម្បាញ់មិញទេ។ លោកមេធាវីមិន

មែនធ្វើអត្ថាធិប្បាយយ៉ាងវែង ហើយមកសួរសាក្សីទេ។ សូមអង្គន់នូវការតាំងសំណួររបស់លោកឲ្យបាន ខ្លីៗ ដែលសាក្សីមានលទ្ធភាពនៅក្នុងការស្តាប់យល់ ហើយនិងអាចឆ្លើយតបបាន។

**លោក សុន អរុណ៖**

ខ្ញុំសួរ-- ខ្ញុំចោលសំណួរនេះ ហើយខ្ញុំនឹងសួរសំណួរបន្ត។

**សួរដោយលោក សុន អរុណ៖**

**ស៖** ចាប់ពីឆ្នាំ១៩៦៩ និងដើមឆ្នាំ១៩៧០ ពេលនុ៎ងលោកមានទីតាំងនៅឯណា? លោកនៅធ្វើការនៅភ្នំពេញ ឬក៏រូបលោកបានចូលទៅក្នុងរណសិរ្ស ទឹកដីរណសិរ្សរួចហើយ?

[១១:១០:០៧]

**ឆ៖** បាទ ខ្ញុំស្ថិតនៅទីក្រុងភ្នំពេញ។

**ស៖** ពេលនោះលោកធ្វើការ លោកបានចូលធ្វើការនៅក្នុង-- មានការងារធ្វើរួចហើយអ៊ីចឹង?

**ឆ៖** បាទ មានហើយបាទ។

**ស៖** ខ្ញុំយល់ថា លោកជាបញ្ញវន្តម្នាក់ ហើយមានវ័យចំណាស់ល្មមដឹងរឿងគ្រប់គ្រាន់។ ពេលនៅឆ្នាំ១៩៦៩ មកដល់១៩៧០ ពេលនោះលោកមានដែលឮ ឬបានឃើញ ឬឮតាមការកាសែត ឬក៏គេនិយាយថា ទ័ពវៀតណាមខាងត្បូង-- អ្ហឺ! ខាងជើង សូមទោស ចូលមកទឹកដីកម្ពុជាច្រើនណាស់ លោកមានបានដឹងរឿងហ្នឹងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់អ៊ីចេះ គឺថាព្រឹត្តិការណ៍នេះ វាកើតមានមុនសម័យខ្មែរក្រហមចូលកាន់កាប់ ហើយជារឿងប្រវត្តិសាស្ត្រ កាសែតសរសេរអ៊ីចេះ សរសេរអ៊ីចុះ ខ្ញុំមិនអាចយករឿងអស់ហ្នឹងមកបំភ្លឺជម្រាបបានទេបាទ។ សូមអរគុណ។

[១១:១១:៤៧]

**ស៖** ខ្ញុំថានេះជាអង្គហេតុ សម្រាប់អង្គសេចក្តី ហើយជាផ្លូវមួយសម្រាប់ទៅដល់ការកាត់ក្តីដោយយុត្តិធម៌។ លុះដល់ឆ្នាំ១៩៧០ មានខ្មែរក្រហម កាលហ្នឹងមានខ្មែរក្រហម និងវៀតកុង បានវាយទ័ព លន់ នល់ រហូតដល់ឆ្នាំ១៩៧៥។ តើលោកនៅឯណា ពេលនុ៎ង?

**ឆ៖** បាទ ខ្ញុំនៅភ្នំពេញ។

**ស៖** ហើយនៅឆ្នាំ១៩៧៣ ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៣ ទ័ពវៀតកុង មានន័យថា ទ័ពវៀតណាមខាងត្បូង-- អ៎! ខាងជើង សូមទោស បានដកទ័ពចេញមួយចំនួនធំ ពីប្រទេសខ្មែរ នៅពាក់

និងប្រហាក់ប្រហែលពាក់កណ្ដាលឆ្នាំ១៩៧៣ តើលោកសាក្សីបានដឹងរឿងហ្នឹងទេ?

**ឆ៖** រឿងនេះ ខ្ញុំមិនចាំច្បាស់លាស់ទេបាទ។

**ស៖** លោកឆ្លើយថា មិនចាំ មានន័យថា លោកដឹងដែរ ប៉ុន្តែលោកមិនបានចាំអីចឹង ឬក៏លោកមិនដឹងសោះ?

**ឆ៖** ខ្ញុំមិនចាំតែម្ដង បាទ ខ្ញុំមិនចាំបាទ។

**ស៖** ពេល១ដែល-- នៅឆ្នាំ១៩៥៤ ពេលដែលបារាំងឈប់ធ្វើអាណានិគមប្រទេសកម្ពុជា។ ពេលហ្នឹងមានរឿចុងក្រោយបំផុតជាមួយនឹងខាងវៀតណាម គឺនៅ ឌៀនបៀនភូ។ ហើយរដ្ឋាភិបាលបានវៀតណាម បានមកចាប់យកកូនខ្មែរពីអាយុ១៣ ទៅ១៧ឆ្នាំ ឲ្យទៅរៀននៅ-- រៀន សិក្សាអប់រំអំពីទ្រឹស្ដីកុម្មុយនីស្ដតាមបែបវៀតណាម នៅទីក្រុងហាណូយ។

[១១:១៤:៣៣]

ក្រុមនោះបានត្រឡប់មកស្រុកខ្មែរវិញ នេះជាពេលដែលវៀតណាមឲ្យកូនក្មេងត្រឡប់មកកាន់កាប់ប្រទេសកម្ពុជា។ បើតាមខ្ញុំដឹងថា ក្រុមទាំងនេះសុទ្ធតែយកប្រពន្ធជនជាតិវៀតណាមផង តែដោយយថាហេតុយ៉ាងណាទេ ពេលនោះក្រុមខ្មែរកុម្មុយនីស្ដវៀតណាម នោះមិនបានដឹកនាំប្រទេសទៅជាក្រុមកុម្មុយនីស្ដ ប៉ុល ពត និយមចិន ជាអ្នកកាន់កាប់អំណាចទៅវិញ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធានសូមជំទាស់--

**លោក សុន អរុណ៖**

ខ្ញុំនិយាយរឿងបន្តិច ដើម្បីឲ្យគាត់យល់សាច់រឿងហើយ ក្រែងគាត់ភ្លេច ហើយបានខ្ញុំសួរគាត់។ នេះខ្ញុំសូមបន្តបាទ សូមអរគុណ។

**សួរដោយលោក សុន អរុណ៖**

**ស៖** តែដោយយថាហេតុយ៉ាងណា ពេលនោះ ក្រុមខ្មែរកុម្មុយនីស្ដវៀតណាមនោះ មិនបានដឹកនាំប្រទេសទៅជាក្រុមកុម្មុយនីស្ដ ប៉ុល ពត និយមចិន ជាអ្នកកាន់កាប់អំណាចពីឆ្នាំ១៩៧៥ ដល់១៩៧៩ ទៅវិញ។ តើរឿងនេះ លោកដឹងច្បាស់ ដូចមាននៅក្នុងឯកសារទេ? ឬក៏លោកឮគេថា? ខ្ញុំនិយាយពីមុនដំបូងបំផុត ថាលោកជាអ្នក ជាបញ្ញវន្តម្នាក់ ហើយដែលមានវ័យចំណាស់ល្មមដឹង។

[១១:១៦:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាង-- ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ បន្ទាប់ពីសំណួរមុនដែលថាបានសួររួចមកហើយ។ មេធាវីរបស់លោក នួន ជា បានឆ្លៀតយកឱកាសនេះ ដើម្បីសួរសំណួរដើម្បីបង្ហាញនូវទស្សនៈរបស់គាត់ផ្ទាល់ ដោយផ្អែកទៅលើឯកសារជាក់លាក់ណាមួយនោះទេ។ ខ្ញុំគិតថា នេះមិនមែនជាពេលក្នុងការធ្វើរបៀបនេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា! តំណាងសហព្រះរាជអាជ្ញាមានស្ន៊ីលើកឡើងទេ ពីព្រោះអត់មានឱកាសក្នុងការជំទាស់ទេ ប្រសិនបើជំទាស់បានតែមួយម្តងទេ។ ប្រសិនបើភាគីខាងណោះឆ្លើយហើយ យើងមិនអនុញ្ញាតឲ្យភាគីនេះលើកបញ្ហាម្តងទៀត លើបញ្ហាដដែលនោះឡើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

អរគុណលោកប្រធាន។ ខ្ញុំគិតថា សហមេធាវីនាំមុខបាននិយាយ បានលើកឡើងនូវការជំទាស់ដែលខ្ញុំចង់លើករួចទៅហើយ។ សូមអរគុណលោកប្រធាន។

[១១:១៧:២៩]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅនឹងការជំទាស់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ នេះជាអង្គហេតុមួយ ដែលអង្គហេតុមួយសំខាន់បំផុត ឈានទៅដល់ការកាត់ក្តីថ្នាក់ដឹកនាំមេខ្មែរក្រហម ដើម្បីឲ្យមានយុត្តិធម៌ក្នុងការកាត់ក្តី ខ្ញុំទាញយកអង្គហេតុទាំងអស់នេះ យកមកជម្រាបសួរទៅកូនក្តី ដើម្បីតុលាការធ្វើការវិនិច្ឆ័យ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់មានប្រសិទ្ធភាព។ មេធាវីមិនអាចតាំងសំណួរដូច្នេះបានទេ យើងបានរំឭកហើយកាលពីតាំងសំណួរដំបូង ថាមេធាវីគប្បីតាំងសំណួរឲ្យបានខ្លីៗ សមស្រប ដើម្បីឲ្យសាក្សីមានលទ្ធភាពអាចស្តាប់យល់ ហើយនិងឆ្លើយតបបាន។ ទីពីរ អង្គហេតុដែលលោកបានលើកឡើងមកនេះ មិនមាននៅក្នុងដីកាដំណោះស្រាយទេ។ បានន័យថា ជារឿងអង្គហេតុមិនពាក់ព័ន្ធ។ សាក្សីមិនចាំបាច់ឆ្លើយនឹង

សំណួរដែលសួរឡើងដោយមេធាវីការពារក្តីលោក នួន ជា ដែលសួរលោកអម្បាញ់មិញនេះទេ។

**លោក សុន អរុណ៖**

សំណួររបស់ខ្ញុំទាំងអស់ នៅពេលនេះ មានជាងដប់សំណួរ សូមជម្រាបតុលាការ។ ខ្ញុំមិនបានយកនូវ-- នេះ តែសំណួរដែលក្នុងការមានឯកសារក្នុងប្រវត្តិសាស្ត្រ មានសៀវភៅសរសេរច្រើន ហើយការចេះដឹង ការដឹងផ្ទាល់របស់ខ្ញុំ ដែលខ្ញុំបានភពប្រសព្វជាមួយនឹងរយៈពេលនុ៎ង បើ--

[១១:១៩:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ជម្រាបថា អង្គជំនុំជម្រះបានជម្រាបហើយ ទីមួយ ឲ្យលោករៀនរៀបចំនូវការតាំងសំណួរឲ្យបានត្រឹមត្រូវ ដែលមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការភាគី គោលដៅនៃការទទួលសំណួរពីលោក ស្តាប់យល់ នូវខ្លឹមសារសំណួរ។ ទីពីរ សំណួរឲ្យមានការពាក់ព័ន្ធ។ ពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយដែលកំណត់នៅក្នុងដីកាដំណោះស្រាយ។ ឌៀនបៀនភូនេះ ដូចជានៅក្នុងដីកាដំណោះស្រាយ យើងរកមិនឃើញទេ។ យើងមិនមានទេ ប្រសិនបើមាន លោកអាចបង្ហាញយើងបាននូវសង្គ្រាមឌៀនបៀនភូ នៅក្នុងដីកាដំណោះស្រាយណាមួយនៃដីកាដំណោះស្រាយដែលបញ្ជូនមកជំនុំជម្រះ។ ទីមួយទៀត សូមលោកគិតគូរ ហើយនិងចាប់អារម្មណ៍មែនទែន យើងបានរំឭកលោកច្រើនលើកច្រើនសាហើយ។ នៅក្នុងកិច្ចនីតិវិធីសវនាការដេញដោលនេះ ភាគីដែលពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការដេញដោល មិនអាចយកការយល់ដឹង ការដឹង ការចងចាំ របស់ខ្លួន បុគ្គលផ្ទាល់ខ្លួនមកសួរបានទេ។ ប្រសិនបើធ្វើដូច្នេះ ត្រូវត្រឡប់ទៅធ្វើជាសាក្សីវិញ មិនមែនមកធ្វើជាភាគីដេញដោលនៅក្នុងរឿងក្តីទេ។ ព្រោះបានដឹងរឿងហេតុ ដែលវាកើតមានឡើង អ្នកណាដឹង យល់ដឹងផ្ទាល់ ដែលដឹងហេតុការណ៍ដែលកើតឡើងនោះ ត្រូវមកធ្វើជាសាក្សី។

លោកអាចតាំងសំណួរផ្សេងទៀតបាន។ ហើយសំណួរសូមរៀបចំឲ្យបានត្រឹមត្រូវ បើពុំដូច្នោះទេ នឹងមានការជំទាស់ ឬក៏អង្គជំនុំជម្រះសម្រេចមិនឲ្យសាក្សីឆ្លើយតបទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន ខ្ញុំសំណួរខ្ញុំភាគច្រើន ៗតែមិនមាននៅក្នុងកំណត់ហេតុ-- នៅក្នុងសំណួររបស់ចៅក្រមស៊ើបអង្កេត ម្ល៉ោះហើយខ្ញុំមានសំណួរជាងដប់ ប៉ុន្តែឥឡូវបើសិនជាសំណួរខ្ញុំហ្នឹងមិនចូលទៅក្នុងប្រធានដែលខ្ញុំត្រូវសាកសួរ ហើយជារឿងពិតរបស់ប្រវត្តិសាស្ត្រ ពេលនេះគឺខ្ញុំសូមឈប់

សួរត្រឹមហ្នឹង ខ្ញុំជូនទៅ-- ពេលវេលាទៅសហការីរបស់ខ្ញុំ ដើម្បីសួរបន្ត។ សូមអរគុណ។

[១១:២១:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ហ្សាស្ដើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្ដើ ប៉ោ៖**

សួស្ដីលោក សគីម ល្មុត ខ្ញុំរីករាយដែលបានមកជួបនៅទីនេះ។ ខ្ញុំនឹងលើកនូវសំណួរមួយចំនួនទាក់ទងទៅនឹងសក្ខីកម្មដែលលោកបានផ្ដល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ហើយសំណួរទីមួយរបស់ខ្ញុំគឺមានដូចតទៅ៖

**ស៖** គេបានបង្ហាញនូវឯកសារជាច្រើនជូនចំពោះលោក គឺអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្ហាញនូវឯកសារទាំងនោះជូនដល់លោក។ ហើយឯកសារទាំងអស់នេះគឺចាប់ផ្ដើមពីរបបកម្ពុជាប្រជាធិបតេយ្យមក។ ហើយសំណួររបស់ខ្ញុំដែលចង់សួរលោកគឺថា តើឯកសារទាំងនេះជួយដល់លោកក្នុងការយល់ដឹងអំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១១:២៣:០៨]

**លោក សគីម ល្មុត៖**

**ឆ៖** សូមឆ្លើយថា ជួយបានកម្រិតណាទេ មិនអាចដឹងបានល្អិតឲ្យត្រឹមត្រូវទេ។ ដឹងខ្លះ ក៏ដោយប៉ាន់ស្មាន ក៏តាមឯកសារហ្នឹងដែរ។

**ស៖** តើលោកអាចជម្រាបបន្ថែមបានដែរឬទេ ថាតើៗលោកធ្វើការសន្និដ្ឋានបែបណា ដោយផ្អែកទៅលើឯកសារទាំងអស់នោះ? តើលោកអាចជម្រាបបានដែរឬទេ? តើលោកសន្មតបែបណាដោយផ្អែកទៅលើឯកសារទាំងអស់នោះ?

**ឆ៖** ឯកសារទាំងនោះគឺថា មើលទៅតាមខ្លឹមសារខ្លះ ចំណារខ្លះឃើញថា ដឹងថា ក្រសួងណារាយការណ៍ទៅនរណា។ ដឹងតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំនឹងលើកនូវប្រធានបទនេះនៅពេលក្រោយទៀត។ ប៉ុន្តែឥឡូវនេះខ្ញុំគិតថាយើងចាប់ទៅលើចំណុចនេះសិន។ លោកសាក្សី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាតើលោកអាច

ចូលរួមនៅក្នុងកិច្ចប្រជុំដែលនិយាយអំពីការនាំចេញស្រូវ អង្ករបានដែរឬទេ? តើលោកមានដែលចូលរួមក្នុងពិធីប្រជុំបែបនេះដែរឬទេ?

[១១:២៤:៤៩]

**ឆ៖** ខ្ញុំមិនបានចូលរួមសម្រេចពីរឿងដូចថា នាំស្រូវអង្ករនេះទេបាទ។ អានេះជាភារកិច្ចរបស់ខាងក្រសួងពាណិជ្ជកម្ម ឬក៏ជាមួយអ្នកណាទៀត ខ្ញុំមិនដឹងទេ។ តែថាខ្លួនខ្ញុំផ្ទាល់មិនបានចូលរួមទេបាទ។

**ស៖** តើលោកដឹងដែរឬទេ ថាតើបុគ្គលណាដែលចូលរួមនៅក្នុងការសម្រេចក្នុងការនាំស្រូវអង្ករចេញ ឬក៏មិនត្រូវនាំចេញ? តើលោកដឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។

**ស៖** យើងនិយាយអំពីស្រូវអង្ករ។ ប៉ុន្តែក៏វាអាចមានលទ្ធភាព ដែលថាមានការនាំចេញនូវទំនិញ ឬក៏ផលិតផលផ្សេង តើលោកមានដែលចូលរួមក្នុងកិច្ចប្រជុំ ដែលនិយាយអំពីការនាំចេញនូវផលិតផលដទៃទៀតដែរឬទេ?

[១១:២៥:៥០]

**ឆ៖** បាទ មិនដែលទេបាទ។

**ស៖** លោកបាននិយាយពីមុនរួចមកហើយថា លោកអាចសន្មតថា ស្រូវមិនអាចនាំចេញក្នុងបរិមាណច្រើនទេ។ តើលោកអាចពន្យល់បានដែរឬទេ ថាហេតុអ្វីបានលោកសន្មតបែបដូច្នេះ?

**ឆ៖** អានេះ គឺជាការប៉ាន់ប្រមាណជាអត្តនោម័តិរបស់ខ្ញុំទេ ខ្ញុំគ្មានដើងលេខអីទេ ដើងលេខទើបនឹងបានក្រោយថ្មីៗនេះទេ។ ពេលនោះ ខ្ញុំអ៎ គ្មានដើងលេខទេ ប៉ុន្តែដូចថាខ្ញុំនៅ ក្នុងកន្លែងអ៊ីចឹងទៅឃើញថា មើលទៅដូចមិនឃើញថា សកម្មភាពអីធំដុំ ខ្ញុំក៏គិតថា មើលទៅមិនជាច្រើនអីទេ។ ហ្នឹងខ្ញុំ--តែឲ្យមានដើងលេខបញ្ជាក់ ខ្ញុំគ្មានទេបាទ។

**ស៖** ខ្ញុំចង់សួរបន្តបន្តិចទាក់ទងចំណុចនេះ តើលោកយល់ស្របដែរឬទេ ដែលថាលោកធ្វើការសន្មត ហើយវាជាការសន្មតផ្ទាល់ខ្លួនរបស់លោក? ថាតើលោកអាចពន្យល់បន្ថែម ឲ្យបានលម្អិតបន្ថែមដែរឬទេ ថាតើលោកផ្អែកទៅលើមូលដ្ឋានអ្វីដែលលោកធ្វើការសន្មតបែបនេះ? ថាតើការសន្មតផ្ទាល់ខ្លួនការសន្និដ្ឋានផ្ទាល់ខ្លួនរបស់លោកហ្នឹងផ្អែកទៅលើមូលដ្ឋានអ្វីដែរ?

[១១:២៧:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប!

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក បាណាបេ ណោគ្វី៖**

បាទ សូមអរគុណលោកប្រធាន។

ដោយសារតែមេធាវីនេះសួរសំណួរច្រើនពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំមិនធ្វើការជំទាស់នោះទេ ខ្ញុំគ្រាន់តែគាត់ចង់ឲ្យ-- ឲ្យគាត់បញ្ជាក់ថា ពេលណា? ហើយផ្អែកលើមូលដ្ឋានអ្វីដែលគាត់សួរបែបហ្នឹង? ហើយថាតើពេលណាដែរ ដែលសាក្សីហ្នឹងគាត់បាននិយាយថា ស្រូវមិនបាននាំចេញច្រើននោះ? គាត់បាននិយាយអំពីការសន្មតរបស់សាក្សី តែមិនដឹងថានៅពេលណាច្បាស់នោះទេ។

[១១:២៨:៣៣]

**ប្រធានអង្គជំនុំ៖**

មានអីត្រូវឆ្លើយតបនឹងការកត់សម្គាល់នេះទេ លោកមេធាវី?

**លោក ហ្សាស្តើ ប៉ៅ៖**

លោកប្រធាន ខ្ញុំអាចផ្តល់នូវចំណុចទាំងអស់នេះ ប៉ុន្តែខ្ញុំគិតថា យើងដឹងថាយើងទៅដល់ចំណុចណាមួយ។ ដូច្នេះនៅពេលដែលយើងដកស្រង់ នូវអ្វីដែលសាក្សីបាននិយាយឡើង ខ្ញុំត្រូវដកស្រង់នូវចំណុចទាំងអស់នោះ។ ហើយខ្ញុំគិតថា ឯកសារទាំងអស់នេះប្រហែលជាមានសម្រាប់ភាគីទាំងអស់ ហើយសាក្សីអាចនឹង-- ហើយយើងអាចនឹងផ្តល់នូវឯកសារទាំងអស់នេះ។ ហើយប៉ុន្តែដោយសារតែយើងចង់ឲ្យដំណើរការនេះមានដំណើរឆាប់រហ័ស ដូច្នេះទើបខ្ញុំមិនអាចផ្តល់ឲ្យឯកសារទាំងអស់បានដើម្បីឲ្យដំណើរការបានទៅឆាប់រហ័ស។ ប្រសិនបើយើងធ្វើដូចដែលខ្ញុំធ្វើនេះ គឺការចោទសួរហ្នឹង វានឹងមានប្រសិទ្ធភាពប្រសើរជាងមុនតទៅទៀត។

[១១:២៩:៣៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣១:៣០]

**ប្រធានអង្គជំនុំ៖**

បាទសេចក្តីជំទាស់របស់លោកមេធាវីទទួលសិទ្ធិ នៃមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លើការតាំងសំណួរចុងក្រោយរបស់មេធាវីជាតិ-- អ៉ំ មេធាវីអន្តរជាតិការពារក្តីលោក នួន ជា ត្រឹមត្រូវ។ ដូច្នេះ សូមមេធាវីអន្តរជាតិការពារក្តីលោក នួន ជា តាំងសំណួរដែលមានការពាក់ព័ន្ធទៅនឹងឯកសារដែលទាក់ទិនទៅនឹងព្រឹត្តិការណ៍ ឬក៏សំណួរដែលសួរត្រូវបង្ហាញនូវឯកសារ ដែលពាក់ព័ន្ធហើយនិងពាក្យពេចន៍ ដែលគាត់បាននិយាយពេលមុននៅក្នុងប្រតិចារឹក ដើម្បីផ្ទុះបញ្ចាំងអំពីអ្វីដែលគាត់បានឆ្លើយទៅនឹងតបទៅនឹងសំណួរ ដែលពាក់ព័ន្ធនឹងឯកសារនីមួយៗហ្នឹង ឲ្យបានជាក់ច្បាស់ ដើម្បីងាយសាក្សីឆ្លើយតប ហើយនិងបានទទួលលទ្ធផលត្រឹមត្រូវផង នូវលទ្ធផលនៃការពិភាក្សាដេញដោលនេះ។

**លោក ហ្វាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ សេចក្តីយោងនោះគឺ មាននៅក្នុងឯកសារ D279/7 គឺជាចម្លើយទៅនឹងសំណួរ៦៣ នៅក្នុង ERN អង់គ្លេស 00425229។ អ្នកកាន់សំណុំរឿងរបស់ខ្ញុំ អាចនឹងសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ជាភាសាខ្មែរ ហើយសូមអនុញ្ញាតដើម្បីបង្ហាញឯកសារលើក្រដាសទៅសាក្សីផងដែរ។ បើសិនជាតុលាការត្រូវការបែបនោះ ហើយខ្ញុំនឹងបន្តសំណួរ ហើយខ្ញុំជឿជាក់ថា លោកសាក្សីប្រហែលជាមានឯកសារ ជាកំណត់ហេតុនេះរួចហើយ។ បាទ ដូច្នេះប្រហែលជាមិនចាំបាច់ ជូនឯកសារលើក្រដាសទៅគាត់ទៀតទេ។ ដូច្នេះដើម្បីឲ្យសាក្សីជ្រាបគឺថា សំណួរ និងចម្លើយនៅសំណួរ៦៣ បាទ។

លោកប្រធាន សូមយើងខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់បាទ។

[១១:៣៤:០២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ឲ្យបុគ្គលិកជំនួយការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍។ មន្ត្រីរដ្ឋបាលតុលាការទៅចង្អុលបង្ហាញចំណុចលើឯកសារអម្បាញ់មិញនេះ ដែល-- ដល់សាក្សីដើម្បីបានឆាប់រហ័សក្នុងការពិនិត្យ និងឆ្លើយតប។

[១១:៣៦:០៣]

**លោក សគឹម ល្អុត៖**

**ឆ៖** ក្នុងៗសំណួរ៦៣ នេះថា៖ "តើលោកអាចប្រាប់យើងពីចំនួនស្រូវដែលនាំចេញកាលពីពេល

នោះ ថាមានចំនួនបានប៉ុន្មានដែរឬទេ?” ខ្ញុំឆ្លើយថា៖ “ខ្ញុំមិនអាចស្មានៗបានទេ ពីព្រោះធ្វើជាស្ថិអ្វីនោះទេ។ ម្យ៉ាងទៀត ៣០ឆ្នាំទៅហើយ យើងមិនបានកត់ត្រា ដូច្នេះខ្ញុំមិនចងចាំនៅក្នុងក្បាល-- ខួរក្បាលទេ។ ប៉ុន្តែបើតាមខ្ញុំប៉ាន់ស្មាន គឺមិនជាច្រើនប៉ុន្មាននោះទេ”។ ខ្ញុំឆ្លើយអ៊ីចឹងបាទ។ ហើយឯកសារស្ថិតិនេះ គឺខ្ញុំទើបនឹងបានឃើញពីម្សិលមិញ ដែលក្រសួងពាណិជ្ជកម្ម គេសរសេររបស់គេ ពេលនោះ ខ្ញុំមិនដែលឃើញទេ។ ហើយដែលការខ្ញុំប៉ាន់ស្មានជាអត្តនោម័តិរបស់ខ្ញុំ ខ្ញុំគិតទៅ មើលទៅថា ដូចជាមិនច្រើនប៉ុន្មានទេ ហើយថាឲ្យខ្ញុំបញ្ជាក់ម៉េចទៀតនោះ គឺខ្ញុំមិនអាចលម្អិតម៉េចទេ។ អាហ្នឹងតាមខ្ញុំ-- អត្តនោម័តិខ្ញុំ តាមមើលដូចមិនច្រើនប៉ុន្មានទេ។ តែថាជើងលេខខ្ញុំគ្មានទេ បើសិនជាបានជើងលេខនេះមកមើលមុននឹងគឺអាចខ្ញុំប៉ាន់ប្រមានឲ្យវាច្បាស់លាស់ជាងហ្នឹងបាទ។ ដូច្នេះឲ្យខ្ញុំលម្អិតទៀត ខ្ញុំមិនអាចលម្អិតបានទៀតទេបាទ។

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** សូមអរគុណលោកសាក្សីនេះ គឺថាស្រដៀងទៅនឹងអ្វីដែលលោកបានឆ្លើយពីខាងដើម គឺថាលោកមិនមានលទ្ធភាពមើលស្ថិតិនោះទេ។ ហើយខ្ញុំយល់ថា លោកបានឃើញស្ថិតិ ឯកសារផ្សេងៗទៀតនោះ គឺនៅពេលតែម្សិលមិញតែប៉ុណ្ណោះ។ ក៏ប៉ុន្តែខ្ញុំចាប់អារម្មណ៍ក្នុងការស្តាប់សម្តីរបស់លោកថាតើការសន្និដ្ឋានរបស់លោកហ្នឹង គឺផ្អែកលើអ្វី? លោកធ្វើការនៅក្នុងអង្គការនេះ លោកបានពាក់ព័ន្ធជាមួយការនាំចេញ នាំចូល។ ប្រហែលជាអាចថា នៅក្នុងកម្រិតមួយដែលលោកអាចជួបនឹងបញ្ហាទាំងអស់នេះ។ តើលោកអាចជម្រាបខ្ញុំ និងតុលាការបានទេ? ថាតើសេចក្តីសន្និដ្ឋាន ឬការសន្និដ្ឋានរបស់លោកដែលទាក់ទងទៅនឹងការនាំចេញស្រូវហ្នឹង គឺមិនច្រើនប៉ុន្មានទេនោះបាទ?

[១១:៣៨:៣០]

**ឆ៖** អាហ្នឹង ខ្ញុំដូចប្រកាន់ជំហរឆ្លើយអ៊ីចឹង គឺថាខ្ញុំប៉ាន់ស្មានពេលនុ៎ង ដូចថាវាមិនច្រើនទេ។ ហើយថា ឲ្យខ្ញុំបញ្ជាក់ពីមូលហេតុលម្អិតយ៉ាងម៉េចៗថែមទៀត ខ្ញុំមិនមានមូលហេតុអីនឹងជម្រាបជូនថែមទៀតទេបាទ។ អាចថា ខ្ញុំនិយាយខុសទៅក៏-- តែក្នុងពេលៗ ខ្ញុំគិតទៅដូចជាមិនច្រើន។ ខ្ញុំគិតអ៊ីចឹងពេលនុ៎ង វាជាការគិតរបស់ខ្ញុំ។ តែដល់ជើងលេខដែលជាក់ស្តែងនេះ ខ្ញុំមិនបានច្បាស់ តែមើលទៅថាអាការគិតរបស់ខ្ញុំហ្នឹង ថាមិនច្រើន តែជើងលេខនេះច្រើន ឬមិនច្រើន ខ្ញុំក៏មិនបានមើលច្បាស់ដែរពីម្សិលមិញហ្នឹង។ ស្រេចហ្នឹងអង្គតុលាការវិនិច្ឆ័យចុះបាទ។

[១១:៣៩:៣៤]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមិនព្យាយាមតទល់ជាមួយលោកនឹងបញ្ហានេះទេ ខ្ញុំគ្រាន់តែចង់ដឹងថា តើប្រភពនៃការយល់ដឹងរបស់លោកទាក់ទងទៅនឹងការនាំស្រូវចេញតែប៉ុណ្ណឹងទេ។ ឥឡូវនេះខ្ញុំនឹងទៅមុខទៀតដែលថា លោកបញ្ជាក់ថាជាការសន្និដ្ឋានផ្ទាល់ខ្លួននោះទេ។ សំណួរបន្ទាប់របស់ខ្ញុំចំពោះលោកហ្នឹង គឺទាក់ទងទៅនឹងចម្លើយ៦២ នៅក្នុងឯកសារដដែលនេះ ដែលក្នុងនោះលោក គេសួរលោកថាសហ-- អ្នកស៊ើបអង្កេតសួរថា៖ “តើចំពោះការនាំចេញម្ហូបអាហារដូចម្ដេចដែរ?” លោកឆ្លើយថា “បើតាម ខ្ញុំចាំគឺមានស្រូវ អង្ករ កៅស៊ូ សំឡីគ និងរបស់កសិកម្មផ្សេងៗទៀតដូចជា សណ្ដែក សណ្ដែកសៀងជាដើម គឺមិនមានច្រើនប៉ុន្មានទេ។ ហើយខ្ញុំក៏មិនបានដឹងពីសេចក្ដីលម្អិតនោះដែរ។” នេះជាចម្លើយរបស់លោក។ ខ្ញុំទុកពេលមួយនាទីជូនលោក ដើម្បីលោករកឃើញចម្លើយរបស់លោកទៅនឹងសំណួរ៦២ នៅខាងលើចំណុចដែលយើងពិភាក្សាអម្បាញ់មិញនេះ។ សំណួររបស់ខ្ញុំជូនលោកនោះថា តើលោកដឹងដូចម្ដេចបាន? តើលោកបានឈានទៅដល់សេចក្ដីសន្និដ្ឋាន សន្និដ្ឋាននោះថា មិនមានការនាំចេញផលិតផលកសិកម្មច្រើនហ្នឹង គឺលោកផ្អែកលើកត្តាអ្វីខ្លះដែលលោកសន្និដ្ឋានបែបនេះ?

[១១:៤១:២៦]

**ឆ៖** អាហ្នឹង គឺហេតុផលដូចទៅនឹងចម្លើយលើកមុនអ៊ីចឹង គឺថា ខ្ញុំៗគិតមើលទៅដូចជាមិនច្រើនទេ។ ហ្នឹងខ្ញុំសន្និដ្ឋាននៅពេលនុ៎ង ហើយក៏មិនដែលបានឃើញស្ថិតិអីក៏អត់ដែរទេ។ ហើយដែលថាឲ្យខ្ញុំលម្អិតថាហេតុអីបានជាខ្ញុំសន្និដ្ឋានអ៊ីចឹង? បាទ គឺថាពេលនុ៎ងក៏គិតទៅថា គិតថាទូទៅគឺថាដូចសេដ្ឋកិច្ច ដូចកសិកម្ម មិនៗឮគេនិយាយថា យ៉ាងម៉េចៗច្បាស់ទេ តែខ្ញុំដូចជាសន្និដ្ឋានដូចជាមិនច្រើន។ ហើយឲ្យសួរខ្ញុំថា មូលហេតុអីលម្អិត? ខ្ញុំមិនអាចលម្អិតអីទេបាទ អាហ្នឹងអត្តនោម័តិខ្ញុំថាអ៊ីចឹងត្រង់ថាវាខុស វាត្រូវ អាហ្នឹងយកទៅប្រៀបធៀបយកទៅនឹងនែ អាហ្នឹងស្ថិតិ អាឌែងពាណិជ្ជកម្មគេធ្វើមកនេះ តើវាអ៊ីចឹងទេ ច្រើនឬតិច? ដូចខ្ញុំប៉ាន់ស្មានការប៉ាន់ស្មានរបស់ខ្ញុំទេ? ពីព្រោះថាការធ្វើការដូចថា ខ្ញុំអាចយល់ដឹងពីរឿង--

**ស៖** លោកសាក្សីខ្ញុំគិតថាចម្លើយរបស់លោកច្បាស់ហើយ។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត ដែលទាក់ទងទៅនឹងបញ្ហានេះដែរ។ ខ្ញុំចង់ដឹង ហើយនិងខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនលោក។ D279/7.4 ឯកសារនោះគឺថា ឯកសារដដែល គឺ E3/829 អង់គ្លេស ERN ជាភាសាអង់គ្លេស 00002714 ខ្មែរ ERN នោះគឺ 00002711។

[១១:៤៣:៣៧]

**លោក ហ្សាស្តើ ប៉ោះ**

សូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញជូនឯកសារនេះទៅសាក្សី ហើយនិងបង្ហាញនៅលើអេក្រង់ផងដែរ។ ហើយឯកសារហ្នឹងហៅថា "របាយការណ៍នៃការចរចារវាងគណៈប្រតិភូពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ ហើយនិងគណៈប្រតិភូពាណិជ្ជកម្មចិន ថ្ងៃទី០៣ ធ្នូ ឆ្នាំ១៩៧៨។" ហើយ ពីម្សិលមិញនោះក៏បានបង្ហាញឯកសារនេះនៅលើអេក្រង់ និងសាក្សី និងតុលាការផងដែរ។

**សួរដោយលោក ហ្សាស្តើ ប៉ោះ**

**ស៖** លោកសាក្សី តើលោកមានឯកសារនេះនៅក្នុងដៃទេ ឬក៏លោកត្រូវការឲ្យខ្ញុំជូនទៅលោកមួយច្បាប់នៅពេលនេះ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! បុគ្គលិកជំនួយការអាចបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ ហើយនិងផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនេះនៅលើអេក្រង់ទូរទស្សន៍។ ហើយមន្ត្រីរដ្ឋបាលតុលាការពិនិត្យឯកសារ ហើយនិងចង្អុលបង្ហាញឲ្យចំទំព័រ លេខ ERN នៃឯកសារនេះដល់សាក្សី ពីព្រោះឯកសារនេះបានបង្ហាញរួចហើយកាលពីម្សិលមិញ។

[១១:៤៥:៤៦]

**លោក ហ្សាស្តើ ប៉ោះ**

ឯកសារនេះមានហើយលោកប្រធាន។ ដូច្នេះ គឺថាអាច យើងខ្ញុំសូមអនុញ្ញាតជូនឯកសារលើក្រដាសដើម្បីសាក្សីបានពិនិត្យមើល អាចនឹងងាយស្រួលជាងបាទ។

**សួរដោយលោក ហ្សាស្តើ ប៉ោះ**

**ស៖** សំណួរទីមួយដែលខ្ញុំចង់សួរនោះ គឺនៅទំព័រទី២ នៅខាងផ្នែកខាងលើនៃទំព័រនោះ ដែលគូសជាពណ៌ខៀវបាទ។

**លោក សតីម ល្អុត៖**

**ឆ៖** បាទ ខ្ញុំបានអានហើយបាទ។

**ស៖** សូមអរគុណ ដើម្បីឲ្យសាធារណជនច្បាស់ ហើយខ្ញុំនឹងអានជាភាសាអង់គ្លេស ផ្នែកនេះគឺនិយាយថា ដកស្រង់៖ "នៅក្នុងស្ថានភាពសង្គ្រាមយ៉ាងធ្ងន់ដូច្នេះ ហើយថែមទាំងទទួលរងគ្រោះពីទឹកជំនន់ជាពីរលើកទៀតក្នុងឆ្នាំនេះ ហើយដែលមានទំហំធំ មិនធ្លាប់មានជាង៧០ឆ្នាំមកហើយ។ ព្រឹត្តិ-

ការណ៍នេះ វាប៉ះពាល់ដល់កសិកម្មយើងជាច្រើន។ ហេតុដូច្នេះ យើងបានគម្រោងនាំចេញក្នុងឆ្នាំនេះ មិនបានអនុវត្តតាមផែនការទេ”។ ហើយសំណួររបស់ខ្ញុំថាតើមានទឹកជំនន់ធ្ងន់ធ្ងរខ្លាំងក្លាដែរឬទេ នៅក្នុងឆ្នាំ១៩៧៨នោះ?

**ផ៖** បាទ ខ្ញុំមិនចាំទេបាទ។

[១១:៤៨:១៩]

**ស៖** បាទ ដូច្នេះខ្ញុំនឹងប្តូរទៅប្រធានបទមួយផ្សេងទៀត ដែលទាក់ទងទៅនឹងឯកសារ IS21.130។ ឯកសារនេះរបស់ក្រសួងពាណិជ្ជកម្ម ភាសាអង់គ្លេស ERN 00664494, ខ្មែរ ERN គឺ00072699, បារាំង ERN 00643583។

**លោក ហ្សាស្តេ ប៉ោះ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីផ្តល់ឯកសារនេះ ជូនទៅសាក្សី ជាឯកសារលើក្រដាស ហើយនិងសុំអនុញ្ញាតដើម្បីបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបឋម សាក្សីទទួលឯកសារនេះពីមេធាវីការពារក្តី យកជូនសាក្សីពិនិត្យជាមុនសិន។

[១១:៥០:០០]

**លោក ហ្សាស្តេ ប៉ោះ**

ខ្ញុំចង់ជម្រាបលោកប្រធាន និងសាក្សីថា មុននឹងខ្ញុំប្រើឯកសារនេះ ខ្ញុំមិនដឹងថាតើឯកសារនេះ បានដាក់នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាដែរឬទេ? ជាពិសេស នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជាពិសេសក្នុងផ្នែកនៃសវនាការនេះ។ ខ្ញុំសូមជម្រាបថា ឯកសារនេះ គឺប្រើនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញាបានពឹងផ្អែកលើឯកសារនេះ ទាក់ទងលើបញ្ហាថា វាពាក់ព័ន្ធទៅនឹងការយល់ដឹងរបស់សាក្សីនេះ ចំពោះប្រធាននេះ គឺចំណុចដែលនិយាយពីបញ្ហាមួយចំនួន។ ដូច្នេះ អាចនឹងអនុញ្ញាតឲ្យខ្ញុំផ្សារភ្ជាប់ទៅនឹងប្រធានបទដែលខ្ញុំបានសួរខាងដើម នៅថ្ងៃនេះ ទាក់ទងទៅនឹងឯកសារជាក់ស្តែង។ បាទ ឯកសារទាំងនេះ គឺនៅក្នុងសំណុំរឿង ហើយមានបកប្រែទៅជាភាសាទាំងបីរបស់តុលាការ។ ភាគីទាំងអស់មានលទ្ធភាពបើកបាន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើបញ្ហានេះ មុននឹងខ្ញុំបន្តបាទ។

[១១:៥១:១៣]

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមជម្រាបបន្ថែមដោយសង្ខេប នៅក្នុងប្រព័ន្ធ *ដេតាបេស* គឺថាមិនមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញានោះទេ ប៉ុន្តែគឺស្ថិតនៅក្នុងប្រព័ន្ធដាតាបេសរបស់តុលាការ មានឯកសារនេះបាទ។

[១១:៥១:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥២:១៦]

**ប្រធានអង្គជំនុំ៖**

លោក សគឹម ល្មុត លោកធ្លាប់បានឃើញឯកសារនេះ ពីមុនមកដែរទេ?

**លោក សគឹម ល្មុត៖**

បាទ លោកប្រធាន ខ្ញុំមិនដែលឃើញទេបាទ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីដកឯកសារនេះ ចេញពីសាក្សី។ ហើយនិងឲ្យដក-- បុគ្គលិកជំនួយការដកឯកសារនេះ ចេញពីអេក្រង់កុំព្យូទ័រ។

អង្គជំនុំជម្រះសូមរំឭកលោកមេធាវីការពារក្តីថា លោកមេធាវីគប្បីត្រូវបានបង្ហាញជាមុននូវឯកសារដែលលោកមានការ-- មានបំណងដាក់ដេញដោលចំពោះសាក្សីណាមួយ គឺត្រូវបង្ហាញជាមុននូវឯកសារនោះ នៅក្នុងបញ្ជីឯកសារដែលបានស្នើសុំដាក់ដេញដោល នៅចំពោះមុខអង្គជំនុំជម្រះ។ មិនគប្បីលើកមកដាក់រួចហើយ ហើយទើបមកបង្ហាញថា ខ្លួនមិនច្បាស់លាស់ដូច្នេះទេ។

សូមលោកបន្តទៅសំណួរដទៃទៀត!

[១១:៥៣:៣៩]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំយល់ច្បាស់ហើយ។ ខ្ញុំបានចង្អុលបង្ហាញឯកសារនេះ គឺជាឯកសារដែលយើងនឹងប្រើនៅក្នុងការតាំងសំណួរសាក្សីរូបនេះ យើងខ្ញុំបានបញ្ជាក់បែបនោះ។ ហើយខ្ញុំក៏សូមជម្រាបតុលាការជាទូទៅផងដែរ ខ្ញុំឃើញថា សហព្រះរាជអាជ្ញានឹងគាំទ្រខ្ញុំនៅក្នុងសំណើរបស់ខ្ញុំនៅក្នុងកម្រិតមួយ ដែលថានេះជាឯកសារដែលមានការពាក់ព័ន្ធ វាទាក់ទងទៅនឹងការនាំចេញស្រូវ អង្ករ ហើយសាក្សីរូបនេះ គឺធ្វើការកៀកទៅនឹងការងារហ្នឹង គឺថានេះជាវិធីងាយ ដើម្បីឲ្យគាត់អាចបំភ្លឺដល់

តុលាការអំពីឯកសារទាំងនេះបាន។ ជាពិសេស ពីព្រោះថាវាទាក់ទងទៅនឹងបញ្ហាហិរញ្ញវត្ថុនៅក្នុងការបានចំណូលពីការនាំចេញស្រូវ ជាពិសេស បញ្ជូនទៅម៉ាដាហ្គាស្កា ជាដើម។ សាក្សីគាត់អាចដឹងពីបញ្ហានេះ បើសិនជាតុលាការអនុញ្ញាតឲ្យគាត់ផ្ដល់យោបល់ ហើយគាត់បង្ហាញនៅសហចៅក្រមស៊ើបអង្កេតនោះ គឺថាបើបានបង្ហាញ គឺមិនមានគោលការណ៍ជាមូលដ្ឋានអ្វី ដែលថាមិនអនុញ្ញាតឲ្យគាត់ផ្ដល់មតិយោបល់នៅពេលនេះនោះទេ។

[១១:៥៤:៥៧]

ដូច្នេះហើយការសួរសាក្សីរូបនេះ គឺទាក់ទងទៅនឹងព័ត៌មានពាក់ព័ន្ធ យើងព្យាយាមចង់បានព័ត៌មានពីសាក្សីរូបនេះ។ បាទ ហើយបើមិនអនុញ្ញាតឲ្យខ្ញុំបាទសួរទេ គឺអាចនឹងកម្រិតពីលទ្ធភាពការតាំងសំណួរឲ្យបានបំភ្លឺ ហើយ សំណួររបស់ខ្ញុំនឹងសួរថ្ងៃនេះ គឺផ្សារភ្ជាប់ទៅនឹងបញ្ហាប្រហាក់ប្រហែលនេះ ហើយសំណួរចំពោះខ្ញុំទាក់ទងនឹងឯកសារនេះគឺ-- បើសិនជាតុលាការមិនអនុញ្ញាតទេ ខ្ញុំមិនអាចនឹងតាំងសំណួរក្នុងប្រធានបទនេះ ឲ្យមានប្រសិទ្ធភាពដោយជាក់ស្ដែងបានទេ។ បើមិនដូច្នេះ ខ្ញុំសូមអនុញ្ញាតបញ្ឈប់ត្រឹមនេះបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ែខល កាណាវាស!

[១១:៥៥:៤៦]

**លោក ម៉ែខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយភាគីទាំងអស់ ហើយនិងសាធារណជនទាំងអស់។ តាមអ្វីដែលខ្ញុំយល់ អង្គជំនុំជម្រះសាលាដំបូងគឺចេញសេចក្ដីសម្រេចលើបញ្ហានេះ ប្រសិន-- ហើយសាក្សីមិនដឹងថាសាក្សីនេះ-- ឯកសារនេះជាអ្វីទេ អ៊ីចឹងគាត់មិននិយាយទេ ប៉ុន្តែមិនអាចជាការរារាំងមិនឲ្យភាគីសួរសំណួរទាក់ទងទៅនឹងខ្លឹមសារនៅក្នុងឯកសារនេះនោះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណៗច្រើន។ យើងមិនហាមឃាត់ទេ ឲ្យគាត់តាំងសំណួរ គ្រាន់តែឲ្យដកឯកសារចេញពីសាក្សី និងពីកុំព្យូទ័រចំពោះខ្លឹមសារនៃ-- នៅក្នុងឯកសារប្រសិនបើខ្លួនមានបំណងសួរ អាចតាំងសំណួរចំពោះសាក្សីបាន។ ប៉ុន្តែមេធាវីរូបនេះ គាត់មិនបានប្រើសិទ្ធិនោះទេ គាត់បែរយកពេលវេលាធ្វើអត្ថាធិប្បាយយ៉ាងវែងអន្លាយ នីតិវិធីនេះអង្គជំនុំជម្រះបានអនុវត្តច្រើនលើកច្រើនសាមកហើយ ហើយអង្គ

ជំនុំជម្រះនៅតែរក្សានូវសេចក្តីសម្រេចរបស់ខ្លួនដដែល។ អង្គជំនុំជម្រះ មិនហាមថាគាត់ មិនឲ្យគាត់សួរទេ ឲ្យបន្តការតាំងសំណួរ ប៉ុន្តែឲ្យដកឯកសារ អ្វីដែលបានយើងបានសម្រេចរួចហើយ ទាំងសាក្សី ចេញពីសាក្សី ទាំងនៅលើកញ្ចក់ នៅលើអេក្រង់ទូរទស្សន៍ ឬកុំព្យូទ័រ។

[១១:៥៧:១៩]

**លោក ហ្សាស្តេី ប៉ៅ៖**

លោកប្រធាន ខ្ញុំបានច្បាស់ហើយពីបញ្ហានេះ។ គឺមាន១-- មានកម្រិតបញ្ហាលើខ្ញុំ ប្រសិនបើយើងមិនអាចប្រើឯកសារបាន គឺថាវាខ្លឹមសារដើម្បីយើងប្រើឯកសារនេះ ដូច្នេះហើយជាមូលហេតុដែលតុលាការចេញសេចក្តីសម្រេច ថាបង្គាប់ឲ្យខ្ញុំដាក់ឯកសារនៅលើអេក្រង់ដើម្បីឲ្យភាគីទាំងអស់បានឃើញដើម្បីបញ្ជាក់។ នេះហើយ បើខ្ញុំមិនអាចប្រើឯកសារនេះទេ វាជាការកម្រិតដល់យើងខ្ញុំ ហើយខ្ញុំមិនទាន់បានស្តាប់សំអាងហេតុជាមូលដ្ឋាន គាំទ្របញ្ហាថាមិនឲ្យតាំងឯកសារនៅលើអេក្រង់បង្ហាញសាក្សី ហើយឲ្យយើងខ្ញុំសួរយកតែខ្លឹមសារហ្នឹងឲ្យពិស្តារ ខ្ញុំមិនទាន់បាននៅឡើយបាទ។

**ប្រធានអង្គជំនុំ៖**

លោកទៅមើលឯកសារលើកមុន អង្គជំនុំជម្រះបានសម្រេចតាំងពីលើកមុន នៅលើប្រតិចារឹកដែលអង្គជំនុំជម្រះសម្រេចរួចហើយ។ លោកស្រាវជ្រាវរកមើលរឿងដដែលនេះ ដោយមានប្រតិចារឹកគ្រប់គ្រាន់ហើយ ក្រែងលោលោកមានការផ្លាស់ ផ្លាស់ប្តូរគ្នានៅក្នុងកិច្ចដំណើរការទើបលោកក្តាប់បញ្ហានេះមិនបាននោះ។

លោកអស់សំណួរហើយមែនទេ?

បាទ ឥឡូវហ្នឹងដោយសារពេលវេលាសមល្មមនឹង--

សូមអញ្ជើញ! លោកមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា ចង់និយាយអីទៅ?

**លោក ហ្សាស្តេី ប៉ៅ៖**

លោកប្រធាន ខ្ញុំបានអង្គុយ គឺថា ខ្ញុំជម្រាបថា បើខ្ញុំមិនអាចប្រើឯកសារជាមូលដ្ឋានសម្រាប់សួរសំណួរទេ ខ្ញុំមិនអាចសួរបានទេ គ្រាន់ជម្រាបប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

[១១:៥៩:២៣]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្តីសហភាគា ព្រះរាជអាជ្ញា លោកអ្នកទាំងឡាយនៅក្នុងអង្គប្រជុំ នៅក្នុងសវនាការនេះ និងក្រៅបន្ទប់សវនាការ។ ខ្ញុំគ្រាន់តែលើកមកបញ្ជាក់ថា សួស្តីផងដែរលោក សគឹម ល្អុត ខ្ញុំ អាង ឧត្តម ជាសហមេធាវីជាតិការពារក្តីឲ្យលោក អៀង សារី សូមបញ្ជាក់ថា ដើម្បីជួយសង្គ្រោះ និងសន្សំពេលវេលារបស់តុលាការ សុំបញ្ជាក់ពីជំហរក្រុមមេធាវីយើងថា យើងខ្ញុំគ្មានសំណួរចំពោះលោកទេ ហើយយ៉ាងណាក្តី តាងនាមលោក អៀង សារី ខ្ញុំនិងសហភាគារបស់ខ្ញុំគឺលោក មៃខល កាណាវាស សូមថ្លែងអំណរគុណចំពោះលោក ដែលបានមកឆ្លើយផ្តល់សក្ខីកម្មដល់តុលាការក្នុងការស្វែងរកការពិត និងយុត្តិធម៌។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដល់ក្រុមមេធាវីការពារក្តីលោក អៀង សារី ដែលបានបង្ហាញជំហរច្បាស់លាស់ក្នុងការមិនតាំងសំណួរចំពោះសាក្សី ហើយផ្តល់ព័ត៌មានឲ្យយើងទាន់ពេលវេលា នាំឲ្យអង្គជំនុំជម្រះងាយស្រួលក្នុងការសម្រេច និងជំរុញកិច្ចដំណើរការសវនាការពិភាក្សាដេញដោលបានឆាប់រហ័ស។

[១២:០០:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០២:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ដែលមានបំណងចង់សួរ តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយសួរទៅកាន់សាក្សីរូបនេះ ដើម្បីបំភ្លឺចំណុចមួយដែលត្រូវបានពិភាក្សាយ៉ាងវែងរួចមកហើយ គឺការកំណត់អត្តសញ្ញាណឈ្មោះ ហែម។

**ស៖** លោកសាក្សី គេបានសួរសំណួរលោកជាច្រើនពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ ហែម ដែលមាននៅក្នុងកំណត់ហេតុជាច្រើន។ ហើយលោកបានឆ្លើយថា លោកបានកំណត់ឈ្មោះ ហែម នេះគឺថាមិនដឹងពេលនោះទេ គឺថាលោកដឹងនៅពេលដែលក្រោយដែលគេបង្ហាញលោក-- ឯកសារលោក។ បើតាមលោកដឹងនោះ តើអាចមានឈ្មោះអ្នកណាផ្សេងទៀត ដែលអាចត្រូវបានហៅថា ហែម

ដែរទេ គឺក្រៅពី ខៀវ សំផន នោះ? ព្រោះលោកបាននិយាយថា លោកផ្អែកការវិភាគរបស់លោកទៅលើការកត់សម្គាល់ជាលក្ខណៈសន្និដ្ឋាន។ ប៉ុន្តែបើតាមរបាយការណ៍នោះ គឺថាវាមានឈ្មោះ ហែម ដែលជាលក្ខណៈជាសត្យានុម័តិនោះ។ បើតាមលោកដឹង តើមានមូលហេតុ ដែលថានាំឱ្យយើងសង្ស័យចំពោះអត្តសញ្ញាណរបស់ ហែម ដែលជា ខៀវ សំផន នេះដែរឬទេ?

[១២:០៤:៥៩]

**លោក អាកទូរ វែកគែន៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ចាំចៅក្រមសួរចប់សិន លោកអាចធ្វើសេចក្តីសន្និដ្ឋានចុងក្រោយណ៎ា មិនមែនមកជំទាស់ចៅក្រមសួរយ៉ាងម៉េចទៅ? អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យធ្វើដូច្នេះទេ។

**លោក សតឹម ល្អិត៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន ចំពោះបញ្ហាឈ្មោះ ហែម, ខៀវ សំផន នេះជាបញ្ហាស្មុគស្មាញមួយ។ ម្យ៉ាង ដំបូងខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនដឹងថាមានអ្នកណាទៀតឈ្មោះ ហែម ដែរនោះទេ ខ្ញុំក៏មិនដឹងដែរ។ តែក្នុងឯកសារផ្សេងៗក៏ឃើញថា ទំនាក់ទំនងពីពាណិជ្ជទៅ គឺថាច្រើនទៅដល់បងហែមៗ។ ហើយឈ្មោះ ហែម, ខៀវ សំផន នេះ ខ្ញុំក៏ខ្ញុំគ្មានឯកសារថា ហែម, ខៀវ សំផន ដែលថាពាក្យហ្នឹងគេនិយាយទូទៅ ហើយមកដល់ក្រោយមកសម័យក្រោយមកក៏គេថាអ៊ីចឹង។ ដូចថាៗវាជារឿងមួយគ្មាននរណាប្រកែកទៅហើយ។ ហើយដល់ទៅខ្ញុំភស្តុតាងថា ភស្តុតាងស្អីដែលថា ខៀវ សំផន ហ្នឹង ហែម។ អាហ្នឹងក៏ខ្ញុំជម្រាបត្រង់ ខ្ញុំពិបាកនឹងថាដែរ ប៉ុន្តែថាទូទៅគេថាអ៊ីចឹង គេយល់ថាអ៊ីចឹង។ ហើយថាតើមានអ្នកណាម្នាក់ទៀតឈ្មោះ ហែម ក្រៅពីលោក ខៀវ សំផន ខ្ញុំក៏មិនដឹងដែរទេបាទ។ ខ្ញុំសូម-- បើចម្លើយមិនគ្រប់គ្រាន់ សូមអធ្យាស្រ័យបាទ។

[១២:០៧:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី។ សាជាថ្មីម្តងទៀត គឺលោកបានចំណាយពេលវេលាដ៏មានតម្លៃ ហើយបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាព និងសមត្ថភាពដែលមាន ផ្តល់អារម្មណ៍ឆ្លើយតបទៅនឹងសំណួរក្នុងរយៈពេលប៉ុន្មានថ្ងៃមកនេះ។ ហើយឥឡូវនេះកិច្ចដំណើរការស្តាប់សក្ខីកម្មរបស់សាក្សី ពាក់ព័ន្ធនឹង

សំណុំរឿងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ ឃើញថាដល់ទីបញ្ចប់ហើយ។

ដូច្នេះសាក្សីអាចវិលត្រឡប់ទៅលំនៅដ្ឋានវិញ ឬក៏ទៅគោលដៅណាដែលលោកចង់ទៅវិញបានហើយ។ អង្គជំនុំជម្រះលែងត្រូវការស្តាប់សក្ខីកម្មរបស់លោកសាក្សីទៀតហើយ។ ហើយសូមលោកធ្វើដំណើរប្រកបដោយសុវត្ថិភាព។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការបញ្ជូនសាក្សី សគឹម ល្មុត វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ។

[១២:០៨:២២]

ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា កិច្ចដំណើរការសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មរបស់សាក្សីមួយរូបទៀត គឺសាក្សីដែលមានរហស្សនាម TCW-604 ដែលនឹងតាំងសំណួរចាប់ផ្តើមដោយតំណាងសហព្រះរាជអាជ្ញា បន្ទាប់ពីសំណួរបឋមសួរដោយប្រធានអង្គជំនុំជម្រះ។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសូមឲ្យ-- អនុញ្ញាតឲ្យមេធាវីការពារក្តីមានយោបល់។

សូមអញ្ជើញបាទ!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ លោក នួន ជា សុំអនុញ្ញាតទៅតាមដានសវនាការល្ងាចនេះពីបន្ទប់នៅខាងក្រោម ហើយខ្ញុំបាទនឹងដាក់ជូនលិខិតបោះបង់សិទ្ធិជូនតុលាការបន្ទាប់ពីនេះ។ សូមអរគុណបាទ។

[១២:០៩:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ ហើយក្រុមមេធាវីការពារក្តីរបស់គាត់បានសន្យាថា នឹងប្រគល់

មកឲ្យអង្គជំនុំជម្រះភ្ជាមនូវលិខិតលះបង់សិទ្ធិចូលរួមផ្ទាល់ ក្នុងកិច្ចដំណើរការសវនាការរបស់ជនជាប់ចោទ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ។

[១២:១០:២០]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ។ នៅរសៀលនេះឲ្យទុកលោក នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១១ នាទី ដល់ម៉ោង ១៣:៣៧ នាទី)*

[១៣:៣៧:១៧]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីព្រឹកមិញ ថានៅកិច្ចដំណើរការសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់នូវសក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-604 ដែលថ្ងៃនេះយើងនឹងចាប់ផ្តើមស្តាប់សក្ខីកម្មរូបនេះជាពេលដំបូង។

លោក ឌុច ផារី តើសាក្សី TCW-604 មានវត្តមានហើយឬនៅ ហើយទំនាក់ទំនងរវាងគាត់ជាមួយនឹងភាគីនៃរឿងក្តី ហើយនិងការធ្វើសម្បថរបស់គាត់យ៉ាងម៉េចដែរ?សូមលោកឡើងរាយការណ៍!

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន សាក្សីដែលមានរហស្សនាម TCW-604 មានវត្តមាននៅក្នុងបន្ទប់រង់ចាំ។ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកកាលពីពេលព្រឹកមិញរួចហើយ។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់នោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-604 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៧:៤៦]

បាទ សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន អង្គសវនាការទាំងមូល ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូនលោក

ប្រធាន មេធាវីនាំមុខផ្ទេរសិទ្ធិនៅក្នុងការធ្វើអន្តរាគមន៍ពាក់ព័ន្ធនឹងសាក្សីរូបនេះ ជូនលោកស្រី ទី ស្រ៊ីន ណា ហើយនិងលោកស្រីមេធាវីនាំមុខ អេលីហ្សាបេត ខ្លួនឯងផ្ទាល់តែម្តង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

[១៣:៣៩:២១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអ្វីដែរ?

**លោក សៅ សារុន៖**

**ឆ៖** ខ្ញុំបាទសូមគោរព ខ្ញុំឈ្មោះ សៅ សារុន។

**ស៖** បាទ អរគុណ។ លោក សៅ សារុន តើក្រៅពីឈ្មោះ សៅ សារុន តើលោកធ្លាប់មានប្រើឈ្មោះអ្វីផ្សេងពីនេះដែរឬទេ?

លោកៗ សៅ សារុន ឆ្លើយណ៎ា។ តើលោកធ្លាប់ដែលប្រើឈ្មោះអ្វីផ្សេង ក្រៅពីឈ្មោះ សៅ សារុន ដែរឬទេ?

**ឆ៖** អត់មានទេ មានតែឈ្មោះតែមួយ។

**ស៖** បាទ អរគុណ។ ចុះជំនាន់ធ្វើបដិវត្តន៍ ចន្លោះឆ្នាំ៧០-៧៩ តើលោកប្រើឈ្មោះអ្វីដែរ? ឈ្មោះក្នុងបដិវត្តន៍?

**ឆ៖** អត់មានទេ។

[១៣:៤០:៤៧]

**ស៖** បានន័យថា លោកអត់មានប្រើឈ្មោះអ្វីផ្សេង ក្រៅពីឈ្មោះ សៅ សារុន ទេ អ៊ីចឹងពិតមែនដែរឬទេ? លោកឆ្លើយណ៎ា កុំអាលទានល់ឆ្លើយរហ័សពេក លោករង់ចាំភ្លើងក្រហមនៅពីមុខលោកហ្នឹង សូមលោកឆ្លើយ បើពុំដូច្នោះទេ កាលណាលោកឆ្លើយទៅអត់បានចូលទៅក្នុងប្រព័ន្ធនៃការបកប្រែជាភាសាផ្សេងៗទេ។ អ៊ីចឹង គឺមិនអាចដំណើរការបានទេ ព្រោះនៅទីនេះប្រើជា បីភាសា ភាសាខ្មែរ ភាសាអង់គ្លេស ហើយនិងភាសាបារាំង។ លោក សៅ សារុន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ផ៖** ៧០។ បើអាយុមែនទែនហ្នឹង គឺអាចចូល៨០ហើយ។

**ស៖** លោកដឹងថ្ងៃខែឆ្នាំកំណើតរបស់លោក លោកចាំទេថ្ងៃខែឆ្នាំកំណើតរបស់លោក តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ? តើលោកកើតថ្ងៃខែឆ្នាំអីទៅ?

[១៣:៤២:១២]

**ផ៖** អត់ដឹងទេ អត់ដឹងខែអត់ដឹងថ្ងៃទេ។

**ស៖** តើលោកមានទីលំនៅសព្វថ្ងៃនេះ នៅទីកន្លែងណា?

**ផ៖** សព្វថ្ងៃនៅភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

**ស៖** បាទអរគុណ។ លោក សៅ សារុន លោកអាចឈរ ឲ្យត្រង់ខ្លួនក៏បានដែរ មិនបាច់ងាកជិតមីក្រូទេ ក្បាលមីក្រូហ្នឹងអាចចម្ងាយជាប្អូនតឹក ក៏អាចស្រូបសំឡេងលោកស្ដាប់បានដែរ ប្រហែលហ្នឹងក៏លោកអាចស្ដាប់បានដែរ មិនបាច់ងោកទៅរកក្បាលមីក្រូទេ អាចឈរអង្គុយឲ្យបានត្រង់ខ្លួនអ៊ីចឹងក៏បានដែរណ៎ា។ សព្វថ្ងៃតើលោកប្រកបមុខរបរអ្វីដែរ?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)* ស្រែ។

**ស៖** សូមឆ្លើយម្ដងទៀត!

**ផ៖** ធ្វើស្រែ។

**ស៖** តើឪពុកបង្កើតរបស់លោក គាត់ឈ្មោះអ្វីដែរ?

**ផ៖** ឈ្មោះ នូ។

**ស៖** គាត់ប្រើត្រកូលអីទៅ ឈ្មោះ នូ ឈ្មោះរបស់គាត់។ ចុះត្រកូល? គាត់ឈ្មោះអី? ឪពុកឈ្មោះអី? ទាំងត្រកូលទាំងនាមខ្លួនរបស់គាត់ឈ្មោះអីទៅ?

[១៣:៤៤:០០]

**ផ៖** សៅ នូ។

**ស៖** ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ផ៖** ប្រុង។

**ស៖** ចុះគាត់យកនាមត្រកូលអីទៅ?

**ផ៖** នាមត្រកូល គ្រេន១។

**ស៖** គ្រេន ប្រុង?

**ឆ៖** បាទ។

**ស៖** ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអ្វីដែរ? អញ្ជើញឆ្លើយ ប្រពន្ធរបស់លោកឈ្មោះអី?

[១៣:៤៤:៥៧]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ឈ្មោះ ម៉ឺត អ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ចុះគាត់មានត្រកូលអីដែរ?

**ឆ៖** នូ។

**ស៖** នូ ម៉ឺត ប្រពន្ធរបស់លោកឈ្មោះ នូ ម៉ឺត អ៊ីចឹងមែនទេ? *(ឮមិនច្បាស់)*។

**ឆ៖** នូ ម៉ឺត។

**ស៖** តើលោកមានកូនប៉ុន្មាននាក់? លោក សៅ សារុន តើលោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានទាំងអស់ ១០នាក់។

**ស៖** ប្រុសប៉ុន្មាននាក់? ស្រីប៉ុន្មាននាក់ដែរ?

**ឆ៖** ប្រុសប្រាំនាក់ ស្រីប្រាំនាក់។

[១៣:៤៦:១១]

**ស៖** បាទ អរគុណ។ លោក សៅ សារុន តាមរបាយកាណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានញាតិលោហិត ឬញាតិពន្ធជាមួយនឹងគូភាគីនៃរឿងក្តីនេះទេ។ គឺជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាជនជាប់ចោទដែរ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** ហើយតាមរបាយការណ៍អម្បាញ់មិញនេះដែរ គឺក្រឡាបញ្ជីបានរាយការណ៍ថា លោកបានធ្វើសម្បថមុខអ្នកតាដំបងដែករួចហើយ នៅមុនពេលដែលចូលមកកាន់ទីកន្លែងផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះនេះ តើពិតមែនដែរឬទេ?

[១៣:៤៧:០៣]

**ឆ៖** បាទ ពិតមែន។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជំនុំជម្រះសូមជម្រាប អំពីសិទ្ធិ និងករណីយកិច្ច ក្នុងនាមលោកជាសាក្សីចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោក សៅ សារុន ក្នុងនាមលោកជាសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសូមឲ្យធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងមានន័យថា ដោយសារតែចម្លើយ ឬការធ្វើអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ ហើយទន្ទឹមនឹងនេះដែរ គឺក្នុងនាមលោកជាសាក្សី លោកក៏មានករណីយកិច្ចត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការនេះ ដោយត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលនឹងសួរដោយភាគី ឬដោយអង្គជំនុំជម្រះចំពោះលោក លើកលែងតែក្នុងករណីការឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដូចយើងបានប្រាប់លោកខាងលើអម្បាញ់មិញនេះ។

[១៣:៤៨:៣២]

ហើយលោកជាសាក្សី លោកត្រូវឆ្លើយការណ៍ណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏មានបទពិសោធន៍ផ្ទាល់ឆ្លងកាត់ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នៅក្នុងព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះតាំងសំណួរចំពោះលោក។ តើលោកយល់ដែរឬទេ អំពីសិទ្ធិ និងករណីយកិច្ចនេះ?

**លោក សៅ សារុន៖**

បាទ យល់ហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ មុននឹងប្រគល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើតាំងសំណួរដេញដោលចំពោះសាក្សីនេះមុនគេ អង្គជំនុំជម្រះសូមរំឭក និងជម្រាបជូនភាគីឲ្យបានជ្រាបផងដែរថាដោយសារសាក្សីនេះគាត់មានវ័យចាស់ ហើយគាត់មានបញ្ហាភ្នែក ហើយនិងបញ្ហាត្រចៀក។ ដូច្នេះសូមភាគីដែលពាក់ព័ន្ធក្នុងការតាំងសំណួរដេញដោល គួរតែត្រូវបានរៀបចំដោយមានការប្រយ័ត្នប្រយែងក្នុងការតាំងសំណួរ ឬក៏ដាក់បង្ហាញឯកសារផ្សេងៗ ដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានរលូន ត្រឹមត្រូវ ហើយនិងងាយស្រួលនៅក្នុងការដេញដោលនេះ។

E1/81.1

ហើយជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀត។ សូមអញ្ជើញ!

[១៣:៥០:២៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ជម្រាបសួរលោក សៅ សារុន! ខ្ញុំនឹងចាប់ផ្តើមសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិគ្រួសាររបស់លោក។ ដូចដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា លោកមានកូនចំនួន ១០នាក់។ ប៉ុន្តែបើខ្ញុំគ្រាន់តែចង់សួរបញ្ជាក់លោកឱ្យបានច្បាស់បន្ថែមទៀត ដែលចម្លើយដែលលោកបានឆ្លើយនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងបួនលើក គឺជាពិសេសនៅក្នុងឯកសារលេខ D125/167។ នៅពេលនោះ លោកបានឆ្លើយបញ្ជាក់ទៅក្រុមអ្នកស៊ើបអង្កេតនុ៎ងថា លោកមានកូនប្រាំមួយនាក់ តើលោកនៅរក្សាចម្លើយមួយណាដែលជាការត្រឹមត្រូវបាទ សូមលោកឆ្លើយមកបាទ?

[១៣:៥១:៤២]

**លោក សៅ សារុន៖**

**ឆ៖** គឺ ខ្ញុំថា ១០នាក់ហ្នឹង គឺវាស្លាប់តាំង-- វាស្លាប់បួននាក់ វានៅសល់ប្រាំមួយនាក់។ អ៊ីចឹងបានជាខ្ញុំប្រាប់ថា ប្រាំមួយនាក់ហ្នឹង។

**ស៖** បាទ អរគុណ។ ជាមួយគ្នានេះដែរ តើប្រពន្ធរបស់លោកដែលលោកបានបញ្ជាក់ឈ្មោះ នូ មឿន ហ្នឹងគាត់មានឈ្មោះហៅអ្វីផ្សេងទៀតដែរទេ?

**ឆ៖** មាន។

**ស៖** ឈ្មោះអ្វីដែរទៅ?

**ឆ៖** យន់ៗ

**ស៖** បាទ អរគុណ។ សូមលោកជួយជម្រាបជូនអង្គសវនាការបន្ថែមផងដែរថា តើលោកមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

**ឆ៖** បងប្អូនបង្កើតទាំងអស់ ទាំងស្លាប់ ទាំងនៅរស់ ១០នាក់។

[១៣:៥៣:០៤]

**ស៖** លោកអាចជម្រាបជូនបានទេថា ប្រុសប៉ុន្មាន? ស្រីប៉ុន្មានដែរ?

**ឆ៖** ប្រុសបួននាក់ ស្រីប្រាំមួយនាក់។

**ស៖** បាទ អរគុណ។ នៅពេលថ្មីៗនេះគឺខាងផ្នែកគាំពារ-- អង្គភាពគាំពារសាក្សី និងអ្នកជំនាញគឺគាត់បានពិនិត្យអំពីស្ថានភាពរបស់លោក ហើយគឺឃើញថាលោកបានប្រើឈ្មោះថា នូ សារុន។ តើនេះជាឈ្មោះរបស់លោកដែរឬទេបាទ?

**ឆ៖** ជាឪពុក ខ្ញុំយកនាមជីតាហ្នឹង គឺសៅ។

**ស៖** តើលោកអាចជម្រាបជូនអង្គសវនាការបានទេថា តើលោកប្រើឈ្មោះ នូ សារុន ហ្នឹងចាប់តាំងពីពេលណាមក?

**ឆ៖** ប្រើចាប់ពីពេល ពេលគេហ្នឹង-- ពី៧៤ ៧៥ ហ្នឹងឯង។

**ស៖** ចុះនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យកាន់អំណាចហ្នឹង តើលោកធ្លាប់ប្រើឈ្មោះអីផ្សេងទៀតទេ ដូចជា ឈ្មោះ បៃ អីមានទេ?

**ឆ៖** ឈ្មោះ សៅ សារុន តែមួយ។

**ស៖** សូម-- អំមិញហាក់បីដូចជាស្តាប់អត់សូវជាច្បាស់។ ចង់ឲ្យលោកជួយបញ្ជាក់ថា តើលោកធ្លាប់បានប្រើឈ្មោះ បៃ អីដែរទេ?

**ឆ៖** អត់។

**ស៖** អ៊ីចឹងលោកមានដឹងទេថា នៅក្នុងសមាជិកគណៈតំបន់១០៥ តើមានអ្នកណាធ្លាប់ប្រើឈ្មោះ បៃ ហើយនិងឈ្មោះ សារុន អីដែរទេ?

**ឆ៖** មានតែឈ្មោះខ្ញុំទេ សារុន។ សៅ សារុន ៗនេះ។

[១៣:៥៦:០១]

**ស៖** នៅអំឡុងពេល ឬក៏មុនពេលកម្ពុជាប្រជាធិបតេយ្យកាន់អំណាច តើលោកធ្លាប់បានបំពេញប្រវត្តិរូប ឬក៏នៅបំពេញប្រវត្តិរូប បំពេញប្រវត្តិធ្វើបដិវត្តន៍អីដែរទេពេលនុ៎ង?

**ឆ៖** បាន បានបំពេញ។

**លោក សេង ប៊ុនឃាង៖**

ជាបន្តទៅទៀតនេះ ខ្ញុំមានឯកសារមួយដែលជាជីវប្រវត្តិបដិវត្តន៍ ហើយដែលយើងជឿថា ជា

ប្រវត្តិរបស់សាក្សី សៅ សារុន នេះ។ ហើយខ្ញុំក៏មានសំណួរមួយចំនួនសួរទៅសាក្សីនេះ ដែលទាក់ទងទៅនឹងប្រវត្តិបដិវត្តន៍នេះផងដែរ។ ហើយដូច្នេះ ខ្ញុំសូមស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារ D175/3.55 ដោយយោងទៅតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង និងដើម្បីសាកសួរសាក្សីនេះ យោងទៅលើឯកសារនេះផងដែរ។ ហើយអម្បាញ់មិញ ហាក់បីដូចជាសហការីរបស់ខ្ញុំបញ្ជាក់ថា លេខឯកសារប្រហែលជាមានការខុសបកប្រែ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់លេខឯកសារម្តងទៀត គឺឯកសារ D175/3.55។

[១៣:៥៧:៥៤]

មូលហេតុនៃការស្នើសុំដាក់ឯកសារនេះ គឺដោយសារកន្លងមក យើងឃើញថា ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានធ្វើការសម្ភាសជាមួយសាក្សីរូបនេះ គឺមិនបានបញ្ជាក់ថា សាក្សីឈ្មោះ សៅ សារុន នេះមានឈ្មោះហៅក្រៅអីទេ។ រហូតមកដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ បានដាក់របាយការណ៍មួយដែលបង្ហាញឲ្យឃើញថា សាក្សីរូបនេះ គឺមានឈ្មោះ នូ សារុន ផងដែរ។ ហើយទើបតែនៅដំណាក់កាលត្រៀមរៀបចំ ការសួរដេញដោលទៅលើសាក្សីរូបនេះ ការិយាល័យសហព្រះរាជអាជ្ញា បានឃើញកំណត់ហេតុស្តាប់ចម្លើយសាក្សីពីររូបដែលបញ្ជាក់ថា ឈ្មោះ នូ សារុន ក៏ធ្លាប់ប្រើឈ្មោះ បៃ ផងដែរ។ លុះមកដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ទើបការិយាល័យសហព្រះរាជអាជ្ញាស្រាវជ្រាវតាមរយៈប្រពន្ធ័ *ហ្សាយឡេប* ក៏ឃើញមានប្រវត្តិរូបបដិវត្តន៍របស់កម្មាភិបាលមួយរូប ដែលកំណត់អត្តសញ្ញាណថា បៃ ហើយឈ្មោះបដិវត្តន៍ថា សារុន។

[១៣:៥៩:០៥]

ប្រវត្តិរូបនេះជាឯកសារដែលបានដាក់ចូលក្នុងសំណុំរឿងរួចហើយ ហើយនិងមានឯកសារលេខដូចដែលខ្ញុំបានបញ្ជាក់ហ្នឹង គឺ D175/3.55។ នៅក្នុងឯកសារប្រវត្តិរូបបដិវត្តន៍នេះដែរ គាត់បានបង្ហាញអំពីប្រវត្តិរូបបដិវត្តន៍របស់សាក្សីរូបនេះ ហើយបើយើងពិនិត្យទៅលើព័ត៌មានផ្សេងៗ ដែលមាននៅក្នុងប្រវត្តិរូបបដិវត្តន៍នេះ ឃើញថា ទីកន្លែងកំណើត ឈ្មោះប្រពន្ធ និងចំនួនកូនរបស់គាត់ គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានសម្ភាសគាត់។

ដូច្នេះ បើយើងពិនិត្យទៅលើវិធាន៨៧(៣) ឃើញថាឯកសារនេះ គឺវាមានភាពពាក់ព័ន្ធ និងអាច

ទទួលយកបាន។ ព្រោះថាឯកសារនេះបានបង្ហាញអំពីព័ត៌មានសំខាន់ៗ ទាក់ទងទៅនឹងតួនាទីរបស់សាក្សីនៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ដែលរួមទាំងអង្គហេតុដែលជា-- ដែលបម្រើការងារនៅតំបន់នៃមណ្ឌល-- ខេត្តមណ្ឌលគិរី។ ឯកសារនេះ ក៏បានបង្ហាញនូវព័ត៌មានពិស្តារផងដែរ ដែលតម្រូវឲ្យកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង ឲ្យសរសេរ បំពេញប្រវត្តិរូបនានា ដូចជាវណ្ណភាព កម្រិតវប្បធម៌ និងប្រវត្តិមុខងារ កន្លងមកផងដែរ។ ហើយដែលទាំងអស់នេះ គឺវាមានព័ត៌មានស្រដៀងគ្នា ទៅនឹងប្រពន្ធ កូន ឪពុកម្តាយ បងប្អូន និងមិត្តភក្តិផងដែរ។

ដូច្នេះ ការិយាល័យសហព្រះរាជអាជ្ញាសូមស្នើសុំដាក់បញ្ចូលឯកសារដែលមានលេខ D175/3.55 នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដើម្បីប្រើឯកសារនេះ ដើម្បីសម្រាប់ជួយ សម្រាប់សួរដេញដោលទៅលើសាក្សីនេះផងដែរបាទ។

[១៤:០១:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ហើយរីឯលេខយោងនេះ គប្បីតែឲ្យភាគីបានដឹងច្បាស់។ នៅពេលនេះ ខ្ញុំមិនដឹងថា សូមជំទាស់នឹងឯកសារហ្នឹងដោយខ្លួនឯង ដែលថាសហព្រះរាជអាជ្ញាប្រើពេលដប់នាទីដើម្បីពន្យល់ពីឯកសារ ហើយគួរតែសួរសំណួរទៅសាក្សីវិញ ដើម្បីថា បញ្ជាក់ថាឯកសារនោះពាក់ព័ន្ធ។ ដូច្នេះ តើព្រះរាជអាជ្ញាចង់ឲ្យសាក្សីបញ្ជាក់ទទួលស្គាល់ដូចម្តេច? ហើយគាត់នៅទីនេះ ដើម្បីឲ្យលោកសួរ ហើយគាត់ឆ្លើយ។ បើសិនជាលោកពន្យល់ពីភាពពាក់ព័ន្ធ ហើយពីប្រវត្តិរូប។ ខ្ញុំមិនយល់ពីគោលបំណងថា តើការពន្យល់ពីឯកសារដប់មីនុត ដោយមិនសួរសំណួរអ្វីសោះហ្នឹង ព្រះរាជអាជ្ញាមានបំណងធ្វើអ្វីនោះទេ។ ដូច្នេះ សូមតុលាការជ្រាប។

**ប្រធានអង្គជំនុំ៖**

បញ្ហាចំពោះមុខនេះ តំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារនេះ បំណង ខ្លួនមានបំណងទំនងជាមានបំណងស្នើសុំដាក់ឯកសារនេះ ចំពោះមុខអង្គជំនុំជម្រះនាពេលនេះ ដើម្បីខ្លួនមានលទ្ធភាពក្រោយពេលអង្គជំនុំជម្រះសម្រេចហ្នឹង ខ្លួនលើកយកឯកសារនេះ ទៅដាក់ដេញដោលចំពោះមុខ-- ដេញដោលសាក្សីរូបនេះ។ តើភាគីតំណាង-- អ៎ មានភាគីការពារក្តី តើមានមតិយោបល់យ៉ាងម៉េចទេ លើ

បញ្ហាសំណើសុំនេះ? ពីព្រោះគាត់បានប្រាប់ហើយ ឯកសារនេះគឺមិនមាននៅក្នុងបញ្ជីឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះកន្លងមកទេ ទើបតែស្វែងរកឃើញថ្មីៗនេះប៉ុណ្ណោះ។

[១៤:០៣:១៥]

**លោក ហ្សាស្តេ ប៉ោះ៖**

សូមអរគុណលោកប្រធាន។ ទាក់ទងថាតើឯកសារនេះ គប្បីអនុញ្ញាតឱ្យដេញដោលចំពោះតុលាការអត់នោះ គឺថាយើងមិនប្រកាន់ជំហរអ្វីទេ ទាក់ទងទៅថាតើអាចប្រើ ឬមិនប្រើមកសួរសាក្សីនេះ គឺថាជំហររបស់យើងគឺច្បាស់ គឺថាគប្បីឱ្យប្រើក្នុងបំណងនោះ វាអាចនឹងឯកសារពាក់ព័ន្ធ ហើយសាក្សីអាចនឹងផ្តល់យោបល់បាន ហើយយើងអាចនឹង-- យើងខ្ញុំអាចនឹងទទួលបានព័ត៌មានខ្លះ ផ្អែកតាមឯកសារនេះ។ នៅក្នុងគោលបំណង-- តាំងសំណួរលើសាក្សីនេះ ឯកសារនេះ គឺគប្បីតែអនុញ្ញាតឱ្យយកមកប្រើបាន។ នេះជាជំហររបស់យើងខ្ញុំបាទ។

[១៤:០៤:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៤:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមជម្រាបលោកប្រធាន ហើយនិងភាគីទាំងអស់។ ខ្ញុំចង់បន្ថែមទៅហ្នឹងមតិរបស់សហសេវិករបស់ខ្ញុំ គិតថាបន្ទាប់ពីយើងបានឃើញឯកសារនេះ សប្តាហ៍មុនហ្នឹង គឺថាយើងបានដាក់សំណើនៅថ្ងៃព្រហស្បតិ៍ ពន្យល់ពីមូលហេតុដែលថាយើបានរកឃើញឯកសារនេះ។ ដូច្នេះ មូលហេតុដែលគាំទ្រៗសំណើរបស់ខ្ញុំហ្នឹង គឺយើងនឹងសួរសំណួរ សហសេវិករបស់ខ្ញុំប្រកាន់ជំហរ ដើម្បីសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីសួរសំណួរសាក្សី។ ជាពិសេសទាក់ទងទៅអ្វីដែលយើងជឿជាក់ថា វាមានការពាក់ព័ន្ធពីឯកសារដែលយើងរកឃើញក្នុងពេលថ្មីៗនេះ បាទ។

[១៤:០៥:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៧:២០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា ក្នុងការដាក់ឯកសារដែលមានអត្តសញ្ញាណលេខ D175/3.55 ដែលមានចំណងជើងថា "ពិនិត្យប្រវត្តិរូបបដិវត្តន៍" ដោយសំអាងហេតុយ៉ាងជាមូលដ្ឋានសមរម្យ ដោយផ្អែកលើបទប្បញ្ញត្តិនៃវិធាន ៨៧(៣) និង ៨៧(៤) ហើយម្យ៉ាងទៀត តំណាងសហព្រះរាជអាជ្ញាបានបង្ហាញច្បាស់លាស់ហើយ គឺថាខ្លួនបានដាក់សំណើសុំជាលាយលក្ខណ៍អក្សរកាលពីចុងសប្តាហ៍មុន ហើយដោយសារការបង្ហាញហេតុអម្បាញ់មិញនេះឃើញថាមានការពាក់ព័ន្ធ គឺអង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចយកឯកសារនេះមកដាក់ដេញដោលចំពោះសាក្សីនេះ ចំពោះមុខអង្គជំនុំជម្រះបាន។

[១៤:០៨:៣០]

ប៉ុន្តែអង្គជំនុំជម្រះសូមជម្រាបថា សូមឲ្យច្បាស់លាស់ គឺករណីនេះមិនមែនជាករណីការដាក់ឯកសារសួរផ្ទុញនោះឡើយ។ ចំណែកឯឯកសារសួរផ្ទុញ គឺសូមឲ្យភាគីមានការចាប់អារម្មណ៍ និងអនុវត្តទៅតាមសេចក្តីណែនាំអនុវត្តរបស់អង្គជំនុំជម្រះ ដែលបានចេញថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ បាទជាបន្តទៀត ខ្ញុំនឹងសួរសំណួរទៅលោកសៅ សារុន បន្តទៀត។

លោក--

**ប្រធានអង្គជំនុំ៖**

លោក១ សៅ សារុន លោកមើលឃើញភ្លើងក្រហម ១នៅហ្នឹងដែរទេ? នៅជិតខ្លួនលោកដែរឬទេ?

[១៤:០៩:៣៤]

**លោក សៅ សារុន៖**

អត់។ អត់ឃើញ ងងឹតភ្នែក។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវដោយសារ បញ្ហានេះដោយសារយើងបានទទួលព័ត៌មានពីអង្គភាពគាំពារសាក្សី និង

អ្នកជំនាញថាគាត់មានបញ្ហាភ្នែកខ្លាំង ដោយសារគាត់ពិបាកមើល ហើយនិងត្រចៀកពិបាកស្តាប់។ ហើយត្រចៀកហ្នឹងយើងបានឲ្យគាត់រៀបចំ ខាងមន្ត្រីរដ្ឋបាលតុលាការរៀបចំនូវដំឡើងនូវ *វូលើម* សំឡេងឲ្យបានខ្ពស់ដើម្បីឲ្យគាត់អាចស្តាប់បាន ប៉ុន្តែភ្នែកហ្នឹងមិនមានមធ្យោបាយអី ដំឡើង *វូលើម* ដើម្បីឲ្យភ្នែកគាត់មើលឃើញបានទេ។ ហើយដើម្បីសម្រួលកិច្ចការនេះ សូមផ្តល់ភារកិច្ចបន្ថែមមួយដល់មេធាវីប្រឹក្សារបស់គាត់ សូមឲ្យជួយសម្របសម្រួល កេះគាត់ដើម្បីឲ្យគាត់អឺ... បានន័យថាប្រាប់គាត់ឲ្យគាត់ឆ្លើយតបផង នៅពេលដែលមានភ្លើង។ នេះជាសម្រួលដើម្បីឲ្យចាត់ការដឹងថា គាត់ដល់ពេលគាត់ត្រូវឆ្លើយតបទៅនឹងសំណួរហើយ។ មិនមែនជាការប្រឹក្សាយោបល់អ្វីពាក់ព័ន្ធទៅនឹងខ្លឹមសារនៃៗចម្លើយទេ។ គឺពាក់ព័ន្ធនឹងនីតិវិធី ដែលរៀបចំធ្វើយ៉ាងម៉េចឲ្យគាត់អាចពន្លឿនកិច្ចដំណើរការនីតិវិធី។

[១៤:១០:៥១]

អ៊ីចឹងលោកមេធាវីអាចជួយសម្រួលក្នុងការកេះប្រាប់គាត់ទៅ ដើម្បីឲ្យគាត់ឆ្លើយដូចអម្បាញ់មិញហ្នឹង គ្រាន់តែអំមិញនេះយើងធ្វើទៅមិនមានបញ្ហា ឬក៏អនុញ្ញាតពីអង្គជំនុំជម្រះប៉ុណ្ណោះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោក សៅ សារុន ដូចដែលខ្ញុំបានជម្រាបជូនអង្គសវនាការអម្បាញ់មិញហើយថា ការិយាល័យសហព្រះរាជអាជ្ញាបានឃើញប្រវត្តិរូបមួយ ដែលមានឈ្មោះថា បៃ ហៅ សារុន ដែលមានទីកន្លែងកំណើតដូចលោកដែរ គឺនៅភូមិកោះម៉ាឃើល ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ហើយដែលគាត់មានប្រពន្ធឈ្មោះ ម៉ឺត ហៅ យន់ និងមានកូនប្រាំពីរនាក់ ប្រុសបី ស្រីបួន ប៉ុន្តែស្លាប់មួយ គឺនៅសល់ប្រាំមួយ។ ហើយគាត់ក៏មានបងប្អូន ១០នាក់ផងដែរ។ យោងទៅតាមអ្វីដែលខ្ញុំបានលើកឡើងនេះ តើលោកជឿថានេះជាប្រវត្តិរូបបដិវត្តន៍របស់លោកដែរទេ?

[១៤:១២:០៨]

**លោក សៅ សារុន៖**

**ឆ៖** បាទ ថាប្រាំពីរហ្នឹង គឺអត់ត្រូវទេ។ កូនខ្ញុំ គឺទាំងអស់ដប់នាក់ ស្រីប្រាំ, ប្រុសប្រាំ ទាំងស្លាប់ទាំងនៅរស់។ ស្លាប់បួន នៅរស់ប្រាំមួយ។

**ស៖** បាទ អរគុណ។ ប៉ុន្តែតើលោកជឿថា អ្វីដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញ ដែលជាឯកសារដែលមានឈ្មោះថា “ប្រវត្តិរូបបដិវត្តន៍” នេះ តើលោកជឿថា វាជាប្រវត្តិរបស់លោកដែរទេ?

**ឆ៖** បាទ ជាប្រវត្តិរូបរបស់ខ្ញុំ ប៉ុន្តែ បៃ ហ្នឹង ខ្ញុំដូចមិនបានយល់ ពីព្រោះធ្វើប្រវត្តិរូបមានតែថា សៅ សារុន១ ហ្នឹង។

**ស៖** បាទ សូមអរគុណ។ តើលោកនៅចាំទេថា ប្រភេទប្រវត្តិរូបរបៀបនេះ តើគេ១-- ត្រូវបានគេប្រើប្រាស់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យកាន់អំណាចនោះដែរទេបាទ?

[១៤:១៣:៣៧]

**ឆ៖** បាទ១១ បានប្រើ តែ សៅ សារុន ទេ តែ បៃ ហ្នឹងអត់ដែល។

**ស៖** ខ្ញុំចង់បញ្ជាក់អំពីប្រភេទនៃទម្រង់ប្រវត្តិរូបហ្នឹង។ តើប្រភេទ ទម្រង់ប្រវត្តិរូបអ៊ីចឹង គេ-- ត្រូវបានគេប្រើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ! ចាំស្តាប់ការជំទាស់របស់មេធាវីការពារក្តីសិន ហើយនិងអង្គជំនុំជម្រះនឹងសម្រេចបញ្ហានេះ មុននឹងអនុញ្ញាតឲ្យលោកឆ្លើយ ឬក៏មិនឲ្យឆ្លើយតបទៅនឹងសំណួរ។

[១៤:១៤:២៦]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសាជាថ្មី។ ខ្ញុំបាទ មិនមានគោលបំណងជំទាស់ទេ ប៉ុន្តែសូមធ្វើការកត់សម្គាល់មួយសម្រាប់ភាពយុត្តិធម៌សម្រាប់សាក្សីផងដែរ។ លោកព្រះរាជអាជ្ញាគាត់សួរទៅលើប្រវត្តិរូប។ ខ្ញុំគិតថាប្រវត្តិរូបនេះ ដោយសារថាសាក្សីគាត់អត់-- គាត់មិនបានឃើញ ទោះក៏អានក៏អានមិនបាន យ៉ាងហោចណាស់មុនមកទីនេះ ក៏មាន-- ត្រូវមានអ្នកណាម្នាក់អានយ៉ាងលម្អិតឲ្យគាត់ស្តាប់ដែរ បើគាត់មិនបានឃើញ។ ប៉ុន្តែដល់យើងលើកមកសួរគាត់ តើទម្រង់ប្រវត្តិរូបនេះត្រឹមត្រូវ? គេប្រើអ៊ីចឹងអីទេ ជំនាន់ហ្នឹងអីហ្នឹង? ហើយឲ្យគាត់ឆ្លើយថាត្រឹមត្រូវ តើយើងទទួលយកបានអត់? ព្រោះអត់ គាត់អត់បានឃើញផងហ្នឹង។ ហ្នឹងជាការកត់សម្គាល់របស់ខ្ញុំបាទទេទាន។ តើយើងគួរតែផ្លាស់ប្តូររបៀបយ៉ាងម៉េចដើម្បីឲ្យសាក្សីនេះគាត់បានឆ្លើយបានត្រឹមត្រូវផង។

សូមអរគុណ លោកប្រធាន។

[១៤:១៥:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ការកត់សម្គាល់របស់លោកមេធាវីជាតិការពារក្តីលោក អៀង សារី ត្រឹមត្រូវ។ តំណាងសហព្រះរាជអាជ្ញាដូរវិធីក្នុងការសួរ ដោយការសួររបស់លោកហាក់ដូចជាព្រាវដែរ ពីព្រោះមិនទាន់បានបង្ហាញទៅដល់សាក្សីនូវប្រវត្តិរូបនេះទេ ប្រវត្តិរូបកាន់ដៃខ្លួនឯង ហើយសួរសាក្សីឱ្យទទួលស្គាល់ថាប្រវត្តិរូបនេះត្រឹមត្រូវដែរឬទេ? ការសួរបែបនេះមិនទំនងទាល់តែសោះ។

ដូរវិធីដើម្បីសួរធ្វើយ៉ាងណាឲ្យមានលក្ខណៈស្គាល់ ណែនាំឲ្យសាក្សីស្គាល់អំពីខ្លឹមសារ អំពីទម្រង់នៃឯកសារដែលខ្លួនមានបំណងដាក់ ហើយបានស្នើសុំ ហើយអង្គជំនុំជម្រះបានអនុញ្ញាតរួចហើយនេះ ដើម្បីឲ្យមានលទ្ធភាពក្នុងការតាំងសំណួរ។ បើពុំដូច្នោះទេ គឺត្រៀមសំណួរនេះជាក្រោយ ហើយសួរសំណួរផ្សេងទៀត ប្រសិនបើសំណួរនេះមិនទាន់បានត្រៀមសំណួរត្រឹមត្រូវនោះទេ។

[១៤:១៦:២៣]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ខ្ញុំសូមជម្រាបជូនដែរថា ប្រវត្តិរូបបដិវត្តន៍ ដែលខ្ញុំលើកអម្បាញ់មិញនេះ គឺមានៗចំនួន១៥ ទំព័រ ហើយទម្រង់ប្រវត្តិរូបនេះគឺមានរៀបចំជាសំណួរ មានវាយអង្គុយលីលេខរួចជាស្រេច ហើយៗមានទុកកន្លែងទំនេរសម្រាប់ឲ្យអ្នកបំពេញហ្នឹងបំពេញចម្លើយផងដែរ។ ហើយឯកសារនេះ មានចំនួនប្រាំពីរផ្នែកនៃការសួរសំណួរហ្នឹង។ ផ្នែកទីមួយគឺជាប្រវត្តិផ្ទាល់ខ្លួន ហើយផ្នែកទីពីរនៃសំណួរគឺអំពីប្រពន្ធ-ប្តី ហើយផ្នែកបន្តបន្ទាប់ទៀតគឺអំពីប្រវត្តិរូបកូនបង្កើត បន្ទាប់មកទៀតគឺមានផ្នែកទាក់ទងទៅនឹងឪពុកម្តាយ ឪពុកម្តាយក្មេក និងបងប្អូនបង្កើត ហើយនៅផ្នែកចុងក្រោយនៃសំណួរក្នុងប្រវត្តិរូបនេះ គឺទាក់ទងទៅនឹងមិត្តជិតស្និទ្ធ និងមជ្ឈដ្ឋានចូលចិត្តប្រាស្រ័យ រួមប្រាស្រ័យក្រៅអង្គការបដិវត្តន៍។

[១៤:១៧:៣៨]

អ៊ីចឹងសំណួររបស់ខ្ញុំចង់សួរទៅលោកសាក្សី លោក សៅ សារុន គឺថា តើទម្រង់របៀបនេះ តើគេប្រើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរទេបាទ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំមិនមិនសូវយល់ដែរបញ្ហាហ្នឹង។ សូមអស់។

**ស៖** បាទ សូមអរគុណ។ បើពិនិត្យទៅលើក្នុងប្រវត្តិរូបរបស់លោកដែលនៅត្រង់ផ្នែកទីមួយ អំពីប្រវត្តិផ្ទាល់ខ្លួនហ្នឹង ជាពិសេសនៅត្រង់សំណួរទី១៥ នៃឯកសារ D175/3.55 ត្រង់ ERN ជាភាសាខ្មែរគឺ 00230783 បានសួរអំពីថា-- ហើយមុននឹងខ្ញុំបញ្ជាក់តទៅទៀតដែរ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់ឯកសារនេះនៅលើអេក្រង់កុំព្យូទ័រផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៤:១៩:៣៦]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បានទៅកន្លែងសំណួរទី១៥ ហ្នឹងគឺបានសួរថា៖ "បានធ្វើការពិនិត្យផ្ទាល់ និងឆ្លងតាមការបដិវត្តន៍នៅប្រវត្តិរូប និងជីវទស្សនបដិវត្តន៍ប៉ុន្មានដង? ហើយនិងចំណាយពេលវេលាទាំងត្រៀម ទាំងឆ្លងអស់ប៉ុន្មាន?" នៅក្នុងចម្លើយរបស់លោកទៅនឹងសំណួរនេះ គឺថា លោកបានធ្វើ-- បានឆ្លើយថា៖ "បានធ្វើជីវទស្សនបដិវត្តន៍ចំនួន១០ដង និងធ្វើប្រវត្តិរូបចំនួន១០ដង ហើយចំណាយពេលវេលា ទាំងត្រៀមទាំងឆ្លងអស់បី ឬបួនថ្ងៃ។ តើលោកអាចជម្រាបជូនអង្គសវនាការបានទេថា លោកមានន័យយ៉ាងម៉េច ចំពោះឃ្លាដែលថា ធ្វើជីវទស្សនៈ និងប្រវត្តិរូបចំនួន ១០ដងហ្នឹង?

[១៤:២០:៣២]

**លោក សៅ សារុន៖**

**ឆ៖** បាទ ពីព្រោះពេលទៅប្រជុំទៅ គេក៏ធ្វើ ឲ្យធ្វើប្រវត្តិ។ ពេលទៅប្រជុំពេលណា ឲ្យធ្វើប្រវត្តិរូបពេលហ្នឹងណ៎ា គឺអស់ប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេថា អ្នកណាជាអ្នកពិនិត្យប្រវត្តិរូបនេះ ហើយថា គេពិនិត្យយ៉ាងដូចម្ដេចដែរ លោកអាចដឹងទេ?

**ឆ៖** អត់ដឹង។ ដឹងគេពិនិត្យអីយ៉ាងម៉េចៗអត់ដឹងទេ ជូនគេហើយគឺថា ចប់ហើយ។

**ស៖** បាទជាទូទៅ តើរយៈប៉ុន្មានណាទើបលោកត្រូវបំពេញប្រវត្តិរូបហ្នឹងជាថ្មីឡើងវិញ លោកនៅចាំទេ?

**ធ៖** អត់ចាំទេ។

**ស៖** បាទ ចុះលោកដឹងទេ លោកនៅចាំទេថា ប្រវត្តិរូបដែលលោកបានបំពេញហើយហ្នឹង លោកដាក់ទៅអ្នកណាដែរ?

**ធ៖** គឺជូនឲ្យទៅខាងប្រធានតំបន់គេ។

**ស៖** បាទ អរគុណ។ តើប្រធានតំបន់ ប្រធានតំបន់ណា? ហើយប្រធានតំបន់ហ្នឹង ឈ្មោះអ្វីដែរលោក? សូមលោកជម្រាបជូនអង្គសវនាការផង។

[១៤:២២:២៩]

**ធ៖** តំបន់មណ្ឌលគិរី។

**ស៖** ប្រធានតំបន់ហ្នឹង មានឈ្មោះអ្វីដែរ?

**ធ៖** ឈ្មោះ ឡាំង។

**ស៖** បាទ អរគុណ។ តើលោកដឹងទេ ប្រវត្តិរូបរបស់កម្មាភិបាលនៅតំបន់ ដែលលោកនិយាយអំមិញនៅតំបន់មណ្ឌលគិរីហ្នឹង នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យហ្នឹង តើគេយកប្រវត្តិរូបហ្នឹងទៅទុកនៅកន្លែងណាដែរ?

**ធ៖** អត់ដឹងទេៗ។ អត់ដឹងគេទុកត្រង់ណា។

**ស៖** បាទ ឥឡូវខ្ញុំចូលមកទាក់ទងនឹងតួនាទីរបស់លោកដែលជាសមាជិកក្នុងបដិវត្តន៍ និងក្នុងបក្ស។ ដូចដែលលោកបានជម្រាបជូនអង្គសវនាការហើយថា លោកកើតនៅភូមិកោះម៉ាយើល ស្ថិតនៅក្នុងស្រុកកោះញែក។ ចុះថា-- សំណួរសួរថា តើនៅឆ្នាំ១៩៥៤ លោករស់នៅកន្លែងនោះដដែល ឬក៏លោកទៅនៅកន្លែងណាផ្សេង?

[១៤:២៤:១៦]

**ធ៖** បាទ នៅភូមិកោះម៉ាយើលដដែល។

**ស៖** នៅពេលនោះ តើលោកស្គាល់ កែត និងឈ្មោះ បុន ដែរទេ?

**ធ៖** អត់ទេ។

**ស៖** តើលោកចាំដែរទេថា នរណាជាអ្នកណែនាំលោកឲ្យចូលនៅក្នុងបដិវត្តន៍ហ្នឹង នៅឆ្នាំ១៩៥៤ហ្នឹង?

**ធ៖** ឡាំង។

**ស៖** តើកាលនុ៎ងឈ្មោះ ឡាំង គាត់មានតួនាទីជាអ្វីដែរ?

**ឆ៖** អត់ដឹងទេ អត់ដឹងគាត់តួនាទីស្អីទេ។ អត់ដឹង។

**លោក សេង ប៊ុនឃាង៖**

បាទ ហើយជាបន្តទៀត ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីដាក់នៅលើអេក្រង់កុំព្យូទ័រ នៅឯកសារលេខ D175/3.55 ដដែលនៅត្រង់ ERN ជាភាសាខ្មែរគឺ 00230781។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៤:២៦:៤៥]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** នៅក្នុងឯកសារនេះ គឺជាពិសេសនៅត្រង់ចម្លើយលេខ៨ ក្នុងផ្នែកទីមួយនៃប្រវត្តិរូបបដិវត្តន៍នេះ គឺបានសរសេរថា លោកបានចូលបដិវត្តន៍នៅឆ្នាំ១៩៥៤ នៅភូមិកោះម៉ាយើល ហើយអ្នកនាំលោកចូលបដិវត្តន៍នោះ គឺសមមិត្ត កែត និងសមមិត្ត បុន។ ហើយចំណុចមួយទៀតដែរ នៅក្នុងចម្លើយលេខ១០ ក្នុងផ្នែកទីមួយនៃប្រវត្តិរូបបដិវត្តន៍ហ្នឹងក៏បានសរសេរដែរថា លោកបានចូលអង្គការបក្សនៅថ្ងៃទី០៤ ខែ៣ ឆ្នាំ១៩៦៣ នៅភូមិតាកក ហើយអ្នកឧទ្ទេសនាម គឺសមមិត្ត បុន និងសមមិត្ត ឡាំង។ តើការលើកឡើងនេះជាការត្រឹមត្រូវដែរទេ?

[១៤:២៧:៥៨]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ អ្នកដែលនាំលោក ឬក៏ឧទ្ទេសនាមលោកចូលបដិវត្តន៍ឈ្មោះ កែត និងបុន តើលោកស្គាល់ កែត និង បុន ហ្នឹងដោយរបៀបណាដែរ? ហើយគាត់មានតួនាទីអីនៅក្នុងបដិវត្តន៍នុ៎ងពេលនុ៎ង?

**ឆ៖** អត់ដឹងទេ។ ដឹងគាត់តួនាទីអី អត់ដឹង។

**ស៖** នៅពេលដែលលោកចូលបក្សកុម្មុយនីស្តកម្ពុជា តើលោកមានបានរៀនសូត្រវគ្គសិក្សា ឬក៏វគ្គអប់រំអំពីមាគ៌ាបក្ស និងគោលនយោបាយបក្សអីដែរទេ ពេលនុ៎ង?

[១៤:២៩:០៨]

**ឆ៖** រៀនតិចតួចទេ។ បានរៀនតិចតួចទេ។

**លោក សេង ប៊ុនឃាង៖**

បាទ ជាមួយគ្នានេះផងដែរ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីបន្តបញ្ចាំង នូវឯកសារលេខ D175/3.55 ដដែលបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញណា អាចបន្តឲ្យចប់ទៅ ពីព្រោះរឿងដដែលទេណា។ ហើយសូមឲ្យខាងផ្នែកសោតទស្សន៍ បង្ហាញឯកសារនោះនៅលើអេក្រង់ទូរទស្សន៍ផង។

[១៤:៣០:០០]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** នៅត្រង់សំណួរលេខ១៤ ក្នុងផ្នែកទីមួយនៃប្រវត្តិរូបហ្នឹងគឺបានសួរថា បានរៀនសូត្រវិជ្ជាបដិវត្តន៍ ជីវៈ ឬ ជីវៈជាសាលាណាខ្លះ? ហើយចម្លើយរបស់លោកនោះ គឺ ឆ្លើយថា "បានរៀនជាសាលា ១០ដង និងជីវៈខ្លីច្រើនដង"។ តើលោកនៅចាំទេថា សាលានោះនៅកន្លែងណា? ហើយដែលៗលោកបានទៅរៀនចំនួន ១០ដងហ្នឹង?

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺរៀននៅភូមិនេះឯង រៀននេះអត់មានសាលាទេ សាលាក្នុងព្រៃហ្នឹង រៀនទៅ។

**ស៖** ចុះលោកនៅចាំទេថា ការដែលលោកទៅរៀននៅក្នុងនេះ គេរៀនសូត្រហ្នឹង គេប្រើរយៈពេលប៉ុន្មានថ្ងៃដែរសម្រាប់វគ្គមួយៗហ្នឹង។

[១៤:៣១:២៣]

**ឆ៖** ចួនកាលបីថ្ងៃ ចួនកាលពីថ្ងៃ វាអត់ទៀងទេ។

**ស៖** តើលោកនៅចាំទេថា មាគ៌ាបដិវត្តន៍ និងមាគ៌ាបក្សអ្វីខ្លះដែលគេបង្រៀននៅពេលនោះ?

**ឆ៖** បាទ ដឹងតែថាមាគ៌ាបដិវត្តន៍អី ដឹងតែប៉ុណ្ណឹង។

**ស៖** ចុះអ្នកដែលបង្រៀនហ្នឹងមានឈ្មោះអ្វីដែរ លោកនៅចាំទេ?

**ឆ៖** អត់ចាំទេ។

**ស៖** ចុះទាក់ទងទៅនឹងចំនួនអ្នកដែលចូលរៀនហ្នឹង តើក្នុងមួយវគ្គៗហ្នឹងមានប៉ុន្មាននាក់ដែរ?

**ឆ៖** ចួនកាល ១០នាក់ ចួនកាល ប្រាំបី-ប្រាំបួននាក់ វាមិនទៀងទាត់ទេ។

**ស៖** ចុះលោកនៅចាំទេថា ប្រវត្តិរូបបដិវត្តន៍នេះលោកបានធ្វើនៅឆ្នាំណាដែរ?

**ឆ៖** អត់ចាំទេ។

**ស៖** តើលោកអាចជម្រាបជូនអង្គសវនាការបានទេថា វាៗមុន ឬវាក្រោយឆ្នាំ១៩៧៥?

**ឆ៖** អត់ជម្រាបបានទេ វាអត់ចាំ។

[១៤:៣៣:៥០]

**ស៖** ឥឡូវ ខ្ញុំសូមសួរលោកនៅសំណួរមួយចំនួនទាក់ទងទៅនឹងតួនាទី និងភារកិច្ចរបស់លោកនៅក្នុងបដិវត្តន៍ ហើយនិងនៅក្នុងបក្សអំឡុងឆ្នាំមុនឆ្នាំ១៩៧៥។ ហើយខ្ញុំនិយាយអំពីពេលដែលលោកបានចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៥៤ ហើយនិងពេលដែលលោកបានចូលបក្សក្នុងឆ្នាំ១៩៦៣។ សូមលោកជម្រាបជូនអង្គសវនាការថា តើលោកត្រូវបានគេចាត់តាំងឲ្យធ្វើការងារ ឬក៏ទទួលខុសត្រូវអ្វីខ្លះសម្រាប់បដិវត្តន៍នៅពេលនុ៎ង?

**ឆ៖** បាទ គឺឲ្យណែនាំ ដឹកនាំប្រជាជន អប់រំប្រជាជនឲ្យយល់អំពីបដិវត្តន៍នេះ។ ប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំទេថា លោកណែនាំឲ្យប្រជាជនយល់ហ្នឹង តើណែនាំពីអ្វីខ្លះទៅ?

**ឆ៖** ណែនាំអំពីថា កសាងសេដ្ឋកិច្ចជីវភាពនោះ វ៉ៃចក្រពត្តិអាមេរិកតែប៉ុណ្ណឹង។

**ស៖** សូមលោកជួយជម្រាបជូនអង្គសវនាការអំពីការណែនាំរបស់លោកទាក់ទងទៅនឹងការកសាងសេដ្ឋកិច្ចហ្នឹង តើលោកណែនាំយ៉ាងម៉េចខ្លះទៅ?

**ឆ៖** ឲ្យធ្វើស្រែ ធ្វើចម្ការ ដាំពោត ដាំដំឡូង ធ្វើយ៉ាងម៉េចកុំឲ្យមានការអត់ឃ្លាន ឲ្យគ្រប់គ្រាន់ការហូបចុក។

**ស៖** ចុះចំណេះដឹងដែលលោកបានយកទៅណែនាំនេះ តើលោកបានចេះពីណាមកដែរ?

**ឆ៖** ចេះពីការណែនាំរបស់ខាងលើអ៊ីចឹងដែរ។ គេណែនាំប៉ុណ្ណឹង គឺខ្ញុំក៏ណែនាំប៉ុណ្ណឹងដែរ។

[១៤:៣៦:១៥]

**ស៖** បាទ សូមអរគុណ។ សូមលោកជួយរៀបរាប់បន្តិចអំពី នៅខេត្តមណ្ឌលគីរីហ្នឹងក្នុងទសវត្សរ៍៥០ និងទសវត្សរ៍ទី៦០។ តើនៅខេត្តមណ្ឌលគីរីហ្នឹងប្រភេទប្រជាជនបែបណាខ្លះដែលរស់នៅ

កន្លែងនុ៎ង? ហើយពួកគេធ្វើការងារអីដែរ?

**ឆ៖** បាទ ប្រជាជននៅមណ្ឌលគីរី មានជនជាតិព្នង ជនជាតិក្រោល ជនជាតិចារ៉ាយ ជនជាតិទំពួន វាចម្រុះ។

**ស៖** តើពួកគេធ្វើការងារអ្វីទៅ នៅពេលនុ៎ង?

**ឆ៖** មានតែធ្វើស្រែ ធ្វើចម្ការតែប៉ុណ្ណឹង អត់មានធ្វើអីទេក្រៅពីហ្នឹងទេ។

**ស៖** តើលោកបានដឹងទេថា គោលដៅបដិវត្តន៍ដែលនៅខេត្តមណ្ឌលគីរីហ្នឹង គឺគេចង់បានអ្វី? គឺដើម្បីអ្វីទៅ?

**ឆ៖** គឺគោលដៅនោះ វាអត់ដឹងទេ អត់ដឹងថាទៅធ្វើបដិវត្តន៍ហ្នឹង ថាវៃអាមេរិក គឺដឹងតែប៉ុណ្ណឹងម្តង។

[១៤:៣៧:៥៤]

**ស៖** ឥឡូវ ខ្ញុំសូមត្រឡប់ទៅអំឡុងពេលដែលលោកបានចូលក្នុងបក្សក្នុងឆ្នាំ១៩៦៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សូមលោកជួយរៀបរាប់ជូនអង្គសវនាការថា តើពេលនោះលោករស់នៅកន្លែងណា? ហើយលោកត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវអ្វីខ្លះសម្រាប់បក្ស នៅអំឡុងពេលនុ៎ង?

**ឆ៖** ក្រោយ៧០ គឺខ្ញុំធ្វើទាហានទេ។

**ស៖** តើទាហាន ក្រុមទាហានរបស់លោកមានឈ្មោះអីដែរទេ?

**លោក សេង ប៊ុនឃាង៖**

ដោយបានការអនុញ្ញាតពីលោកប្រធានឲ្យបន្តការដាក់បញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រនេះ ហើយ ខ្ញុំសូមអនុញ្ញាត ខ្ញុំសូមបញ្ចាំងឯកសារនេះដដែល។ ហើយខ្ញុំនឹងលើកនូវសំណួរចម្លើយទី១១ ក្នុងផ្នែកទីមួយហ្នឹង គឺមាននៅក្នុងចំណុចនោះ ដែលបាននិយាយថា លោកបានទទួលតំណែងជាអនុលេខាឃុំ អ-៤ ទទួលបន្ទុកឈ្លបភូមិ ហើយក៏ទទួលខាងសេដ្ឋកិច្ចឃុំ អ-៤ ផងដែរ។ តើនៅពេលណាដែលលោកទទួល តើលោក តើលោកទទួលស្គាល់ចម្លើយនេះដែរឬទេ?

**ឆ៖** បាទ អត់ដឹងទេ ភ្លេចអស់ហើយ អត់ដឹង។

[១៤:៤០:០៥]

**ស៖** ដូចអ្វីដែលខ្ញុំបានបញ្ជាក់ជូននៅក្នុងឯកសារហ្នឹង ថាលោកបានទទួលតំណែងជាអនុលេខាឃុំ អ-៤ ហើយទទួលបន្ទុកឈ្លបភូមិ ហើយក៏ទទួលខាងសេដ្ឋកិច្ចឃុំ អ-៤ ផងដែរ។ តើលោកនៅចាំ

តួនាទីនេះដែរឬទេ?

**ឆ:** បាទ ចាំ បានធ្វើអ៊ីចឹងមែន។

**ស:** ចុះលោកនៅចាំទេ ថាតួនាទីរបស់លោកហ្នឹង លោកបានទទួលនៅក្នុងពេលណាដែរ? ឆ្នាំណា?

**ឆ:** អារឿងឆ្នាំណាៗ អាហ្នឹង អត់យល់ទេ ភ្លេចអស់ហើយ។

**ស:** ចុះមានការងារជាក់លាក់អ្វីខ្លះ ដែលលោកទទួលភារៈខាងការងារសេដ្ឋកិច្ចនៅក្នុងឃុំហ្នឹង លោកអាចជម្រាបជូនអង្គសវនាការបានទេ ថាមានអ្វីជាជាក់លាក់ទៅ ដែលលោកបានបំពេញនៅពេលនុ៎ង?

[១៤:៤១:២៤]

**ឆ:** បាទ គឺជាក់លាក់វា សំខាន់ណាស់ គឺបញ្ហាធ្វើស្រែ ធ្វើចម្ការ ដាំដំឡូង ដាំអី ដោះស្រាយជីវភាពប្រជាពលរដ្ឋ ប៉ុណ្ណឹង។

**ស:** បាទ អរគុណ។ ចុះទាក់ទងទៅនឹងតួនាទីរបស់លោក ដែលមានតួនាទីជាឈ្លបភូមិនោះ តើនៅពេលណា ដែលលោមានតួនាទីហ្នឹង លោកនៅចាំទេ? ហើយលោក តួនាទីរបស់លោកហ្នឹង ធ្វើខ្លះ? សូមបញ្ជាក់សំណួរឡើងវិញ។ នៅពេលដែលលោកមានតួនាទីជាឈ្លបភូមិនោះ តើលោកមានតួនាទីធ្វើអ្វីខ្លះ?

**ឆ:** តួនាទីឈ្លបភូមិហ្នឹង គឺការពារភូមិ ការពារកុំឱ្យមានចោរលួច ចោរប្លន់ តែប៉ុណ្ណឹងទេ។ មានតែតួនាទីប៉ុណ្ណឹង។ សូមអស់។

[១៤:៤២:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យ នៅកន្លែងរង់ចាំសម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់។ ហើយនិងឱ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៤៣នាទី ដល់ម៉ោង ១៥:០២នាទី)*

[១៥:០២:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី ខ្ញុំនឹងបន្តសំណួររបស់ខ្ញុំបន្តទៀត។ សូមលោកជម្រាបជូនអង្គសវនាការផងថាតើនៅពេលណា-- មានពេលណាមួយដែលលោកត្រូវបានតែងតាំងជាលេខាស្រុកណាដែរទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ឆ្នាំបានតែងតាំងលេខាស្រុកមែន ឆ្នាំ១៩៧១។

**ស៖** តើស្រុកនោះឈ្មោះអ្វីដែរ?

**ឆ៖** ស្រុកពេជ្រចិន្តា។

**ស៖** បាទ អរគុណ។ តើលោកនៅចាំទេថា តំបន់មណ្ឌលគិរីហ្នឹងត្រូវបានខ្មែរក្រហមរំដោះនៅពេលណាដែរ?

[១៥:០៤:០៥]

**ឆ៖** បាទ រំដោះឆ្នាំ១៩៧០។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការតែងតាំងលោកឲ្យធ្វើជាលេខាស្រុក តើពេលនោះនរណាជាអ្នកតែងតាំងលោកដែរ?

**ឆ៖** តាឡាំង។

**សៈ** នៅពេលដែល តាឡាំង តែងតាំងលោកឲ្យធ្វើជាលេខាស្រុកហ្នឹង តើ តាឡាំង ពេលនុ៎ង គាត់មានតួនាទីជាអ្វីទៅ?

**ផៈ** អត់ដឹងតួនាទីគាត់ជាអ្វីទេ។

**សៈ** បាទ។ សូមលោកជួយរៀបរាប់ជូនអង្គសវនាការថា តើលោកមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ ក្នុងនាមលោកជាលេខាស្រុកហ្នឹង?

**ផៈ** តួនាទីរបស់ខ្ញុំគឺគ្រប់គ្រងប្រជាជន ដឹកនាំប្រជាជនធ្វើស្រែ ធ្វើចម្ការ ធ្វើយ៉ាងម៉េចដោះស្រាយជីវភាពប្រជាពលរដ្ឋហ្នឹង ឲ្យមានបាយស៊ី មានផ្ទះនៅតែប៉ុណ្ណឹង។

**សៈ** ចុះកន្លែងធ្វើការរបស់ស្រុកពេជ្រចិន្តាហ្នឹង នៅក្នុងកន្លែងណាដែរ លោកចាំទេ?

**ផៈ** ធ្វើការនៅក្នុងស្រុកហ្នឹងតែម្តង។

**សៈ** តើស្រុកហ្នឹងនៅភូមិ ឬក៏ឃុំអីដែរទៅ?

[១៥:០៥:៣៥]

**ផៈ** ស្រុកហ្នឹងគឺនៅ ស្ថិតនៅក្នុងឃុំប៊ូស្រា ភូមិប៊ូស្រា។

**សៈ** នៅកន្លែងលោកធ្វើការហ្នឹង មានមនុស្សប៉ុន្មាននាក់ដែរ?

**ផៈ** ប្រជាពលរដ្ឋច្រើន ប្រហែលជាងបីបួនពាន់នាក់។

**សៈ** ចុះអ្នកធ្វើការ ខ្ញុំចង់និយាយពីអ្នកធ្វើការដែលនៅក្នុងស្រុកពេជ្រចិន្តាហ្នឹង ទាំងអស់មានប៉ុន្មាននាក់ទៅ?

**ផៈ** មានបួននាក់ បើទាំងយុទ្ធជនទាំងអីនេះ ទាំងអស់ហ្នឹងមាន៣០នាក់។

**សៈ** តើអ្នកដែលទាំងបួននាក់ ដែលធ្វើការនៅក្នុងស្រុកពេជ្រចិន្តាជាមួយលោកហ្នឹង ពួកគេមានតួនាទីធ្វើអ្វីខ្លះដែរនៅពេលនុ៎ង?

**ផៈ** តួនាទីចែកគ្នាប្រចាំឃុំ គ្រប់ឃុំ។

**សៈ** នៅក្នុងស្រុកពេជ្រចិន្តា មានប៉ុន្មានឃុំដែរ?

**ផៈ** មានបួនឃុំ។

**សៈ** លោកចាំបានទេថាឃុំទាំងបួនហ្នឹង មានឈ្មោះអ្វីខ្លះ?

**ផៈ** បាទ ចាំបាន។ ទីមួយ ឃុំក្រាំងតេះ ទីពីរ ឃុំប៊ូស្រា ទីបី ឃុំទោស្វាយ ទីបួន កៅក្អែ អស់។

**សៈ** បាទ អរគុណ។ តើនៅ-- លោកដឹងទេថានៅក្នុងឃុំនីមួយៗហ្នឹងមានដូចជា លេខាបក្ស

ឬក៏សមាជិកបក្សប្រចាំឃុំនីមួយៗនោះដែរទេ?

[១៥:០៩:៥២]

**ឆ៖** ឃុំខ្លះមាន ឃុំខ្លះអត់។

**ស៖** ចុះនរណាគេជាអ្នកតែងតាំងដូចជា លេខាឃុំនីមួយៗហ្នឹង?

**ឆ៖** បាទ គឺខ្ញុំជាលេខាស្រុកអ្នកតែងតាំង។

**ស៖** បាទ អរគុណ។ តើលោកបានកាន់តួនាទីជាលេខាស្រុកហ្នឹង ចាប់ពីឆ្នាំ១៩៧១ ដូចដែលលោកបានជម្រាបជូនអង្គសវនាការអំមិញហ្នឹងរហូតដល់ពេលណាដែរ?

**ឆ៖** ចាប់ពីឆ្នាំ១៩៧១ រហូតមកដល់ឆ្នាំ១៩៧៨។

**ស៖** បាទ អរគុណ។ ចុះលោកដឹងទេថា នៅតំបន់១០៥ តើមានស្រុកប៉ុន្មានដែរ?

**ឆ៖** បាទ មានស្រុកប្រាំ។ ប្រាំស្រុក។

**ស៖** លោកនៅចាំទេថា ស្រុកទាំងនុ៎ងឈ្មោះអ្វីខ្លះទៅ?

[១៥:១១:៤៦]

**ឆ៖** បាទ ទីមួយស្រុកកោះញែក។ ទីពីរ ស្រុកច្បារ។ ទីបី ស្រុកពេជ្រចិន្តា។ ទីបួន ស្រុកអូររាំង។ ទីប្រាំ ស្រុកកែវសីមា អស់។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំទេថា លេខាស្រុកមួយៗទាំងៗប្រាំ ដែលលោកបានរៀបរាប់អម្បាញ់មិញហ្នឹង តើមាននរណាខ្លះលោកនៅស្គាល់-- លោកស្គាល់ទេ?

**ឆ៖** អត់សូវស្គាល់គេទេ។

**លោក សេង ប៊ុនឃាង៖**

បាទ ជាបន្តទៀត ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់ឯកសារនៅចំពោះមុខអង្គសនាការក៏ដូចជានៅលើអេក្រង់កុំព្យូរទ័រ។ ឯកសារនោះ គឺមានលេខ E3/367 ឬក៏ D125/167 នៅត្រង់ ERN ជាភាសាខ្មែរគឺ 00251438 ជាភាសាអង់គ្លេសគឺ 00278695 និងជាភាសាបារាំងគឺ 00486010 ហើយឯកសារហ្នឹង គឺជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** នៅក្នុងឯកសារនេះ ដូចដែលបានជម្រាបជូនអម្បាញ់មិញនេះ គឺលោកបានលើកឡើងថា លេខាស្រុកផ្សេងៗទៀត ដែលបានតែងតាំងក្នុងឆ្នាំ១៩៧២ មានដូចជា គី ជាលេខាស្រុកអូររាំង។ ស្វាយ ជាលេខាស្រុកកោះញែក។ ចាំ ជាលេខាស្រុកច្បារ។ ខាំ ភួន ជាលេខាស្រុកកែវសីមា។ តើនេះជាការត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ តើលោកដឹងទេថា បន្ទាប់ពីនេះមកទៀត តើ ខាំ ភួន ដែលជាលេខាស្រុកកែវសីមា ហ្នឹងត្រូវបានតែងតាំងឲ្យធ្វើអ្វីនៅក្នុងគណៈតំបន់ដែរទេ?

**ឆ៖** អត់ដឹងទេ មិនដឹងគេធ្វើខាងអីៗ អត់ដឹងដែរ។

**ស៖** ចុះលោកស្គាល់ឈ្មោះ តាស៊ី ដែរទេនៅពេលនុ៎ង?

[១៥:១៦:១៥]

**ឆ៖** អត់ស្គាល់ទេ ពីព្រោះស្រុកឆ្ងាយពីគ្នា។

**ស៖** លោកអាចជម្រាបជូនអង្គសវនាការបានទេថា នៅៗតំនប់១០៥ របស់លោកហ្នឹង តើមានស្រុកណាខ្លះនៅជាន់នឹងព្រំដែនវៀតណាម?

**ឆ៖** បាទ មានបីស្រុក។

**ស៖** តើស្រុកអ្វីខ្លះ?

**ឆ៖** ទីមួយ ពេជ្រចិន្តា, ទីពីរ អូររាំង, ទីបី កែវសីមា អាហ្នឹងជាប់នឹងព្រំប្រទល់។

**ស៖** តើលោកដឹងទេថា អំឡុងខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ហ្នឹង តំបន់ ១០៥ ហ្នឹងត្រូវមានស្រុកតែប្រាំដដែលតាំងពីដើមរហូតមក ឬក៏មានការបន្ថែម ឬក៏បន្ថយចំនួនស្រុកដែរ?

**ឆ៖** បាទ ស្រុកតាំងពីជំនាន់សង្គមចាស់។

**ស៖** ស្រុកទាំងអស់ហ្នឹង តើមានការបន្ថែម ឬបន្ថយចំនួនទេ ឧទាហរណ៍ថា ពីមុនមានប្រាំថយមកបី ឬក៏មកប្រាំមួយអីចឹង តើមានទេ?

**ឆ៖** អត់ទេ នៅតែប្រាំងដែល។

**ស៖** ចុះលោកនៅចាំទេថា ខាំ ភួន ដែលជាលេខាស្រុកកែវសីមាហ្នឹង គាត់នៅកាន់តួនាទីជាលេខាស្រុកហ្នឹងរហូតដល់ពេលណាដែរ លោកដឹងទេបញ្ហាហ្នឹង?

[១៥:១៩:០៥]

**ឆ៖** ខ្ញុំអត់បានចាំទេ។

**ស៖** ចុះតើលោកស្គាល់មនុស្សម្នាក់មានឈ្មោះថា ហាំ អនស៊ី ដែលជាបងប្អូនរបស់លេខាតំបន់ឈ្មោះ ឡាំង ដែរទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកស្គាល់ ហាំ អនស៊ី ហ្នឹងរយៈពេលប៉ុនណាដែរ?

**ឆ៖** វាភូមិជិតគ្នា។

**ស៖** តើលោកស្គាល់យូរ ឬក៏រយៈពេលខ្លី?

**ឆ៖** យូរហើយ ពីព្រោះភូមិជិតគ្នា វាស្គាល់តាំងពីតូចម្ល៉េះ។

**ស៖** ចុះលោកដឹងទេថា ហាំ អនស៊ី ហ្នឹងគាត់មានតួនាទីអ្វីដែរនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** អត់ដឹងតួនាទីអីទេ ខ្ញុំ។

[១៥:១៧:៤៦]

**លោក សេង ប៊ុនឃាង៖**

បាទ ជាបន្តទៀត ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងឯកសារជាចម្លើយកំណត់ហេតុយកចម្លើយរបស់ឈ្មោះ ហាំ អនស៊ី ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមាននៅក្នុងឯកសារលេខ E3/366 ឬក៏ D125/165 នៅត្រង់ ERN ជាភាសាខ្មែរ គឺ 00242412 ដល់ 13 ហើយនិងជាភាសាអង់គ្លេសគឺ 00250749 ហើយជាភាសាបារាំង គឺ 00283164 ដល់ 65។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ-- សូមអញ្ជើញ!

**លោក គង់ សំអុន៖**

លោកប្រធានសូមអរគុណ។ ខ្ញុំកត់សម្គាល់ឃើញថា ឯកសារដែលតំណាងសហព្រះរាជអាជ្ញា

លើកអម្បាញ់មិញនេះ គឺជារបស់ឈ្មោះ ផ្សេង មិនមែនជារបស់សាក្សីទេអ៊ីចឹង។ ពីព្រោះថា លោកប្រធានអនុញ្ញាតអាចឲ្យប្រើបានដែរទេ បាទ។

ខ្ញុំគិតថា មិនអាចយកមកប្រើប្រាស់ដើម្បីផ្ទាញ់ទៅលើសាក្សី ប្រើប្រាស់ប្រឆាំងទៅនឹងសាក្សីនេះ ដើម្បីឲ្យសាក្សីនេះឆ្លើយថា យ៉ាងណាៗ នោះបានទេ។ ពីព្រោះសាក្សីដែលនឹងត្រូវមានឈ្មោះ នឹងឡើងមកនេះ ក៏មិនបានឱកាសនឹងឆ្លើយតបចំពោះចម្លើយ ដែលនឹងត្រូវលើកនៅពេលនេះដែរ។

[១៥:២៣:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបខ្លីទេទៅនឹងវេទិកានេះ។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសាក្សីដទៃទៀត ដែលនឹងមិនចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ។ ជាពិសេសក្នុងករណីដែលចម្លើយសារភាពនោះ គឺថាសាក្សីដែលត្រូវសួរក៏បានដឹងផងដែរ។ ហើយដោយសាក្សីនោះ ក៏ឮដំណឹងថាគាត់ឈឺផង។ ដូច្នេះ គាត់មិនអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបានទេ។ អ៊ីចឹងអង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីដទៃទៀតទាំងអស់ប្រើប្រាស់ចម្លើយសាក្សី ដែលនឹងមិនចូលខ្លួននេះ ជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះប៉ុន្មានសប្តាហ៍ បីបួនសប្តាហ៍មុននេះរួចមកហើយ។ ហេតុដូច្នេះឯង បានជាសហព្រះរាជអាជ្ញាយកចម្លើយសាក្សីនេះមកសួរ សាក្សីដទៃមកសួរសាក្សីរូបនេះ។ សូមអរគុណ។

[១៥:២៤:៣៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៦:១៤]

**ប្រធានអង្គជំនុំ៖**

បាទ ដោយហេតុឯកសារនេះ គឺជាប្រភេទឯកសារមួយ ដែលអង្គជំនុំជម្រះបានយល់ព្រម និងអនុញ្ញាតកន្លងមកហើយ ចំពោះឯកសារដែលស្តាប់សក្ខីកម្មដោយបណ្តាសាក្សី-- បណ្តាលបុគ្គលផ្សេងទៀត ដោយអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត ហើយសាក្សីនោះគឺអង្គជំនុំជម្រះមិនមានបំណងក្នុងការកោះអញ្ជើញគាត់មកផ្តល់សក្ខីកម្មនាពេលខាងមុខ គឺអនុញ្ញាតឲ្យភាគីអាចលើកយកមក

សួរ ដាក់សួរដេញដោលចំពោះសាក្សីបាន។ ហេតុដូច្នេះ សេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីឱ្យលោក ខៀវ សំផន គ្មានប្រសិទ្ធភាព។

កិច្ចដំណើរការសវនាការ អង្គជំនុំជម្រះវេទិកា-- និងអនុញ្ញាតឱ្យដាក់បង្ហាញឯកសារនេះនៅលើកញ្ចក់អេក្រង់កុំព្យូទ័រ និងទូរទស្សន៍ ហើយនិងអនុញ្ញាតឱ្យដេញដោល។

[១៥:២៧:១៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ចម្លើយរបស់លោក ហាំ អនស៊ី ដែលមាននៅក្នុងឯកសារដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញ គឺគាត់បានលើកឡើងថា គាត់ធ្វើជាសមាជិកស្រុកកែវសីមា ក្នុងឆ្នាំ១៩៧៧។ ហើយនៅពាក់កណ្ដាលឆ្នាំ១៩៧៨ គាត់បាននៅឃុំណងឃីលឹក ដោយហេតុថាប្រជាជនទាំងអស់ត្រូវអង្គការដកចេញពីកែវសីមា ខ្លាចមានទំនាក់ទំនងជាមួយយួន។ តើលោកដឹងទេ ថាប្រជាជនទាំងអស់ដែលត្រូវដកចេញពីកែវសីមា ក្នុងឆ្នាំ១៩៧៨ ដូចការលើកឡើងអ៊ីចឹងមែនដែរទេ?

**លោក សៅ សារុន ៖**

**ឆ៖** បាទ ដកមែន។ ដកពីព្រំដែន មកនៅរង្វង់ស្រុកកោះញែកបាទ។

**ស៖** ចុះលោកដឹងទេ ថាមានមនុស្សប៉ុន្មាននាក់ ដែលបានរស់នៅក្នុងស្រុកកែវសីមានោះ?

**ឆ៖** ខ្ញុំមិនដឹងបានទេ ដឹងចំនួនប៉ុន្មានៗ អត់ដឹងទេ។

**ស៖** ចុះតើពួកគេត្រូវបានផ្លាស់ទីទៅកន្លែងស្រុកកោះញែកតែមួយហ្នឹង ឬក៏ទៅកន្លែងស្រុកផ្សេងទៀតដែរ?

[១៥:២៨:២២]

**ឆ៖** អត់ទេ គឺគេដកមក គឺស្រុក នៅតាមស្រុកតែម្ដង។

**ស៖** បាទ នៅតាមស្រុក ប៉ុន្តែតើនៅមានក្រៅពីស្រុកកោះញែកដែរទេ ឬក៏មានតែផ្លាស់ទៅតែស្រុកកោះញែកហ្នឹងមួយទេ?

**ឆ៖** ដកមកពីកែវសីមានៅក្នុងរង្វង់ស្រុកកោះញែកដដែល ប៉ុន្តែគេរក្សាទុកជាស្រុកកែវសីមាដដែល។

**សៈ** ចុះលោកដឹងទេថា តើហេតុទៅបានជាគេផ្លាស់ទីប្រជាជនអ៊ីចឹង?

**ធៈ** អត់ដឹងទេ ឃើញតែគេដក។

**សៈ** បាទ អរគុណ។ ជាទូទៅ តើលោក ហើយនិងលេខាស្រុកផ្សេងៗទៀតនៅតំបន់១០៥ ហ្នឹងត្រូវរាយការណ៍ទៅខាងណាដែរ?

**ធៈ** រាយការណ៍មកខាងតំបន់ទាំងអស់។

**សៈ** ចុះនរណាគេជាថ្នាក់លើរបស់លោក?

**ធៈ** គឺតំបន់។

**សៈ** តើមានឈ្មោះអ្វីដែរ?

**ធៈ** តាឡាំង។

[១៥:៣១:៣៩]

**សៈ** ចុះ តាឡាំង ហ្នឹង គាត់មានប្រើឈ្មោះហៅក្រៅអ្វីទៀតទេ?

**ធៈ** អត់ទេ ខ្ញុំអត់ដឹងថាហៅក្រៅ ហៅហ្នឹងខ្ញុំអត់ដឹង ដឹងតែគេហៅ តាឡាំង ៗ តែប៉ុណ្ណឹង។

**សៈ** ចុះលោកដឹងដែរទេថា តួនាទី និងការទទួលខុសត្រូវរបស់ តាឡាំង ក្នុងនាមជាលេខាតំបន់ តើជាមេរបស់លោកហ្នឹង គាត់មានតួនាទីអ្វីខ្លះ?

**ធៈ** អត់ដឹងទេ ដឹងតែតួនាទីថាគាត់ជាលេខាតំបន់តែប៉ុណ្ណឹង។

**សៈ** ចុះទាក់ទងទៅនឹងរបបរាយការណ៍ តើលោកដឹងទេថា តាឡាំង ហ្នឹង គាត់រាយការណ៍ទៅណាដែរ?

**ធៈ** អត់ដឹងគាត់រាយការណ៍ទៅណាទេ អស់ដឹងទេរឿងហ្នឹង។

**សៈ** នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យកាន់អំណាចហ្នឹង តើតំបន់១០៥ហ្នឹង ត្រូវបានគេកំណត់ថាជាតំបន់ឯករាជ្យដែរទេនៅពេលនុ៎ង?

**ធៈ** បាទ ជាតំបន់ គេប្រកាសថាឯករាជ្យហើយណា ព្រោះថាវារំដោះមណ្ឌលគិរីហើយ វាឯករាជ្យ។

[១៥:៣៣:២៥]

**សៈ** បាទ អរគុណ។ តើលោកអាចជម្រាបជូនអង្គសវនាការបានទេ ថាតើវាមានភាពខុសគ្នា ឬក៏ភាពប្លែកគ្នាយ៉ាងដូចម្តេចរវាងតំបន់ឯករាជ្យដូចជា តំបន់១០៥ ហ្នឹង ជាមួយនឹងតំបន់ផ្សេងៗទៀត

ដែលជាផ្នែករបស់ភូមិភាគ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** ចុះក្រៅពី តាឡាំង ដែលជាលេខាតំបន់ហ្នឹង តើមាននរណាខ្លះដែលជាសមាជិកតំបន់ហ្នឹង នៅពេលនោះ?

**ឆ៖** បាទ មាន ខាំ ភួន, មាន តាម៉ែ, មាន តាចាំ បាទ ប៉ុណ្ណឹង។

**ស៖** ចុះចំពោះលោក បន្ថែមពីលើតួនាទីរបស់លោកដែលជាលេខាស្រុកហ្នឹង តើលោកមានតួនាទីអ្វីបន្ថែមទេ ឬក៏លោកជាសមាជិកគណៈតំបន់អីដែរទេ ពេលនុ៎ង?

**ឆ៖** បាទ ខ្ញុំអត់មានតួនាទីអីទេ ជាសមាជិកៗ គឺជាលេខាស្រុកដដែលហ្នឹង។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ ហើយខ្ញុំសូមជម្រាបជូនលោកប្រធានដែរថា ខ្ញុំនឹងប្រើឯកសារ D175/3.55 តទៀត។ អ៊ីចឹងសូមឲ្យខាងមន្ត្រី ជំនួយការជួយដាក់បញ្ចូលឯកសារនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ! ផ្នែកខាងសោតទស្សន៍បង្ហាញឯកសារនេះ នៅលើអេក្រង់ទូរទស្សន៍ផង។

[១៥:៣៥:៥៥]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទនៅក្នុងប្រវត្តិរូបបដិវត្តន៍របស់លោក ត្រង់ចម្លើយទី១១ ផ្នែកទី១ ហ្នឹង បានសរសេរថា "លោកធ្លាប់ជាសមាជិកតំបន់ ទទួលខាងសុខាភិបាលតំបន់ និងទទួលខុសត្រូវពីរស្រុក"។ ស្រុកទាំងពីរដែលលោកទទួលខុសត្រូវ ដែលមានសរសេរក្នុងប្រវត្តិរូបនេះ តើមានឈ្មោះអ្វីខ្លះទៅលោក?

**លោក សៅ សារុន៖**

**ឆ៖** បាទ ទទួលពីរស្រុក ជា-- ទទួលខាងសង្គមកិច្ចតំបន់ ខ្ញុំទទួលពីរស្រុក។

**ស៖** តើលោកចាំទេថា ស្រុកណាខ្លះទៅពេលនុ៎ង?

**ឆ៖** មួយ ស្រុកពេជ្រចិន្តា។ ពីរ អូររាំង នៅជិតគ្នា។

**ស៖** ចុះលោកទទួលតួនាទីជាសមាជិកតំបន់១០៥ ទទួលខាងសុខាភិបាលហ្នឹង នៅក្នុងឆ្នាំណាដែរ?

**ឆ៖** ៧៥។

**ស៖** បាទ អរគុណ។ តើលោកមានការទទួលខុសត្រូវជាក់លាក់អ្វីខ្លះ ក្នុងតួនាទីរបស់លោកដែលទទួលខាងសុខាភិបាលហ្នឹង?

**ឆ៖** គេឲ្យជួយណែនាំ និងរៀបចំមន្ទីរសុខាភិបាលហ្នឹង ឲ្យមានមន្ទីរទទួលជំងឺ ឈឺគ្រុនអី ទាំងអស់ រៀបរយផ្ទះសម្បែង និងមន្ទីរពេទ្យឲ្យស្អាត។

**ស៖** តើមានមន្ទីរពេទ្យ ចំនួនប៉ុន្មាននៅក្នុងតំបន់១០៥ នៅក្នុង-- នៃអំឡុងពេលកម្ពុជាប្រជាធិបតេយ្យកាន់អំណាចនុ៎ង?

**ឆ៖** មួយ មន្ទីរពេទ្យតំបន់តាមស្រុកហ្នឹងគេមានតិចតួចៗដែរ តាមស្រុកគេក៏មានគ្រប់ស្រុកដែរ។

[១៥:៣៨:៣៨]

**ស៖** ចុះនៅតំបន់១០៥ ទទួលថ្នាំពេទ្យ ឬក៏សម្ភារៈបរិក្ខាពេទ្យពីខាងណាមកដែរ លោកដឹងទេ?

**ឆ៖** បាទ ទទួលមកពីភ្នំពេញណ៎ា។

**ស៖** តើលោកដឹងទេថា អ្នកណាគេជាអ្នកប្រគល់ថ្នាំពេទ្យ និងសម្ភារៈបរិក្ខាពេទ្យទាំងនេះមក?

**ឆ៖** ខ្ញុំអត់ដឹងទេ ពីព្រោះលេខាតំបន់គេអ្នកទទួលមក។

**ស៖** តាមការពិនិត្យរបស់លោក តើនៅក្នុងតំបន់១០៥ ហ្នឹងមានថ្នាំពេទ្យ និងសម្ភារៈបរិក្ខាពេទ្យគ្រប់គ្រាន់ដែរទេនៅក្នុងអំឡុងពេលហ្នឹង?

**ឆ៖** បាទគ្រប់គ្រាន់បរិក្ខាអី ល្មម មិន-- ក៏មិនសម្បូរបែប ក៏មិនខ្វះ វាល្មមគ្រប់គ្រាន់មើលព្យាបាលប្រជាពលរដ្ឋ។

**ស៖** នៅក្នុងមណ្ឌលគិរីអំឡុងកម្ពុជាប្រជាធិបតេយ្យកាន់អំណាចហ្នឹង តើជាទូទៅច្រើនមានប្រភេទជំងឺអ្វីខ្លះទៅ ឬក៏មានបញ្ហាសុខភាពអ្វីខ្លះដែរទៅនៅទីនុ៎ង?

**ឆ៖** ទីមួយ គឺជំងឺគ្រុនចាញ់ ឯក្រៅពីជំងឺគ្រុនចាញ់នេះក៏មានជំងឺច្រើនប្រភេទ ដូចជា ជំងឺរបេង ជំងឺអី ច្រើនប្រភេទដែរ ខ្ញុំរៀបរាប់មិនអស់ទេ។

**ស៖** បាទ អរគុណ។ ហើយជាបន្តទៀតនេះដែរ ខ្ញុំសូមដាក់ឯកសារដដែលនៅត្រង់ ERN ជាភាសាខ្មែរ អឺ! ឯកសារដដែលគឺ ឯកសារ D175/3.55 ដែលមាន ERN ជាភាសាខ្មែរគឺ 00230782 នៅលើអេក្រង់កុំព្យូរទ័រ ហើយនិង--។

[១៥:៤១:២៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** នៅក្នុងឯកសារនេះ គឺប្រវត្តិរូបបដិវត្តន៍របស់លោកត្រង់ចម្លើយទី១១ នៅផ្នែកទីមួយដដែលហ្នឹងគឺបានសរសេរថា លោកធ្លាប់ជាគណៈទាក់ទងបរទេសតំបន់១០៥ផងដែរ។ តើគណៈទាក់ទងបរទេសតំបន់១០៥ហ្នឹង មានមុខងារធ្វើអ្វីខ្លះដែរ?

**ឆ៖** ទេ អង្គាល់ហ្នឹងគឺ កាលនៅព្រៃហ្នឹងគេ ទាក់ទងបរទេសហ្នឹងពីព្រោះគេមិនចេះភាសាចារ៉ាយហ្នឹង ខ្ញុំវាចេះភាសាចារ៉ាយហ្នឹងទាក់ទងពីរឿងដោះដូរសេដ្ឋកិច្ចគ្នាទៅវិញទៅមកហ្នឹងតែប៉ុណ្ណឹង។

[១៥:៤២:៣៣]

**ស៖** លោកធ្វើការក្នុងគណៈទាក់ទងបរទេសតំបន់១០៥ហ្នឹង តាំងពីពេលណាមក?

**ឆ៖** តែមួយឆ្នាំគត់ គឺឆ្នាំ១៩៧៤ ពេលនៅក្នុងព្រៃ។

**ស៖** ចុះក្នុងនាមលោកដែលជាសមាជិកតំបន់ទាក់ទងបរទេសហ្នឹង តើលោកបានធ្វើសកម្មភាពជាក់លាក់អ្វីខ្លះដែរទៅ?

**ឆ៖** អត់ទេ។ ទាក់ទងតែខាងសេដ្ឋកិច្ចដោះដូរតែប៉ុណ្ណឹងទេ។

**ស៖** ចុះលោកនៅចាំទេថា កន្លែងធ្វើការរបស់តំបន់១០៥ហ្នឹងស្ថិតនៅកន្លែងណាដែរ? ភូមិណា? ឃុំណា?

**ឆ៖** នៅភូមិកោះញែក ស្រុកកោះញែក។ បាទ អស់ប៉ុណ្ណឹង។

[១៥:៤៣:៥១]

**ស៖** កន្លែងធ្វើការហ្នឹងមានឈ្មោះជាលេខកូដអីដែរទេកន្លែងនុ៎ង?

**ឆ៖** បាទ អត់មានទេ។

**ស៖** ចុះលោកស្គាល់ ក-១៧ ជាអ្វីដែរទេ?

**ឆ៖** ក-១៧ ហ្នឹងជាកន្លែងធ្វើការរបស់តំបន់។

**ស៖** បាទ អរគុណ។ តើនៅកន្លែងធ្វើការរបស់តំបន់ហ្នឹងមានអ្នកធ្វើការប៉ុន្មាននាក់ដែរ?

**ឆ៖** អត់ស្គាល់ទេ។ ដឹងមានគ្នីគ្នាប៉ុន្មាននាក់ៗអត់ស្គាល់ដែរ។

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងកិច្ចប្រជុំជាមួយមេដឹកនាំបក្សមុនឆ្នាំ១៩៧៥។ ក្នុងអំឡុងពេលឆ្នាំ១៩៦៣ និងឆ្នាំ១៩៧៥ តើលោកធ្លាប់បានចូលរួមប្រជុំជាមួយមេដឹកនាំបក្សណាខ្លះដែរទេ នៅពេលនុ៎ង?

**ឆ៖** អត់ទេ។

[១៥:៤៥:៣៩]

**ស៖** ចុះនៅក្នុងចន្លោះឆ្នាំ១៩៦៦ ដល់ ឆ្នាំ១៩៧០ តើលោកធ្លាប់ចូលប្រជុំផ្សេងៗនៅខេត្តរតនគិរីដែរទេ?

**ឆ៖** អត់ទេ អត់បានទៅទេ។

**លោក សេង ប៊ុនឃាង៖**

បាទ ជាបន្តទៀតនេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីដាក់ជូនឯកសារលេខ E3/367 ឬក៏ D125/167 ត្រង់ ERN ជាភាសាខ្មែរគឺ 00251437 ជាភាសាអង់គ្លេស 00278693 ហើយជាភាសាបារាំងគឺ 00486009 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

[១៥:៤៧:០៧]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** នៅក្នុងឯកសារនេះ លោកបានឆ្លើយថា មុនឆ្នាំ១៩៧០ ខ្ញុំបានចូលរួមកិច្ចប្រជុំជាមួយ តាឡាំង, តាធុច និង តាយ៉ា នៅអូរលាវ ខេត្តរតនគិរី នៅជិតព្រំប្រទល់វៀតណាម។ តើនេះជាការត្រឹមត្រូវដែរទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ បានប្រជុំ។

**ស៖** ចុះតាធុច និង តាយ៉ា ហ្នឹងជានរណាដែរលោក?

[១៥:៤៧:៥៣]

**ឆ៖** បាទ អត់ស្គាល់អ្នកណាទេ ឃើញតែគេមកប្រជុំជាមួយ តាឡាំង ហ្នឹង គឺឃើញគេ អត់ដឹងគេមកពីណាៗទេ អត់យល់ទេ។

**ស៖** ចុះលោកចាំទេថា កន្លែងប្រជុំហ្នឹងធ្វើនៅកន្លែងណាដែរ? ក្នុងភូមិ ឃុំណាដែរ លោកដឹងទេ?

**ឆ៖** អត់ដឹងទេ ពីព្រោះប្រជុំហ្នឹង កាលនៅក្នុងព្រៃហ្នឹង ប៉ុន្តែដីហ្នឹង គឺដីខាងកម្ពុជាទៅ ជាដីខាងរតនគិរីដែរ។ ជាដីខាងរតនគិរីបាទ។

**ស៖** ចុះលោកអាចដឹងបានទេថា តើអ្នកចូលប្រជុំហ្នឹងមានប៉ុន្មាននាក់ដែរ?

[១៥:៤៨:៤៩]

**ឆ៖** មិនឃើញមានច្រើនទេ ឃើញបី បួននាក់ នៅក្នុងព្រៃមានពីណាទៅច្រើន។ សូមអស់។

**ស៖** លោកនៅចាំទេថា ការប្រជុំហ្នឹងគេពិភាក្សាពីរឿងអ្វីទៅ?

**ឆ៖** បាទ ប្រជុំហ្នឹងគេមានតែនិយាយពីថាប្រមូលកម្លាំងវៃចក្រពត្តិអាមេរិកហ្នឹង ពីព្រោះកាលហ្នឹងវាមានតែឲ្យវៃអាមេរិក កសាងកម្លាំងអាមេរិក រំដោះប្រទេសជាតិ តែប៉ុណ្ណឹង។ សូមអស់។

**ស៖** តើមានលើកឡើងពីប្រធានបទអ្វីផ្សេងពីហ្នឹងទៀតដែរទេ?

**ឆ៖** អត់ អត់ឮ។

**លោក សេង ប៊ុនឃាង៖**

បាទ ហើយខ្ញុំសូមអនុញ្ញាតបន្តបញ្ចាំងនូវឯកសារដដែលនេះ គឺត្រង់ឯកសារ E3/366 ត្រង់ ERN ជាភាសា ខ្មែរ 00251437 និងជាភាសាអង់គ្លេស 00278693 និងជាភាសាបារាំង 00486009 បាទ។

[១៥:៥០:២៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សីនៅក្នុងឯកសារនេះ លោកបានឆ្លើយនៅចំពោះមុខការិយាល័យ មន្ត្រីការិយា-

ល័យសហថៅក្រុមស៊ើបអង្កេតថា "កិច្ចប្រជុំទាំងនេះ និយាយពីការកសាងកម្លាំង វាយចក្រពត្តិអាមេរិក សក្តិភូមិ និងនាយទុន" តើអ៊ីចឹងមែនទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ ដូចខ្ញុំជម្រាបខាងលើអំមិញ។ សូមអស់។

**ស៖** តើនៅពេលនុ៎ង លោកបានទទួលការណែនាំអ្វីខ្លះ ដែលទាក់ទងទៅនឹងការប្រឆាំងនឹងពួកសក្តិភូមិ និងនាយទុនហ្នឹង?

[១៥:៥១:៣១]

**ឆ៖** ពេល តាឡាំង ថាត្រូវវ៉ៃចក្រពត្តិអាមេរិក រំដោះប្រទេសជាតិ ចក្រពត្តិអាមេរិក និងសក្តិភូមិប្រតិកិរិយា គេថាអ៊ីចឹង។ បាទ សូមអស់។

**ស៖** តើពេលនុ៎ង គេបានណែនាំលោកថាឲ្យត្រូវធ្វើយ៉ាងម៉េចដែរទេ ដើម្បីប្រឆាំងនឹងពួកសក្តិភូមិ ហើយនិងនាយទុនហ្នឹង?

**ឆ៖** បាទ អត់បានធ្វើអ្វីសោះ។

**ស៖** សំណួរសួរថា តើពេលក្នុងពេលប្រជុំហ្នឹង គេបានណែនាំលោកថា យ៉ាងម៉េចទេ ដើម្បីវ៉ៃសក្តិភូមិនាយទុននោះ?

**ឆ៖** បាទគេថាវ៉ៃរបបណ៎ះ របបជិះជាន់ណ៎ះ សង្កត់សង្កិនទៅលើប្រជាពលរដ្ឋហ្នឹង។ តែប៉ុណ្ណឹង។ សូមអស់។

**ស៖** តើនៅពេលប្រជុំហ្នឹង លោកបានឃើញមាន ប៉ុល ពត ឬក៏ អៀង សារី ទៅប្រជុំនៅរតនគិរីនោះដែរទេ?

**ឆ៖** ខ្ញុំមិនដែលឃើញគាត់ទេ។

[១៥:៥៣:១៨]

**ស៖** នៅចន្លោះឆ្នាំ១៩៧០ ដល់៧៥ តើលោកធ្លាប់ធ្វើដំណើរទៅចូលរួមប្រជុំនៅខេត្តកំពង់ធំដែរទេ?

**ឆ៖** បាទ ទៅប្រជុំម្តង។

**ស៖** តើលោកនៅចាំទេ ថានៅក្នុងឆ្នាំណាដែរ ប្រជុំហ្នឹង?

**ឆ៖** បាទ អត់ៗ ចាំទេ។ រឿងឆ្នាំ អត់ចាំទេ។

**ស៖** នៅក្នុងការប្រជុំនៅខេត្តកំពង់ធំហ្នឹង តើមានអ្នកណាខ្លះចូលរួមលោក នៅចាំទេ?

**ឆ៖** អត់ចាំពីណាទេ គឺឃើញត្រឹមគេមកប្រជុំក៏ច្រើនដែរ។ ប៉ុន្តែខ្ញុំអត់ដែលស្គាល់គេ ទើបទៅប្រជុំតែម្តងហ្នឹង អត់ស្គាល់ពីណា។ សូមអស់។

[១៥:៥៤:៣១]

**លោក សេង ប៊ុនឃាង៖**

បាទ ជាបន្តទៀតនេះដែរ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងឯកសារដដែល គឺ E3/367 ត្រង់ ERN ជាភាសាខ្មែរ គឺ 00251437 និងជាភាសាអង់គ្លេស 00278694 និងជាភាសាបារាំង គឺ 00486009។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី នៅក្នុងឯកសារនេះ គឺលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា "ក្នុងឆ្នាំ១៩៧១ ខ្ញុំបានចូលរួមកិច្ចប្រជុំនៅខេត្តកំពង់ធំ។ អ្នកចូលរួមមកពីខេត្តមណ្ឌលគិរីមាន ឡាំង និង ម៉ី ហើយអ្នកធំៗមកពីភ្នំពេញឈ្មោះ ធុច និង ប៉ុល ពត"។ តើលោកនៅចាំទេ ថាអ្នកធំៗដែលក្រៅពី ធុច ហើយនិង ប៉ុល ពត ហ្នឹង មានអ្នកខ្លះដែរ?

**លោក សៅ សារុន៖**

**ឆ៖** អត់ស្គាល់ទេ ស្គាល់តែប៉ុណ្ណឹង។

[១៥:៥៦:១០]

**ស៖** តើលោកបានជួប ប៉ុល ពត ហ្នឹង ជាលើកទីមួយ ឬក៏ជាច្រើនលើកមកហើយ?

**ឆ៖** បាទ ជាលើកទីមួយ តែម្តងហ្នឹង ជួបគាត់។

**ស៖** ចុះលោកដឹងទេ ថានៅពេលនុ៎ង ប៉ុល ពត គាត់មានតួនាទីធ្វើអ្វីទៅ?

**ឆ៖** អត់ដឹងទេ ដឹងគាត់ធ្វើអីៗ អត់ដឹងទេ ខ្ញុំដឹងបាទ អត់ដឹង។

**ស៖** ចុះតើលោកស្គាល់ឈ្មោះ ម៉ី ដែរទេ?

**ឆ៖** ស្គាល់ ពីព្រោះគាត់ជា ក្នុងក្របខ័ណ្ឌគណៈតំបន់មណ្ឌលគិរី។

**ស៖** ចុះលោកចាំទេ ថាការប្រជុំនៅកំពង់ធំ ក្នុងឆ្នាំ៧១ហ្នឹង ប្រជុំនៅកន្លែងណា? ហើយមានមនុស្សប៉ុន្មាននាក់ចូលរួមដែរ?

**ឆ៖** អត់ដឹងកន្លែងណាៗទេ ចំនួនមនុស្សចូលរួម ក៏អត់ដឹងដែរ ប្រហែលជា-- អត់ដឹងចំនួនប៉ុន្មានទេ សូមអស់។

**ស៖** តើលោកនៅចាំទេ ថាការប្រជុំហ្នឹងមានរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ប្រហែលជាជិតដប់ថ្ងៃ។ សូមអស់។

[១៥:៥៨:១៣]

**ស៖** បាទ អរគុណ។ តើនៅពេលប្រជុំនុ៎ង តើមានមេដឹកនាំណាខ្លះជាអ្នកធ្វើបទឧទ្ទេសនាម?

**ឆ៖** អត់ឃើញទេ ឃើញតែលោក ប៉ុល ពត តែម្នាក់ ឧទ្ទេសនាម។

**ស៖** តើលោក ប៉ុល ពត ហ្នឹង គាត់ឧទ្ទេសនាមពីអ្វីដែរ?

**ឆ៖** ឧទ្ទេសនាម គេនិយាយពីរឿងរំដោះអាមេរិកដដែល។

**ស៖** ឧទ្ទេសនាមទាក់ទងនឹងរំដោះអាមេរិក តើចុះមានលើកឡើងអំពីការពាក់ព័ន្ធនឹងសង្គ្រាមប្រឆាំងនឹងទាហាន ឬក៏រដ្ឋាភិបាល លន់ នល់ ដែរទេ នៅពេលនុ៎ង?

**ឆ៖** អត់ឮទេ មានតែការប្រមូលកម្លាំងរំដោះអាមេរិក ដើម្បីរំដោះប្រទេសជាតិ តែប៉ុណ្ណឹង។ សូមអស់។

**ស៖** ចុះតាមការដឹងរបស់លោកផ្ទាល់ តើលោកដឹងទេ ថាមន្ត្រី និងទាហានរបស់ លន់ នល់ ហ្នឹង ត្រូវបានគេចាត់ទុកជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាដែរទេ?

[១៥:៥៩:៥០]

**ឆ៖** អត់ដឹងដែរ។

**ស៖** ចុះនៅក្នុងកិច្ចប្រជុំនៅកំពង់ធំ នៅក្នុងឆ្នាំ១៩៧១ ហ្នឹង លោកមានចាំទេថាមានការរៀបចំឲ្យជាសន្និបាតបក្សមួយ ដើម្បីជ្រើសរើសដូចជាសមាជិកគណៈមជ្ឈិម តើមានដែរទេ?

**ឆ៖** អត់ដឹងទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះកិច្ចដំណើរការ

សវនាការសម្រាប់ថ្ងៃនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក គឺថ្ងៃពុធ ទី០៦ ខែមិថុនា ឆ្នាំ ២០១២ ហើយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅស្អែកនេះ គឺនឹងបន្តធ្វើការដោយការតាំងសំណួរដេញដោលចំពោះសាក្សីឈ្មោះ សៅ សារុន ដោយតំណាងសហព្រះរាជអាជ្ញាជាបន្ត។

លោក សៅ សារុន ដោយការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ ហើយសវនាការត្រូវធ្វើបន្ត ធ្វើនៅថ្ងៃស្អែក។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោក សៅ សារុន មកផ្ដល់ បន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ដូច្នេះ-- ដូចគ្នានេះដែរ អង្គជំនុំជម្រះក៏អញ្ជើញមេធាវីប្រឹក្សាសាក្សីសូមចូលរួមសវនាការ ដើម្បីបន្តប្រឹក្សាសាក្សីនៅក្នុងអំឡុងពេលនៃដំណើរការសវនាការសាក្សីរូបនេះរហូតដល់ចប់ ហើយនិងដូចគ្នាគឺអញ្ជើញមកនៅថ្ងៃស្អែកដែរ។

[១៦:០១:៥១]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សីត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់ទីកន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកឲ្យបាន-- នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២នាទី)*